# ទស្សនាវដ្ដីមិត្តសាលាបាលី

លេខពិសេស



លេខ ៣.៤

ឆ្នាំ មមែ

ព.ស. ២៤៩៨

គ.ស. ១៩៥៥

អក្សរ សៅ.ចេស      វិចិត្រ ចុង      ជាង ស៊ីនរ៉ុង

ទីចាត់ការ

វត្តលង្កា សង្កាត់លេខ៦ ក្រុងភ្នំពេញ

អ្នកទទួលឲ្យជាវ – លោក ម៉ៅ-ម៉ុ ក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

–(ក្នុងប្រទេស ថ្លៃជាវ ១ខែ ១០៛, ៦ខែ ៥០៛, ១ឆ្នាំ ១០០៛; ក្រៅប្រទេស ១ខែ ១៣៛, ៦ខែ ៦០៛, ១ឆ្នាំ ១២០៛

បណ្ណាធិការ ហក-ហៀម

55 / 1 / 3.4
1955 2001 / 1954

# មាតិការឿង


ទំព័រ ១

១– កតញ្ញូជនសាស្ត្រ . . . . . . . . . . . ១

២– បចតិចារណាពីសេចក្តីស្លាប់ (ចប់) . . . . . . . . . . លោកហេង-យ៉ាន ៣

៣- សមណនិស្សិត ៣ រូបទៅបំពេញវិជ្ជានៅបរទេស . . . . . . . . . . . ៧

៤– អូហ៎! ដែលសមាគមមិត្តសាលាបាលីមិនដែលលះបង់ ? . . . . . . . . . ១០

៥– សុន្ទរកថា . . . . . . . . . . . . ១១

៦– ចូលឆ្នាំថ្មី . . . . . . . . . . . . . ១៦

៧– ព្រះបរមរិកធាតុ . . . លោក ក៉យ-ប៊ុក ១៩

៨– ប្រដៅភរិយា . . . . . . . . . អ្នកស្រី សខន-សមន . . . ២០

៩– ការសិក្សាក្នុងប្រទេសជប៉ុន . . . . . . . . មហាធាន ២៥

១០– ពត៌មានគួរជឿខ្លះ គួរគិតខ្លះ . . . . . . . . . . . . មហាសម-មីន . . . ៣០

១១– រឿងប្លែក . . . សួនសុរិន្ទ . . . ៣៤

១២– បកិណ្ណកបរិយាយ . . . . . . . . . . . ៤១

១៣– អ្នកណារក្សាទំនៀមទំលាប់ខ្មែរ . . . . . . ៤៦

១៤– សេចក្តីជំពាស់ . . . សស. ភូរិកា . . . ៤៧

១៥– សេចក្តីឆ្លើយ . . . ៤៩

១៦ –រឿងជ័យប្រាជ្ញ (ត) . . . . លោក តៃ-ផុន ៥១

១៧– ប្រវត្តិក្មេងកំព្រា (ត) . . . ៥៥

១៩– សញ្ញាការពារសុភាគអក្ខ័យ (ត) . . . ហាសម-ម៉ីន ៦២

២២– រឿងស្រីកំសត់ . . . មហាសុខមាលី-សេន ១៨

I.K.2f
1955 (3-4)
R.628-7-55





# កតញ្ញូដ៏អស្ចារ្យ

## នៃសម្ដេចព្រះឧបយុវរាជនរោត្តមសីហនុ

## មតិឯកជនក្នុងផ្លូវនៃពុទ្ធសាសនា

នៅថ្ងៃទី ២ មីនា ឆ្នាំ ១៩៥៥ មុននេះ សម្ដេចព្រះឧបយុវរាជនរោត្តមសីហនុបានទ្រង់ថ្វាយរាជសម្បត្តិ ថ្វាយព្រះបាទសម្ដេចព្រះនរោត្តមសុរាម្រិត និងសម្ដេចព្រះអគ្គមហេសី ដែលត្រូវជាព្រះវររាជបិតា និងព្រះវររាជមាតារបស់ទ្រង់ ។

ការទ្រង់ដាក់រាជសម្បត្តិនេះ នាំឲ្យពុទ្ធជនពិភពលោកមានអ្នកកម្ពុជាជាដើម នឹកស្ញើចដល់ព្រះរាជហឫទ័យយ៉ាងក្រៃលែង ; ជាច្រើនសតវត្សមកហើយ ក្នុងគម្រោងនៃប្រវត្តិសាស្ត្រ គេពុំសូវជួបប្រទះនូវស្ថានការណ៍បែបនេះទេ, លោកជនទាំងឡាយធ្លាប់ចំណាំបានមិនភ្លេចថា គ្រប់តែព្រះមហាក្សត្រច្រើនតែស្ងួតស្ងាញចំពោះរាជសម្បត្តិណាស់ មានតាំងបន្តិចកើតទៅជាសង្គ្រាមរវាងជនក្នុងរដ្ឋ ព្រោះតែការចង់បានរាជបល្ល័ង្កមួយប៉ុណ្ណោះ ។ ការស្វែងរករាជបល្ល័ង្កនេះជាកិច្ចមួយយ៉ាងក្របំផុត; ចុះហេតុម្ដេចបានជាសម្ដេចព្រះឧបយុវរាជ របស់យើងមិនមានស្ដាយរាជសម្បត្តិសោះ ព្រះអង្គទ្រង់លះបង់បានដោយងាយ ហាក់ដូចជាបុគ្គលយកដុំដីទៅបោះចោលក្នុងផលសា; នេះជាហេតុមួយនាំឲ្យយើងស្រឡះ តែមតិនៃជនដំបូកខ្លះថា "ព្រះអង្គទ្រង់ងាយទាល់តែជណ្ដើរយករាជសម្បត្តិ" ដោយពិតគឺព្រះអង្គពុំមានស្ដាយស្រណោះសូម្បីបន្តិចសោះសក់ផង ។ នេះសូមសុជនយល់ឲ្យច្បាស់ តាមគោលការណ៍ដូចខាងក្រោម គុំយើងរេះតែស្មានហើយថាតាមយោបល់ៈ

ព្រះអង្គពិតជាព្រះមហាក្សត្រមានព្រះរាជកិត្តិសព្ទល្បីខ្ទរខ្ទាយខាងនយោបាយពេញពិភពលោក ព្រះអង្គពិតជា ព្រះមហាក្សត្រពុទ្ធសាសនូបត្ថម្ភដែលពុទ្ធជនពិភពលោកបានចារឹកក្នុងប្រវត្តិសាស្ត្រ

ព្រះអង្គពិតជាព្រះមហាក្សត្រលះបង់ប្រយោជន៍ផ្ទាល់ ទ្រង់ផ្តល់ចំពោះតែប្រជារាស្ត្រដោយពិត ។

ព្រះអង្គនឹងទ្រង់សាងតាមលំអានព្រះសមណគោតមដែលទ្រង់កំពុងកសាងពីអតីតសម័យមក ។

សុជនទាំងឡាយ យើងបានឮច្បាស់ហើយតាមព្រះរាជសាសន៍ទាំងពីរលើកដែលទ្រង់ផ្សាយតាមវិទ្យុជាតិ មុនដាក់រាជ្យមួយលើកនិងខាងក្រោយមួយលើក ; ព្រះរាជសាសន៍នោះទ្រង់បានលាចំពោះប្រជារាស្ត្រ ជាទីស្នេហារបស់ទ្រង់ ដែលទ្រង់បានយកព្រះជន្មមកប្តូរជាមួយនឹងប្រជារាស្ត្រ ក្នុងសម័យដែលប្រទេសកំពុងស្ថិតក្នុងកាលៈវិបត្តិបាក់ឆ្អា ។

មុនមិនដាក់រាជសម្បត្តិនេះទ្រង់បានពិចារណាដោយច្បាស់លាស់ថាប្រជារាស្ត្ររបស់ទ្រង់កំពុងបែកទៅក្នុងការជាក្រុមក្តាន់ តាមការឃោសនានៃអ្នកនយោបាយ ដែលប្រាថ្នាប្រយោជន៍ចំពោះក្រុមរបស់ខ្លួន ដោយការហុចកាសែតជាជាបន្ទឹមដល់គំរូគំនិតល្អ ; កាសែតដែលមានការគមស៊ីបពាលធន អ្នកអាស្រ័យតែងតែសប្បាយរីករាយជានិច្ច [illegible]លច្បាស់ថាខ្លួនត្រូវក្បែរដោយថ្នាំបំពុលមានក្នុងពេលជាបន្ទាន់នេះទេ ; មិនត្រឹមតែប៉ុណ្ណោះ បើតាមផ្នែកព្រះរាជសាសន៍ទាំងស្រុង គេអាចបម្រុញសេចក្តីបានថា ប្រជារាស្ត្រអ្នកក្រនិងអ្នកក្រីក្របំផុតត្រូវព្រួតមូលធននិងក្រុមមហាសក្តិជំពួកខ្លះ បំបិទភ្នែកជានិច្ចដោយឥតត្រាប្រណី ផញ្ញក់តែឈាមជាតិរបស់ខ្លួនដោយឥតមេត្តា ; ជនជំពួកនេះហើយដែលសម្រាប់បង្វែប្រទេសឲ្យធ្លាក់ចុះក្នុងឋានៈ ដូចសម័យអាណានិគមវិញ

ឱ! ជនរួមជាតិរួមសាសនាទាំងឡាយ ពេលនេះយើងសោយសោកដោយគ្មានផលនៅត្រូវទេ ; យើងស្តាយព្រះអង្គដែលទ្រង់លះបង់រាជសម្បត្តិ តែយើងត្រូវសប្បាយចំពោះព្រះរាជយោបល់ ដែលទ្រង់នឹងបំពេញជាមួយនឹងយើងទាំងឡាយ ក្នុងសម័យនេះ

ទីបំផុតខ្ញុំសូមឲ្យជនរួមឈាមរួមសាសនា ខំលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ប្រយោជន៍ផ្ទាល់ក្រុមគណៈនោះចោលចេញ សូមកុំស្រឡាញ់ដំណែងពេកបើយើងមិនបានបំពេញប្រយោជន៍ដល់ជាតិនិងសាសនាទេ សូមកុំបំភាន់ព្រោះតែយើងចេះនយោបាយ សូមឲ្យចេះវិនិច្ឆ័យកំហុសដោយផ្ទាល់ខ្លួន កុំភាន់ហើយយើងចេះតែជាន់គេ បង្អាប់គេ បន្ទុះបន្ទុលគេឲ្យដើរទៅតាមផ្លូវខ្លួនចាកផ្លូវត្រូវ ។

ត្រូវដើរតាមលំអានពុទ្ធដីកា គឺឲ្យចេះស្រឡាញ់បង្រួបគ្នា រំលែកប្រយោជន៍ដល់គ្នាអ្នកទន់ខ្សោយ មិនមានគំនុំ ប្រាថ្នាតែប្រយោជន៍សាធារណៈផ្ទាល់ពោលខ្លួនផង ចូរមើលឲ្យជាក់ជម្រាយដែលសម្តេច

ព្រះនរោត្តមសីហនុ បានផ្ដាំទុកឲ្យ បង្ហាញឲ្យយើងរាល់គ្នាឃើញច្បាស់ ។

សម្ដេចព្រះឧបយុវរាជនរោត្តមសីហនុ ទ្រង់យាងតាមលំអាននៃអតីតពោធិសត្វ ដើម្បីស្វែងរក

សាមគ្គីទីធំវៀនធម៌ដល់ប្រជាជាតិទាំងមូល

កុំបោលសាសនា កុំប្រហារជាតិ កុំខ្លាចសាមគ្គី

ជយោ! ជយោ! ជយោ!

# បទពិចារណាអំពីសេចក្ដីស្លាប់ (ត)



ដួនច្នារទាំងក្រោរលត់ទៅមុន នៅសល់តែមនោទ្វារដែលគិតតែអារម្មណ៍ចាស់ គឺអារម្មណ៍ធ្លាប់សន្សំមកនោះ ដូច្នេះអាចិណ្ណកម្មជាកម្មសំខាន់បំផុត គង់ពេលទៀបស្លាប់ ។

ការដែលយើងខ្លាចស្លាប់នោះ សំរេចទៅគឺខ្លាចប្រាសចាកវត្ថុដែលគាប់ចិត្ត ក្រែងខានបានជួបប្រទះទៀត ចុះបើស្លាប់ហើយកើតទៀត តំណាបកម្មនោះឯងគាត់តែងតែចាត់ឲ្យបានល្អ ឬឲ្យបានអាក្រក់តាមកុសលនឹងអកុសលដែលបានធ្វើមកហើយ យើងប្រាថ្នាសេចក្ដីល្អ ចង់បានសេចក្ដីសុខ គួរនាំគ្នាសន្សំអំពើល្អ មានធ្វើបុណ្យទាន រក្សាសីលចំរើនភាវនាជាដើម ឲ្យបានរឿយៗជាអាចិណ្ណកម្មទុកសំរាប់នាំទៅកាន់ជាតិមុខ គតិមុខ ឲ្យបានប្រសើរក្រៃលែង

មិនយកចិត្តទុកដាក់ មានតែរៀងនឹងក្លាយជាបំផុត ។

ឯអាសន្នកម្មនោះ គប្បីធ្វើបានតាំងអារម្មណ៍គង់ខណៈចុតិណាស់ ព្រោះពេលស្លាប់សតិបញ្ញាទនថយទៅ គិតតែពីអំពើដែលធ្លាប់សន្សំធ្លាប់ធ្វើមក

ឡើង ៗ យើងក៏បានដឹងស្រាប់ហើយថា យើងជាអ្នកសាងជាតិកំណើតរបស់យើង សាងនរកឬស្ថានសួគ៌សំរាប់ខ្លួនយើង កាលយើងបានប្រមូលនូវគ្រឿងសម្ភារៈដ៏ល្អពោលគឺកុសលកម្មហើយ គួរយើងមានសេចក្តីសង្ឃឹមយ៉ាងមាំថា ការកសាងជាតិកំណើតរបស់យើងមុខជាបានប្រសើរដោយពិត សុគតិភពប្រាកដជាបានដល់ ការលះចោលភពអាក្រក់គឺការស្លាប់ ទៅកាន់ភពល្អមិនគួរនាំឲ្យយើងភិតភ័យខ្លាចទេ ។

ដើម្បីផ្លូវចិត្តកុំឲ្យភ្ញាក់ស្លុតក្នុងការស្លាប់ យើងគួរពិចារណាឲ្យឃើញ ១ នូវសភាពមិនទៀងនៃសង្ខារទាំងឡាយ ដែលកើតឡើងហើយរមែងរលត់ទៅវិញជាធម្មតា ឥតមាននរណាទីង គប្បីដឹងថា “ សេចក្តីស្លាប់មុខជានឹងមានមកដល់អាត្មាអញក្នុងថ្ងៃស្អែក” ដូច្នោះបានទេ ព្រោះសេចក្តីបណ្តោះបណ្តាឲ្យរួចពីសេចក្តីស្លាប់ដែលមានសេនាដ៏ច្រើនពុំមានសោះឡើយ ។ សត្វទាំងឡាយដែលទើបស្លាប់ឥឡូវនេះក្តី ស្លាប់ហួសទៅហើយក្តី នឹងស្លាប់ទៅខាងមុខទៀតក្តីយ៉ាងណា ខ្លួនយើងសោតក៏ មុខជានឹងស្លាប់យ៉ាងនោះមិនខាន សេចក្តីសង្ស័យក្នុងសេចក្តីស្លាប់នុះ មិនគួរមានដល់យើងឡើយ ។ មួយវិញទៀត សេចក្តីស្លាប់នោះមានតាមគ្នាគ្រប់ៗខណៈចិត្ត ជីវិតរបស់យើងប្រកបដោយការស្លាប់ នឹងការកើតឥតគណនា ទាំងរូបទាំងនាម គួរឲ្យនឹកសង្វេគចំពោះសេចក្តីមិនទៀងនេះពន់ពេក សេចក្តីសង្វេគនេះគប្បីបញ្ជូនចិត្តយើង ដាស់សតិយើងឲ្យភ្ញាក់រលឹកជានិច្ច ឲ្យប្រញាប់ប្រញាល់កសាងសេចក្តីល្អចាប់ពីពេលនេះទៅ ព្រោះតែបណ្តែតបណ្តោយហើយ មុខជាមរណៈបោលមកឆក់យើងយកទៅដោយមិនឲ្យដឹងខ្លួន នាំឲ្យកើតសេចក្តីក្តៅក្រហាយស្តាយក្រោយ ដោយមិនបានត្រៀមខ្លួនទុកជាមុន ដូចជនដែលត្រូវចេញចាកផ្ទះដោយឥតបានរៀបចំរបស់ទ្រព្យ ទុកដោយស្រួលបួលឥតបិទទ្វារបង្អួចដោយហ្មត់ចត់ ។

ឧបាយមួយថែមទៀត សំរាប់ត្រៀមខ្លួនទទួលមរណៈនោះ គឺការពិចារណាដល់ការដេកលក់, ការដេកលក់រៀងរាល់រាត្រីដូចគ្នានឹងមរណៈដែរ ព្រោះក្នុងពេលដេកលក់ ខ្លួនប្រាណរបស់យើងនៅស្ងៀមឥតកំរើក ឥតព្រួយទាំងឡាយក៏ស្ងាត់ឈឹង ឥតឃើញអ្វីឬដឹងអ្វីឡើយ ខុសគ្នាតែមានពេលភ្ញាក់ឡើងវិញដល់វេលាព្រឹកឡើងនៅទីកន្លែងដដែល ដូច្នេះហើយបានជាគេហៅសេចក្តីស្លាប់ជាទីឃនិទ្រា គឺការដេកលក់យ៉ាងវែង ឯការដេកលក់នោះក៏មានពេលភ្ញាក់ដែរ តែភ្ញាក់ក្នុងភពដទៃកំណើតដទៃ ។ បើពេលយើងរៀបដេកលក់តាមធម្មតា ចិត្តគំនិតយើងច្របូកច្របល់ដោយគ្រឿងសៅហ្មង យើងតែងយល់សប្តិអាក្រក់ក្នុងពេលដេកលក់ទៅ បើចិត្តគំនិតថ្លាស្រឡះបរិសុទ្ធល្អវិញ ក៏យល់សប្តិឃើញល្អនាំឲ្យរីករាយសប្បាយ សេចក្តីនេះយ៉ាងណាមិញ ពេលនឹងលះចោលលោកនេះ យើងយល់សប្តិឃើញអារម្មណ៍អាក្រក់ល្អតាមអំពើដែលយើងធ្លាប់ធ្វើមក ជាកម្ម-

និមិត្ត ឬ គតិនិមិត្តក៏មានសេចក្ដីយ៉ាងនោះដែរ ។

ដូច្នេះគង់ពេលរៀបដេកលក់នេះហើយ ដែលយើងគប្បីនឹករលឹកដល់កម្មល្អ ដែលយើងបានធ្វើហើយ ដែលយើងត្រូវតាំងចិត្តជំរះកម្មកក្រក់ឲ្យជ្រះស្រឡះចាកសន្ដានចិត្តរបស់យើង ហើយធ្វើចិត្តឲ្យបរិសុទ្ធល្អ ដោយភាវនាគុណព្រះរតនត្រ័យ ឬមេត្តាធម៌ លុះត្រាតែដេកលក់ទៅ ។

ចំណែកការសន្ទនកម្មនោះ គួរតាក់តែងឲ្យបានល្អដែរ នេះជាទំនៀមដែលអ្នកកាន់ព្រះពុទ្ធសាសនាធ្លាប់ធ្វើមក គេតែងរៀបចំកន្ទេលអ្នកជិតស្លាប់ឲ្យស្អាតល្អ មានតាំងពុទ្ធាសនៈយ៉ាងរុងរឿងនិមន្តព្រះសង្ឃមកសូត្រធម៌ ឬចាំបង្ហាប់ឲ្យអ្នកជិតស្លាប់ភាវនាធម៌មានអរហំជាដើម ទាំងនេះដើម្បីធ្វើចិត្តចុងក្រោយបំផុតនៃអ្នកស្លាប់ឲ្យទៅជាចិត្តកុសល ។

គង់ការពិចារណាអំពីមរណៈ យើងបានពោលដល់ជាតិថ្មី គតិថ្មី, ប្រស្នាដែលកើតឡើងដល់យើងគឺ អ្នកស្លាប់, ស្លាប់ហើយកើតទៀតឬទេ ?

យើងដឹងហើយថា តាមបរមត្ថសច្ចវោហារថា មនុស្ស បុគ្គល សត្វនោះគ្រាន់តែជាពាក្យសន្មតឲ្យចូលចិត្តងាយប៉ុណ្ណោះ តាមពិតមានតែរូបនាមខន្ធ អាយតនៈនិងធាតុ មានតែខន្ធទេដែលបែកធ្លាយ រូបនាមទាំង ២ នេះ ដោយការស្រ័យបច្ច័យកើតហើយរលត់ រលត់ហើយកើតតៗគ្នាតាមសន្តតិ បីដូចក្រសែទឹកហូរទៅមិនដាច់រហូតដល់អស់ខន្ធនិព្វាន ។ តែតាមលោកិយវិស័យ គេនិយាយថាមនុស្សស្លាប់ សត្វស្លាប់ ស្លាប់ហើយគេនឹងកើតទៀត វៀរលែងតែព្រះអរហន្ត ។

ចុះអ្វីទៅកើតទៀត ?

ប្រស្នានេះព្រះនាគសេនត្ថេរ បានដោះស្រាយថ្វាយព្រះបាទមិលិន្ទថា មិនមានសភាពអ្វីមួយចេញចាកកាយអ្នកស្លាប់ ទៅកាន់កាយថ្មីទៀតទេ វិញ្ញាណរបស់សត្វដែលនឹងបដិសន្ធិទៀតនោះ មិនបាច់ចាំចេញអំពីខ្លួននេះ ទៅស្វែងរកទីកើតទៀតទេ គឺគ្រាន់តែញាប់ឬងាកបន្តិចទៅ ក៏អាចចាប់បដិសន្ធិកើតបានមួយរំពេចមិនយូរឡើយ ។ បីដូចអណ្ដាតប្រទីបដែលគេអុជបំឡងពីមួយទៅមួយនោះ អណ្ដាតភ្លើងដើមមិនបានឆ្លង ចាកទីដើមទៅកាន់ប្រទីបថ្មីឯណោះទេ ពុំនោះសោតសូរសព្ទសំឡេងរបស់គ្រូអាចារ្យ ដែលប្រាប់ស្លោកគាថាដល់សិស្ស លាន់ឮប្រាកដដល់សិស្ស អាចកត់សំគាល់នូវសព្ទសំឡេងនោះទុកបាន ហើយបញ្ចេញពីមាត់របស់ខ្លួនមកវិញបាន ។

ធ្វើម្ដេចគេឲ្យផុតពីមរណសង្គ្រាម ?

សេចក្ដីស្លាប់ជាភ័យរបស់មនុស្សសត្វគ្រប់ប្រការ ស្លាប់នាំឲ្យកើតទៀត, ឯជាតិតែងប្រកបព្រមដោយទុក្ខគ្រប់ៗប្រការ ដូច្នេះនឹងឲ្យផុតពីសេចក្ដីស្លាប់ ត្រូវធ្វើដូចម្ដេចកុំឲ្យមានជាតិៗ ជាតិជាគ្រឿងសម្ដែងនូវតណ្ហា សេចក្ដីខ្វះខាត សេចក្ដីត្រូវការមិនចេះអស់មិនចេះហើយ ។ ព្រះរដ្ឋបាលត្ថេរពន្យល់ព្រះបាទកោរព្យថា : " លោកគឺពពួកសត្វ មានសេចក្ដីខ្វះខាតជានិច្ចមិនចេះឆ្អែតឆ្អន់ទេ ជាខ្ញុំរបស់តណ្ហា ។ "

តណ្ហានេះនាំឲ្យយើងតស៊ូរកវត្ថុផ្សេងៗជានិច្ច ដើម្បីយកទៅបំប៉នរាងកាយឲ្យសុខស្រួល ។ ឯរូបរាងកាយរបស់យើងនេះជាសម្បត្តិនៃភពទាំងឡាយ ជាប្រភពនៃសេចក្តីទុក្ខលំបាក រូបរាងកាយមិនឋិតថេរទេ តែងតែប្រែប្រួលទៅជានិច្ច នាំឲ្យតែកើតទុក្ខ ហើយមិននៅក្រោមអំណាចរបស់យើងផង យើងត្រូវការបែបនេះ វាប្រែប្រួលទៅជាបែបនោះទៅវិញ ។

កាលយល់ច្បាស់នូវលក្ខណៈ នៃសង្ខារទាំងឡាយថាមិនទៀងទាត់ជាទុក្ខ មិនមែនជារបស់ខ្លួន ហើយយើងក៏ឈប់ជាប់ចិត្ត ស្រឡាញ់ខ្លួនរបស់យើង លែងសំគាល់ថា នុ៎ះយើង នុ៎ះជារបស់យើង នុ៎ះជាយើងតទៅទៀត យើងកាត់ឫសគល់តណ្ហាចោលឥតសេសសល់លែងខ្វះខាត លែងត្រូវការទៀត ជាតិថ្មីក៏លែងមានដល់យើង មរណៈក៏ផុតអំណាចនឹងញាំញីយើងបាន សមដូចពុទ្ធភាសិតព្យាករណ៍ប្រស្នាមោឃរាជមាណពថា:

“មោឃរាជ បុរសមានសតិគ្រប់ពេល សំឡឹងមើលលោកដោយសេចក្តីថាជារបស់សូន្យ ដកសេចក្តីយល់ឃើញថាមានអត្តាចេញទៅ អ្នកនឹងបានជាអ្នកឆ្លងផុតនូវមច្ចុរាជបាន មច្ចុរាជរមែងមិនសំឡឹងមើលនូវអ្នកដែលរមិលមើលលោកបែបនេះ ។„

ការពិចារណាអំពីមរណៈមកប៉ុណ្ណេះ អាចនាំឲ្យយើងឃើញថា ពុំមានទីណាកន្លែងណានឹងចៀសឲ្យផុតស្លាប់បានទេ កាលបើជាតិមានហើយ ។ ឯសេចក្តីស្លាប់នេះតែងប្រព្រឹត្តទៅជានិច្ចគ្រប់ពេល មានតែការដកខ្លួនឲ្យផុតពីសេចក្តីប្រកាន់ថាយើង ថារបស់យើងប៉ុណ្ណោះ ទើបឃ្លាតចេញពីតណ្ហាបត់តណ្ហាបាន លែងសាងជាតិសាងកំណើតទៀត ។ ការឈប់លែងប្រកាន់ថាយើងនេះ នាំឲ្យកើតមេត្តាធម៌ដ៏ធំទូលាយ ឆម្តាអ្នកបណ្តុះមេត្តា អ្នកភាវនាមេត្តារមែងដេកជាសុខ ភ្ញាក់ឡើងជាសុខ រស់នៅជាសុខ ដល់ស្លាប់ក៏សុខទៀត ។ ដើម្បីត្រៀមខ្លួនទទួលនូវមរណៈដោយមិនតក់ស្លុត គប្បីយើងពិចារណានូវសេចក្តីស្លាប់រឿងរាល់ពេល ឲ្យកើតសេចក្តីសង្វេគចំពោះសេចក្តីមិនទៀងនៃសង្ខារទាំងឡាយ ហើយប្រញាប់ប្រញាល់បំពេញសេចក្តីល្អទុក ។

សូមស្រង់ភាសិត ១ កន្លែងក្នុងសំវេជនីយគាថាមកចារិកចុះក្នុងទីនេះ ជាបញ្ចប់បទពិចារណាអំពីមរណៈ:

“សត្វទាំងឡាយប៉ុន្មានតែនឹងស្លាប់គ្រប់គ្នាទាំងអស់ ព្រោះថាជីវិតសត្វតែមានសេចក្តីស្លាប់ជាទីបំផុត ។ សត្វទាំងឡាយសុទ្ធសឹងតែត្រូវទទួលនូវផលបុណ្យនឹងផលបាប តាមសមគួរដល់អំពើដែលខ្លួនធ្វើ ហើយចេញទៅកាន់បរលោកនាយ សត្វណាដែលធ្វើនូវអំពើបាប សត្វនោះត្រូវទៅរងទុក្ខក្នុងនរក សត្វណាដែលធ្វើនូវអំពើបុណ្យ សត្វនោះត្រូវទៅសោយសុខក្នុងសុគតិភព ។ ព្រោះហេតុនោះ សាធុជនគួរតែប្រញាប់ប្រញាល់ ធ្វើនូវអំពើបុណ្យដែលជាគុណគឺអ្នកប្រាជ្ញតែងរាប់អាន ឲ្យបានជាកំណប់ជាប់តាមទៅក្នុងបរលោក បុណ្យទាំងឡាយរមែងបានជាទីពឹងពំនាក់របស់សត្វទាំងឡាយទៅ ក្នុងលោកខាងនាយ „ ។

ហោ ង៉-យ៉ាំង

# សមណនិស្សិតបីរូបទៅបំពេញវិជ្ជានៅបរទេស



សមាគមមិត្តសាលាបាលី បានចាត់សមណៈនិស្សិតបីរូបគឺព្រះមហា គាំ-សួន , មាស-ចន, កា-យ៉ាវ, ឲ្យនិមន្តទៅបន្តវិជ្ជាព្រះពុទ្ធសាសនានៅមហាវិទ្យាល័យនាលន្ទាប្រទេសឥណ្ឌា ។ ការនេះជាបឋមហេតុ ដែលសមាគមខំប្រឹងរកអស់រយៈពេលជាង ៤ ខែមកហើយទើបបានសម្រេច ។

កាលពីយប់ថ្ងៃព្រហស្បតិ៍ទី ៣ កុម្ភៈ សមាគមបានរៀបចំ ធ្វើពិធីប្រសិទ្ធិពរដល់សមណៈនិស្សិតទាំងបីរូបនេះ; ក្នុងពិធីមង្គលនោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា បានប្រទានឱវាទយ៉ាងច្រើនដោយមានបវរដីការថា " លោកទាំងឡាយត្រូវតាំងចិត្តអប់រំវិជ្ជាដោយប្រពៃ ត្រូវមានវីរិយៈនិងខន្តីជាអាទិ៍ " រួចក៏ប្រទានការជាច្រើនតទៅទៀត បន្ទាប់ពីនោះ លោកម៉ៅ មុំ បានប្រកាស អំពីបច្ច័យដែលបានមកពីទីនានា មានព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ របស់សម្តេចព្រះឧបយុវរាជ កាលទ្រង់គង់នៅក្នុងរាជសម្បត្តិនៅឡើយ ៤០០០៛ សម្តេចធម្មលិខិត ១០០០៛ ពុទ្ធិកសមាគម ៣០០០៛ និងបុណ្យផ្កានានាមានផ្ញើនៅទីក្រុងភ្នំពេញ , តាកែវ , កំពង់ចាំជាដើម , បន្ទាប់មកទៀត ឯ.ឧ សម-ញាណ ប្រធានពុទ្ធិកសមាគម បានថ្លែងសេចក្តីអំណរយ៉ាងសង្ខេប តែមានអត្ថរសជ្រាលជ្រៅដោយន័យថា " ព្រះករុណាខ្ញុំគិតថា ទោះបើលោកម្ចាស់ទាំងបីរូប បានជ្រាបច្បាស់ចំពោះការលំបាកគ្រប់យ៉ាង នៅមហាវិទ្យាល័យនាលន្ទា ក៏គង់តែមានព្រះទ័យដម្កល់ខ្ជាប់ពុំព្រមរាថយពីការសិក្សា នេះហើយ ជាគុណការពិសេស,តែសូមលោកម្ចាស់ជាឲ្យច្បាស់ថា មានជនខ្លះគេបានពោលជាញឹកញាយថា ចុះខ្ញុំដែរ សមាគមមិត្តសាលាបាលីបន្តិចថាពួកខ្លួនលោកសង្ឃឲ្យទៅសិក្សានៅប្រទេសនោះប្រទេសនេះ តើទៅរៀនយកសញ្ញាប័ត្រអ្វី? ចំណែកខាងគ្រហស្ថវិញ គេចេញទៅរៀនយក



សញ្ញាប័ត្របណ្ឌិតខាងពេទ្យ, អក្សរសាស្ត្របរទេស ច្បាប់ ។ល។ នោះទើបមានប្រយោជន៍ដល់ប្រទេសជាតិ! បញ្ហានេះមិនគាប់ត្រចៀកដល់ក្រុមយើងអ្នកពុទ្ធសាសនាទេ, ប្រហែលជាអ្នកផងនោះ មានតែមាត់ហើយ ចាំតែបាប៉ុណ្ណោះ ពុំបានពោលបក្ខុំវិញពិតពលោកទេមើលទៅ, ខ្ញុំព្រះករុណាសូមផ្តាំថាសូមលោកម្ចាស់ទៅសិក្សា ដើម្បីដោះបញ្ហានេះដល់សាសនានៃពលរដ្ឋផង គណិតព្រះពុទ្ធសាសនា ប្រទេសកម្ពុជាផងៗ



ពិធីនោះក៏បានបញ្ចប់នៅម៉ោង ២១,៣០ នាទី ។



ថ្ងៃសុក្រទី៤កុម្ភៈ ម៉ោង ១៥ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថបានជូនដំណើរសមណៈនិស្សិតទាំងប៉ុន្មានេះទៅចំណតអាកាសយានពោធិ៍ចិនតុង ផ្នែកខាងព្រះសង្ឃគេឃើញសម្តេចធម្មលិខិតព្រះតេជព្រះគុណពោធិវង្សជាដើម, ផ្នែកខាងគ្រហស្ថមានលោក



វ៉ាយ-ប៊ុក ប្រធាន សមាគមមិត្តសាលាបាលី ឯ.ឧ. សម-ញាណ ប្រធានពុទ្ធិកសមាគមជាដើម ក្នុងការជូនដំណើរនេះ ក្រុមពុទ្ធបរិស័ទ សឹងតែមានសេចក្តីត្រេកអរគ្រប់គ្នា ដោយយោបល់ថាប្រទេសកម្ពុជាតទៅនឹងមានសមណទូត ខាងសាសនាជាប្រាកដទៅអនាគត , ការជូនដំណើរនេះគួរឲ្យប្លែកខ្លាំងណាស់ ទោះបើអាកាសយានរៀបអណ្តែតខ្លួនចេញផុតពីផែនដីហើយក៏ដោយ ក្រុមពុទ្ធបរិស័ទដែលជាអ្នកជូនក៏នៅតែមានមកបន្តគ្នាទាំងបព្វជិត នឹងគ្រហស្ថ នេះសឲ្យឃើញថា ពុទ្ធជនកម្ពុជរដ្ឋមានស្វាមីភក្តិយ៉ាងខ្លាំងចំពោះសាសនា ។

ម៉ោង១៥,២៥នាទីអាកាសយានថៃ បានដឹកសមណនិស្សិតរបស់យើង ចេញពីចំណតអាកាស-យានបន្តិចម្តងៗ លុះផុតចក្ខុនៃពុទ្ធបរិស័ទអ្នកជូនដំ-ណើរ ។

ទីបំផុតនេះ យើងខ្ញុំទូលព្រះបង្គំតាងនាមសមាគមមិត្តសាលាបាលី សូមថ្វាយព្រះរាជកុសលដ៏ថ្លៃថ្លាចំ-ពោះសម្តេចព្រះឧបយុវរាជ សូមឲ្យព្រះអង្គសម្រេចតាមព្រះរាជន-យោបាយ, សូមថ្វាយព្រះរាជកុសចំ-ពោះព្រះករុណាថ្លៃវិសេស ព្រមទាំងអគ្គមហេសី សូមព្រះអង្គស្តេចគង់ជាសេរីក្នុងការគ្រប់គ្រងរដ្ឋ, សូមពុទ្ធបរិស័ទដែលបានជូនដំណើរសមណ-និស្សិតនោះដោយបានរង់ចាំអស់កាលយូរក្តី , ឆាប់ក្តីមកដល់ហើយអាកាសយានអណ្តែតទៅក្តី មកពុំទាន់ពុំបានជូនក្តី ក៏សូមឲ្យសម្រេច តាមបំណងគ្រប់ប្រការ ។

បើអស់លោកចង់បានសមណៈទូត ឆាប់កើតឡើងសម្រាប់ប្រទេសយើងក៏សូមកុំភ្លេច សមាគមមិត្តសា-លាបាលី ប្រកានទស្សនាវដ្តីមិត្តសាលាបាលីឲ្យសោះ ។

# អ្វីហ្ន៎ ដែលសមាគមមិត្តសាលាបាលីមិនដែលលះបង់ ?

គឺបុណ្យព្រហ្មទាន



កិច្ចពិធីសំខាន់របស់សមាគមមិត្តសាលាបាលី ក្នុងឆ្នាំ ១៩៥៥ នេះបានប្រកាសនៅថ្ងៃអាទិត្យទី ៦ មីនា ១៩៥៥ ។

គេចាំបា្រស់ថាពិធីនេះជាបវេណីរបស់សមាគម បានចាត់ចែងឡើងជារៀងរាល់ឆ្នាំ ។ នៅយប់ថ្ងៃសៅរ៍ទី ៥ មីនា បាននិមន្តព្រះសង្ឃចំរើនព្រះបរិត្តនៅសាលាបាលីជាន់ខ្ពស់, ក្នុងព្រឹបវេណីនេះគេឃើញឥស្សរជនទាំងព្រះសង្ឃនិងគ្រហស្ថជាច្រើន និមន្តនិងអញ្ជើញដោយកិត្តិយស ។

ថ្ងៃអាទិត្យទី ៦ មីនាមុនម៉ោង ១៦ គេឃើញឥស្សរជនជាច្រើនរូប អញ្ជើញទៅដល់ទាំងរដ្ឋមន្ត្រីនិងអគ្គទូតគ្រប់ឋានៈ ម៉ោង១៧គត់ ឯ.ឧ ឃឹម-ទិតជាព្រះរាជតំណាងអញ្ជើញទៅដល់ ដោយមានទាហានទង់ភ្លេងចាំគោរពៗ

លោក ភ៉យ-ប៊ុក ប្រធានសមាគមមិត្តសាលាបាលីបានផ្ដើមថ្លែងសុន្ទរកថា ទទួលអំណរចំពោះឥស្សរជនដែលមានឯ.ឧ. ឃឹម-ទិត ជាប្រមុខ, បន្ទាប់មក ទើបព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់បានថ្លែងសុន្ទរកថាមួយទៀត មានសេចក្ដីគួរចាប់ចិត្តយ៉ាងក្រៃលែង ។

ម៉ោង១៧,៣០ ពិធីចែករង្វាន់ក៏ចាប់ផ្ដើមឡើង លុះត្រាតែដល់ម៉ោង១៨ទើបចប់ ។

នៅទីបញ្ចប់នេះ ឯ.ឧ ឃឹម.ទិត ជាព្រះរាជតំណាង លោកបានថ្លែងបាឋកថាមួយយ៉ាងខ្លីដូចតទៅ :

ថ្វាយបង្គំព្រះថេរានុត្ថេរៈ ជំរាបអស់លោកទាំងឡាយ ខ្ញុំមានសេចក្ដីត្រេកអរណាស់ចំពោះការណ៍ដ៏ប្រសើររបស់សមាគម ដែលបានខំខ្នះខ្នែងក្នុងពិធីដ៏ប្រពៃនេះ ព្រោះខ្ញុំយល់ឃើញថា ប្រទេសកម្ពុជាយើងមានព្រះពុទ្ធសាសនាជាគោល ដែលអាចរក្សាខ្ជាប់នូវធម្មនិយមប្រទេសជាតិ ដែលមិនវិលទៅ

តាមបក្រសម័យនេះបាន គឺតោងអាស្រ័យគ្នានឹងធម្មនិយម ។

របបនិយមនិងធម្មនិយមទុកដូចជាចក្រ ដែលត្រូវតែវិលទៅស្របគ្នា បើមិនស្របទៅតាមគ្នាផង មិនអាចទៅដោយស្រួលបានឡើយ , ត្រូវព្រះករុណាគ្រប់អង្គ អស់លោកចាំច្បាស់ថា ប្រទេសកម្ពុជាយើងមានព្រះពុទ្ធសាសនាជាធម្មនិយម ។

គេចាំបានថា ពិភពលោកកំពុងត្រិះរិះស្វែងរកសន្តិភាពតាមរបបនិយម តែសន្តិភាពនោះនឹងមិនមានដម្លៃថ្លៃថ្នូរប៉ុន្មានទេ គង់នឹងរលាយបាត់បង់ទៅវិញ បើណែកធម្មនិយមវិញ នឹងអាចរកសន្តិភាពឲ្យឃើញច្បាស់ដោយជាក់ស្តែង ពិតមែនតែប្រទេសរបស់យើងតូច តែមានកេរ្តិ៍ឈ្មោះនិងកិត្តិសព្ទដ៏ថ្លៃថ្លាដោយសារព្រះមហាក្សត្រ និងព្រះពុទ្ធសាសនានេះឯង លុះយូរទៅអ្នកស្វែងរកសន្តិភាព គង់រត់រកព្រះពុទ្ធសាសនាដូចប្រទេសយើងមិនខាន ។

ទីបំផុតខ្ញុំសូមព្រះករុណាម្ចាស់ពល់អង្គ អស់លោកទាំងឡាយប្រឹងរក្សាឲ្យខ្ជាប់ខ្ជួនធម្មនិយមដើម្បីរក្សាសន្តិភាព, និងសូមឲ្យសមាគមមិត្តសាលាបាលីមានជីវភាពដ៏ថ្លៃថ្នូរឡើងគ្នា លុះត្រាផុតកំណត់កាលព្រះពុទ្ធសាសនា ដែលព្រះពុទ្ធជាម្ចាស់បានប្រតិស្ឋានទុកមកហើយ ។

កាលបើចប់ហើយសូរទះដៃគំលាំងពីរដងឡើងជានិច្ច ទទួលអំណរដោយគោរព ។

ពិធីចែករង្វាន់ដល់សិស្សប្រឡងចេញពីសាលាបាលីជាន់ខ្ពស់បញ្ចប់នៅម៉ោង ១៨,៣០ ។

---

## សុន្ទរកថា

របស់សាលាបាលីជាន់ខ្ពស់

### ក្នុងឱកាសចែកព្រហ្មទានដល់សិស្សដែលប្រឡងចេញក្នុងឆ្នាំ១៩៥៥នៅថ្ងៃអាទិត្យទី៦មីនា១៩៥៥

សូមចំរើនពរឯកឧត្តម ជាព្រះរាជតំណាងនៃព្រះករុណាជាម្ចាស់ជីវិត,

សូមថ្វាយបង្គំដោយគោរពចំពោះ សម្តេច,

សូមថ្វាយព្រះពរទ្រង់,

សូមចំរើនពរឯកឧត្តម និងអស់លោក-អ្នកទាំងឡាយ,

អាត្មាភាពជាតំណាងបុគ្គលិកទាំងអស់ ក្នុងសាលានេះ មានអំណរដ៏ក្រៃលែង ចំពោះឯកឧត្តមជាព្រះរាជតំណាង ចំពោះសម្តេច, ទ្រង់, ឯកឧត្តមនិងអស់លោក-អ្នកទាំងឡាយ ដែលបានអញ្ជើញមក និមន្តមក ស្តេចមក ជាអធិបតី ជាកិត្តិយសនិងជាមង្គលក្នុងឱកាសបុណ្យ ចែកព្រហ្មទាន

នេះ ព្រោះទស្សនកិច្ចក្នុងទីនេះប្រាកដដូចជាបាននាំយកនូវកិត្តិយសដ៏ខ្ពង់ខ្ពស់, នូវសិរីសួស្តីដ៏ប្រសើរ នូវជោគជ័យដ៏ឧត្តម មកប្រគល់ដល់សាលាបាលីជាន់ខ្ពស់នេះ កិត្តិយសជាដើមនេះហើយដែលនាំឲ្យសាលានេះមានដំណើរទៅកាន់សេចក្តីចំរើន ដោយស្រួលក្នុងអនាគតបាន ។

លំដាប់អំពីនេះ អាត្មាភាពសូមទានឱកាសបន្តិច ដើម្បីថ្លែងអំណរចំពោះសមាគមមិត្តសាលាបាលី និងដើម្បីថ្លែងសេចក្តីក្រើនរំឭកប្រាស្រ័យនឹងព្រះសង្ឃជានិស្សិតនៃសាលានេះដូចតទៅ ។

អម្បាញមិញនេះ លោកប្រធាននៃសមាគមមិត្តសាលាបាលីបានថ្លែង សេចក្តីអំពីការប្រគេនរង្វាន់ដល់សង្ឃជានិស្សិត ដែលទើបប្រឡងចេញពីសាលានេះ និងសិស្សខ្លះកំពុងសិក្សាដែលបានពិន្ទុដ៏ប្រសើរក្នុងថ្នាក់រៀន ។

ការចែករង្វាន់ដូច្នេះ អាចរាប់បញ្ចូលទៅក្នុងការកុសលដែលនឹងជូនលទ្ធផលក្នុងបច្ចុប្បន្ន និងបរលោកបាន ។

សាលាបាលីជាន់ខ្ពស់ សូមទទួលអំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលី ដែលផ្តើមធ្វើការកុសលដូច្នេះជាច្រើនឆ្នាំមកហើយ ដោយឥតរួញរា ប៉ុន្តែសមាគមដែលអាចធ្វើដូច្នេះបាន ដោយអាស្រ័យការឧបត្ថម្ភអំពីព្រះករុណាជាអម្ចាស់ជីវិត , អំពីក្រសួង, ឯកឧត្តម និងឥស្សរជនទាំងឡាយព្រមទាំងពួកពុទ្ធបរិស័ទ ជួយដោយសទ្ធាជ្រះថ្លាផងដែរទើបអាចធ្វើកល្យាណកម្មនេះឲ្យសម្រេចបាន ។

សាលាបាលីជាន់ខ្ពស់ សូមអរគុណចំពោះសមាគមមិត្តសាលាបាលី ជាច្រើនអនេក ដោយឃើញថាសមាគមនេះ បានបំពេញកិច្ចដ៏ប្រសើរច្រើនយ៉ាងដែលជាកិច្ចជួយឲ្យគម្ទាំង ដល់ការសិក្សាខាងព្រះពុទ្ធសាសនា មានការចែកវត្ថុសម្រាប់សិក្សាដល់សាលាបាលីរងជាង ៤០០ សាលាក្នុងព្រះរាជាណាចក្រកម្ពុជាផង ជួយផ្តើមធ្វើបុណ្យចែកព្រហ្មទានដល់សិស្ស ក្នុងសាលាបាលីជាន់ខ្ពស់រាល់ឆ្នាំផង មិនតែប៉ុណ្ណោះបានឈ្វៀតឱកាសជួយឧបត្ថម្ភក្នុងការចាត់ព្រះសង្ឃជានិស្សិតចេញពីសាលានេះ ឲ្យទៅបន្តការសិក្សាក្នុងប្រទេសក្រៅផងទៀត ដូចកាលពីថ្ងៃសុក្រទី ៤ មីនានោះ មាននិស្សិត ៣ រូបបានចេញទៅបន្តការសិក្សាក្នុងវិជ្ជាស្ថានបាលី នៅនាលន្ទាប្រទេសឥណ្ឌា ការចាត់ឲ្យទៅសិក្សានេះ ជាបន្ទុកនៃសមាគមមិត្តសាលាបាលី ។

តពីនេះ សូមរំលឹកប្រាស្រ័យដល់ព្រះសង្ឃជានិស្សិតនៃសាលានេះ

អស់លោកជានិស្សិតទាំងឡាយ !

ការសិក្សារៀនសូត្របំណេះវិជ្ជា គ្រប់ប្រភេទក្នុងលោកនេះ រមែងដឹកនាំមនុស្សក្នុងពិភពលោក

ឲ្យមានការប្រែប្រួលត្រឡប់ពីអាក្រក់ទៅល្អ ពីឋានៈថយថោកទៅកាន់ឋានៈដ៏ខ្ពង់ខ្ពស់ ពីការល្ងង់ខ្លៅទៅកាន់ការចេះដឹង ដូចយើងបានឃើញនឹងភ្នែកស្រាប់ ហើយសេចក្ដីថ្កុំថ្កើងសេចក្ដីចំរើនរុងរឿងជាផលបានមកអំពីចំណេះវិជ្ជា ៗ បានមកអំពីការសិក្សារៀនសូត្ររបស់មនុស្សក្នុងលោក ។ បណ្ដាចំណេះវិជ្ជាទាំងនោះ ការសិក្សាព្រះបរិយត្តិធម៌ និងការសិក្សាវិជ្ជាផ្សេងៗក្នុងសាលាបាលីជាន់ខ្ពស់នេះ មានវិទ្យាសាស្ត្រ, បវត្តិសាស្ត្រ, គណិតសាស្ត្រនិងភូមិសាស្ត្រជាដើម អាចរាប់បញ្ចូលទៅក្នុងចំណេះវិជ្ជាផ្នែក ១ ក្នុងលោកបានដែរ បើចំពោះប្រទេសកម្ពុជាយើងនេះ ជនជាតិខ្មែរយើងក្នុងអតីតកាល បានផ្ដាប់និយមរាប់អានថាជាចំណេះវិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិ ព្រោះគោលចារឹកសំខាន់ ៗ នៃវប្បធម៌ខ្មែរមានអក្សរសាស្ត្រជាដើម តាំងពីសម័យបុរាណ រហូតមកដល់សម័យបច្ចុប្បន្ននេះ រមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។

អស់លោកជាសិស្សទាំងឡាយ !

អស់លោក ដែលបានប្រឡងចេញពីសាលាហើយ ទុកជាចប់កិច្ចសិក្សារបស់លោកក្នុងសាលានេះហើយ ប៉ុន្តែសូមកុំឲ្យគិតច្រឡំថាកិច្ចសិក្សាចំណេះវិជ្ជាចប់ស្រេចត្រឹមបានទទួលសញ្ញាប័ត្រពីសាលានេះដូច្នេះឡើយ ហើយបោះបង់គំនិតក្នុងការសិក្សាតទៅទៀត ។

ឯការសិក្សាក្នុងសាលាបាលីជាន់ខ្ពស់នេះកាលបើយកទៅប្រៀបផ្ទឹមនឹងការសិក្សា ក្នុងសាលារៀនខាងព្រះពុទ្ធសាសនានៅប្រទេសឯទៀត ឃើញនៅអន់ថយច្រើនជាងគេ ដូចប្រទេសដែលមានព្រះពុទ្ធសាសនាដូចគ្នានឹងប្រទេសយើងសព្វថ្ងៃនេះ គឺប្រទេសថៃ, ភូមានិងសិរីលង្កា គេបានបង្កើតមហាវិទ្យាល័យខាងព្រះពុទ្ធសាសនាឲ្យមានឡើងជាយូរឆ្នាំមកហើយ ព្រោះប្រទេសទាំងនោះមានឧត្តមគតិដ៏ប្រសើរ ១ យ៉ាង គឺចង់ឲ្យព្រះសង្ឃបានចេះដឹងវិជ្ជាខាងផ្លូវធម៌សាសនាឲ្យម៉ាំមួន ព្រមទាំងភាសាបរទេសផង កាលបើព្រះសង្ឃបានចេះដឹងហើយ នឹងបានបញ្ជូនព្រះសង្ឃទាំងនោះទៅកាន់នានាប្រទេស និងប្រកាសពីព្រះពុទ្ធសាសនា ដើម្បីឲ្យប្រទេសទាំងនោះបានស្គាល់នូវព្រះពុទ្ធសាសនាយ៉ាងជាក់ច្បាស់ ។

សព្វថ្ងៃនេះ ប្រទេសលង្កាកំពុងចាត់ព្រះសង្ឃចេញទៅកាន់ប្រទេសផ្សេង ៗ ។ ប្រទេសភូមាក៏កំពុងខំប្រឹងបង្កើតវិទ្យាល័យ ធម្មទូតសម្រាប់ព្រះសង្ឃរៀនសូត្រ ។ ក្នុងវិទ្យាល័យធម្មទូតនៅប្រទេសភូមានោះ សព្វថ្ងៃនេះ មានព្រះសង្ឃខ្មែរជានិស្សិតនៃសាលានេះចំនួន ១១ រូបបានចូលទៅសិក្សារួមជាមួយនឹងព្រះសង្ឃភូមា បានចេះភាសាភូមានិងភាសាអង់

គ្រួសយ៉ាងមធ្យមហើយ គោលបំណងនៃពុទ្ធសាសនសភានៅប្រទេសភូមាដែលមានរដ្ឋាភិបាលជួយឧបត្ថម្ភ, ប្រាថ្នានឹងឲ្យព្រះសង្ឃដែលរៀនក្នុងវិទ្យាល័យនោះ មានវិជ្ជាគ្រប់គ្រាន់ ល្មមធ្វើជាធម្មទូតចេញទៅប្រកាសព្រះពុទ្ធសាសនា ក្នុងនានាប្រទេសទៅបាន ។

កុំបាច់ពោលចំពោះប្រទេសដែលមានព្រះពុទ្ធសាសនាយ៉ាងបរិបូណ៌ដូចប្រទេសថៃ ភូមានិងលង្កាដូច្នោះឡើយសូម្បីតែប្រទេសឥណ្ឌាដែលក្នុងសម័យនេះ មានអ្នកកាន់ព្រះពុទ្ធសាសនាមានចំនួនតិច មាន. ពួកបព្វជិតត្រឹម ២០ ឬ ៣០ រូបប៉ុណ្ណោះ ក៏គេបានបង្កើតវិជ្ជាស្ថានខាងព្រះពុទ្ធសាសនា ១ នៅនាលន្ទា មានភិក្ខុមួយរូបឈ្មោះកស្សបៈជាអធិបតី អាចណែនាំជនទុរូបឲ្យចូលបួសបានខ្លះ វិជ្ជាស្ថាននោះ គេបម្រុងនឹងរៀបចំឲ្យ ទៅជាមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ក្នុងពេលយ៉ាងខ្លីខាងមុខសព្វថ្ងៃនេះ គេបានផ្សាយដំណឹងទៅក្នុងលោកថា បើមានអ្នកណាទៅសិក្សាក្នុងសាលានោះ គេនឹងជួយឧបត្ថម្ភដោយអាហារឧបករណ៍ផងទៀត ។ សាលានៅនាលន្ទានោះ ហើយដែលសិស្សសាលាយើងនេះចំនួន ៣ រូបចេញទៅសិក្សាពីថ្ងៃសុក្រមុននោះ ក្នុងសេចក្ដីឧបត្ថម្ភនៃសមាគមមិត្តសាលាបាលី ។

តាមដំណឹងពីភិក្ខុកស្សបៈជាអធិបតីនៃវិជ្ជាស្ថាននោះ ជាសាលាសិក្សាព្រះពុទ្ធសាសនានោះ រដ្ឋាភិបាលប្រទេសឥណ្ឌាដែលមានលោកបណ្ឌិតនេរូជាប្រមុខជួយឧបត្ថម្ភ ។ ឯរដ្ឋាភិបាលឥណ្ឌាមិនមែនជាក្រុមអ្នកកាន់ព្រះពុទ្ធសាសនាទេ តែជួយឧបត្ថម្ភក្នុងឋានៈជាអ្នកគ្រប់គ្រងកិច្ចការក្នុងប្រទេស ។

ចំណែកខាងប្រទេសយើងវិញ សម័យបច្ចុប្បន្ននេះព្រះករុណាជាអម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះនរោត្ដម សីហនុវរ្ម័ន ទ្រង់ជាអគ្គសាសនូបត្ថម្ភ ក៏ទ្រង់សព្វព្រះរាជហឫទ័យចង់ឲ្យ ការសិក្សាក្នុងព្រះពុទ្ធសាសនាមានដំណើរលឿនទៅមុខឲ្យសមតាមកាលៈទេសៈដើម្បីកុំឲ្យអន់ថយជាងប្រទេសនានា ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ទើបទ្រង់មានព្រះរាជបញ្ជាឲ្យក្រសួងធម្មការ (កាលឯកឧត្ដម សម-ញាណ ជារដ្ឋមន្ត្រី) ចាត់ការពិនិត្យព្រមទាំងរៀបចំការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យមានសេចក្ដីចំរើនឡើងដូចប្រទេសជិតខាង ។ ក្រសួងធម្មការក៏បានចាត់ការរៀបចំកែប្រែការសិក្សាក្នុងសាលាបាលី ជាន់ខ្ពស់ព្រមទាំងបង្កើតឲ្យមានការសិក្សាជាន់ខ្ពស់ឡើងទៀត គឺបង្កើតឲ្យមានមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា មាននាមថាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មហាវិទ្យាល័យនេះកើតឡើង ដោយព្រះរាជក្រមលេខ ៨៣៩ ន.ស. ចុះថ្ងៃទី ១ កក្កដា ១៩៥៤ ។

មហាវិទ្យាល័យនេះ សព្វថ្ងៃពុំទាន់បានបើកទ្វារបញ្ចូលសិស្សឲ្យរៀននៅឡើយទេ ដោយមានការរៀបចំពុំទាន់ហើយស្រេច ។ ព្រះករុណាជាអម្ចាស់ជីវិត កាលក្រោយដែលទ្រង់លាលះរាជ-សម្បត្តិហើយបាន ២-៣ ថ្ងៃទ្រង់នៅមានព្រះរាជហឫទ័យប្រារព្ធមកលើពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជនេះឲ្យមានដំណើរទៅមុខ ទើបទ្រង់ប្រោសព្រះរាជទានប្រាក់ ១លាន ៥ សែនរៀល ក្នុងការកសាងគ្រឹះស្ថានឲ្យបានគ្រប់គ្រាន់ ។

ឯគ្រឹះស្ថានដែលកំពុងសង់សព្វថ្ងៃ គឺឧបាសកបេ-យានអ្នកជំនួញ មានសទ្ធាជ្រះថ្លាបំណាយធនធានរបស់ខ្លួនកសាង ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា ជូនដល់ព្រះរាជរដ្ឋាភិបាលឲ្យចាត់ចែងជាកន្លែងសិក្សានៃពុទ្ធិកមហាវិទ្យាល័យតទៅ ។

មហាវិទ្យាល័យនេះហើយ ដែលបម្រុងនឹងទទួលអស់លោកជានិស្សិតទាំងឡាយ ដែលចេញពីសាលានេះឲ្យសិក្សាតទៅទៀត ។

ដូច្នេះ សុំឲ្យអស់លោកទាំងឡាយតាំងចិត្តតាំងព្យាយាមឲ្យមាំមួនក្នុងការបន្តកិច្ចសិក្សាទៅទៀត ។ សុំឲ្យអស់លោកតាំងចិត្តគាំពារខ្លួន កុំឲ្យខ្លួនអន់ថយដោយចំណេះវិជ្ជា គាំពារព្រះពុទ្ធសាសនាកុំឲ្យព្រះពុទ្ធសាសនាទន់ខ្សោយ ដោយខ្វះខាតអ្នកចេះដឹង, គាំពារប្រទេសជាតិ កុំឲ្យប្រទេសជាតិខ្វះខាតបណ្ឌិតដែលមានចំណេះវិជ្ជាច្រើន ។ សុំឲ្យអស់លោកទាំងឡាយតាំងចិត្តអធិដ្ឋាន ដំកល់ព្យាយាមឲ្យរឹងប៉ឹងក្នុងការសិក្សាវិជ្ជាផ្លូវសាសនានិងផ្លូវលោកតទៅទៀត ឲ្យគ្រាន់តែបានសម្រេច កុំគាលបោះបង់ចោលការសិក្សាទៅមុខ ត្រូវយកតម្រាប់តាមព្រះបរមគ្រូនៃយើងកាលដែលព្រះបរមពោធិសត្វមាននាមថាមហា-ជនកៈ ព្រះអង្គបានស្រែកប្រកាសក្នុងមហាសមុទ្រចំពោះទេវតាថា “ កើតមកជាកូនប្រុសត្រូវតែខំប្រឹងព្យាយាមគ្រាន់តែបានសម្រេចប្រយោជន៍” ។

អស់លោកជាសិស្សទាំងឡាយ!

ខ្ញុំសូមរំលឹកជាថ្មីទៀត, សូមលោកជានិស្សិតទាំងឡាយកុំបីមានគំនិតគិតថា ការជ្រោមជ្រែងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងឲ្យធំទូលាយឡើង ទុកឲ្យអស់លោកឯទៀតៗចុះ ប្រសិនបើគិតដូច្នេះតែទាំងអស់គ្នា តើបណ្ឌិតរូបណាទីទៃនៅទ្រទ្រង់ព្រះពុទ្ធសាសនាទៅមុខ ? ព្រោះព្រះពុទ្ធសាសនាក្នុងអនាគតមានសង្ឃឹមដោយច្រើន ចំពោះលើអស់លោកជានិស្សិតកេទបណ្ឌិត ជាអ្នករៀនសូត្របានចេះដឹងវិជ្ជាខាងព្រះពុទ្ធសាសនាទាំងនេះហើយ ព្រោះបណ្ឌិត, ទោះបីមានចំនួនច្រើនរាប់ពាន់រាប់ម៉ឺន ប៉ុន្តែបើឥតមានចំណេះវិជ្ជា ឥតមានសណ្ដាប់ធ្នាប់ល្អ ឥតមានការប្រព្រឹត្តត្រឹមត្រូវ ឥតមានការៈរក្សា ជាបណ្ឌិតពុំសូវមានតម្លៃ មិនគួរដល់ការទទួលយកនូវសេចក្ដីគោ

វេពាប់មានអំពីមហាជន បព្វជិតទាំងនោះឬដែលអាចជួយ ជ្រោមជ្រែងព្រះពុទ្ធសាសនាក្នុងអនាគត? ឃើញថាជួយជ្រោមជ្រែងពុំកើតទេ ។

ហេតុនេះសុំឲ្យអស់លោក ជានិស្សិតទាំងឡាយ ខំគិតពិចារណាឲ្យវែងឆ្ងាយ, ធ្វើចិត្តឲ្យធ្ងន់ឲ្យនឹងធឹង ហើយខំសិក្សាបំណេះវិជ្ជាឲ្យបានចេះដឹង ឲ្យបានសមល្មមជាទីពឹង ជាបង្អែកនៃពុទ្ធសាសនិកជនទូទៅ ។

ក្នុងអវសានកថានេះ, អាត្មាភាពសូមសំបូងសង្រ្គងគុណព្រះស្រីរតនត្រ័យ សូមឲ្យជួយអភិបាលរក្សាព្រះករុណាជាអម្ចាស់ជីវិត សូមព្រះអង្គបានប្រកបដោយជោគជ័យសុវត្ថិមង្គលគ្រប់ប្រការ សូមបានប្រកបដោយ ព្រះជន្មាយុយឺនយូរអស់កាលជាអង្វែង, ទាំងសម្តេច, ទ្រង់, ឯកឧត្តម, ព្រះតេជព្រះគុណ នូវអស់លោក-អ្នកទាំងឡាយជាពុទ្ធបរិស័ទទូទៅ ក៏សូមឲ្យបានប្រកបដោយសេចក្តីសុខ- ចំរើនអស់កាលជានិរន្តរ៍កុំបីអាក់ខានឡើយ ។

# ជូនពរឆ្នាំថ្មី

សេះ និង ពាពែ

សួស្តីបងពពែ !

សួស្តីបងសេះ !

ស—សុខសប្បាយទេបានលើសព្វថ្ងៃនេះ

ព—អើ ! បងអើយធម្មតាបានរបស់យើង មិនដែលមានទុក្ខទេ ដូចបងជ្រាបស្រាប់ហើយ ប៉ែក ក្តែកឡើងយើងត្រូវទទួលរបស់ទិញទាំងអស់ ក្នុង១២ឆ្នាំ ដែលត្រូវវេនខ្ញុំមកជួយរក្សាមនុស្សលោកម្តងៗ ដូចពុញត្រានដែរ តែធ្វើម្តេចបើខំនាយនេះជាប្រពៃណីទៅហើយ ខ្ញុំនឹងត្រាណើយកន្ទុយទៅដូចជាមិនសមគួរ, ចុះបងឯងម៉េចទៅ ការរួមសុខទុក្ខជាមួយនឹងមនុស្សលោករវាង១២ខែនេះ ។

ស—៎បងអើយខ្ញុំ ដូចជាពិបាកនិយាយអស់យ៉ាងហើយ មនុស្សលោកសម័យនេះពិបាកប្រដៅណាស់ ក្នុង១២ខែខ្ញុំឥតមានដែលស្រាកពេលណាសោះ ដើម្បីនឹងជួយដោះស្រាយបញ្ហាមនុស្សលោក ខ្ញុំអស់កម្លាំងណាស់បងអើយ ស្ទើរតែហានិយាយពុំរួច បងមើលចុះក្រចកជើងខ្ញុំរបោលអស់ហើយ មាត់ខ្ញុំបែកពពុះស្កុល, ទាំស្រែកប្រាប់ហេតុផលគេៗធ្វើមិនឮ ទាល់តែនាំមុខគេ ១ មិនបង់ដើរតាម នេះបំផាលប្លាកមែន ឥឡូវនេះនៅសល់បញ្ហាច្រើនណាស់ ដែលខ្ញុំទុកឲ្យបងឯងជួយដោះស្រាយមនុស្សលោក បងឯងមានពួបងពស់និយាយប្រាប់ទេថា បញ្ហាពិភពលោកនេះ លុះត្រាតែមនុស្សលោកវិលមកទីពឹងលើព្រះពុទ្ធវចនៈ តែព្រះពុទ្ធវចនៈនេះសព្វថ្ងៃទ្រុឌទ្រោមណាស់ ពិភពលោកមិនសូវប្រតិបត្តិតាមទេ ច្រើនប្រព្រឹត្ត តាមលំអានលោកិយនិយមអបរិបត្តគេតាមអ្នកវិទ្យាសាស្ត្រ ៗ

ព—៎ឱ! ប៉ោយ៉ាងហ្នឹងបងឯងសព្វថ្ងៃនេះឃូលតែជាមួយពួកអ្នកកាន់សាសនាព្រះពុទ្ធវចនៈប៉ុណ្ណោះទេឬ?

ស—៎ទេ ខ្ញុំមិនមានលម្អៀងទៅខាងណាទេ តែខ្ញុំពោលតាមសច្ចៈទេតើ ព្រោះអ្នកពុទ្ធជននិយាយច្រើនត្រូវ ចំណែកលោកជន និយាយច្រើនតែបន្ទុ បងឯងពិនិត្យមើល! ដូចជា ប្រទេសកម្ពុជានេះ ជាកន្លែងចាត់ការរបស់យើង ហើយខ្ញុំយកចិត្តទុកដាក់ជាងគេបំផុត ព្រោះជាប្រទេសពៅអ្នកឃើញទេ សម្ដេចព្រះឧបយុវរាជ ដែលជាអតីតព្រះចៅនៃប្រទេសនេះ ព្រះអង្គខំសណ្ដោងយកយោង ឲ្យប្រទេសរបស់ទ្រង់ មានមុខស្មើនឹងប្រទេសសេរីទាំងឡាយ ទ្រង់ណែនាំពលរដ្ឋរបស់ទ្រង់ ឲ្យចេះរក្សាធម៌សាមគ្គីរវាងជាតិនឹងជាតិ ព្រះអង្គជាអគ្គពុទ្ធជនមួយក្នុងផ្ទៃនៃពុទ្ធសាសនា, ទ្រង់ជាទីស្រឡាញ់រាប់អាននៃពលរដ្ឋភាគច្រើន សូម្បីអ្នកនយោបាយពិភពលោក គឺគង់គោរពស្ងើងព្រះអង្គដែរ; ព្រះអង្គដែលមានលក្ខណៈជាមហាវីរបុរសដូចនេះ ម្ដេចក៏មានមនុស្សឈ្នានីសព្រះអង្គ, គួរឲ្យខ្ញុំសោកសៅណាស់បងពៅតែ! បងឯងមកនៅគង់តែឃើញទេ, ដែលគេក្បត់ព្រះអង្គ ដែលគេឈ្នានីសព្រះអង្គ ទ្រង់មិនដែលយកទោសអ្នកអស់នោះសោះ ទ្រង់មិនដែលបង្កៀរតបវិញ ដោយម្ដងណាឡើយ នេះបានពេញជាមហាក្សត្រគេបានដោយក្រមមែន; អ្នកបានឮទេ ពេលដែលទ្រង់ដាក់រាជ្យ ផែនដីក្នុងប្រទេសញ័រ! សំដែងសេចក្ដីអស្ចារ្យថ្វាយទ្រង់ៗ ខ្ញុំភ័យណាស់សព្វថ្ងៃ ខ្លាចក្រែងប្រជារាស្ត្ររបស់ព្រះអង្គបែកបាក់គ្នា តែចាំមើលណា! យើងទាយទុកថា បើសិនជាប្រជាជនក្នុងរដ្ឋចេះបែកបាក់គ្នា នោះនឹងក្លាយខ្លួនទៅជាប្រទេសមួយល្បីល្បាញក្នុងពិភពលោក តែលុះត្រាមន្ត្រីគ្រប់ដំណែង ចេះលះបង់ប្រយោជន៍ផ្ទាល់ខ្លួនសិន ។ ខ្ញុំដូចជាចូលដែរ អ្នកគិតប្រយោជន៍ផ្ទាល់ខ្លួនទាំងនោះ ជាពីដើមចុះផលប្រទេសធ្លាក់ទៅលើកណ្ដាប់ដៃគេ គួរតែគិតឲ្យបានច្រើនខ្លួនឯងខ្លះ ចុះពេលនេះផលទាំងនោះ ធ្លាក់មកលើកណ្ដាប់ដៃជាតិ

របស់ខ្លួនហើយ ម្ដេចក៏នៅតែឈ្លក់ដល់ណាទៀត! មួយបែបទៀត ពីរឿងសប្បាយនឹងស៊ីវិល័យ, ហើយស៊ីវិល័យនោះក៏រឹតតែប្លែកទៅទៀត អឺរ៉ុបក៏មិនមែន អាស៊ីក៏មិនមែន មិនដឹងជាដូចម្ដេចទេគួរឲ្យអស់សំណើចដែរខ្ញុំ ! គេចាយប្រាក់តាមគោលបំណងគេ ដូចជាយើងបោះដុំដីលេង ; គេសប្បាយក្បែរសេចក្ដីវិនាស សប្បាយនេះគ្រាន់តែធ្វើជាតិនិងសាសនាខ្លួនឲ្យថោកទាបប៉ុណ្ណោះទេ មិនគួរបើសប្បាយក្បែរដំកៀររបស់ជាតិសោះ ៗ ក្រោយបងពៅតែខ្ញុំនិយាយរឿងនេះយូរទៅនាំតែវង្វេងហើយគេស្អប់ផង យើងប្រគល់ភារៈនេះទុកឲ្យបងឯងជួយដោះពេលក្រោយចុះ ៗ

ព–. ហ្នឹងបងសោះឯងប្រណែនទឹងគេហើយបានជាជាប្លុះ! ព្រោះបងឯងមិនប៉ះកន្ទ្រង់ដូចគេ បងឯងមិនបានសប្បាយ ! បើសិនជាបងឯងសម្បូណ៌ចាយដូចគេវិញ ប្រហែលជាបាត់មាត់ប៉ុនគេចុក ហើយសប្បាយហួសគេទៅទៀតមើលទៅ !

ស–. បងឯងថាដូចនោះក៏បេះតែបាន ព្រោះបងក៏មិនមែននៅក្នុងចិត្តខ្ញុំដែរ បងឯងកុំគាលស្មានថា ខ្ញុំចាល់ច្រកហើយបេះតែនិយាយនោះ ខ្ញុំចង់សប្បាយលើសហ្នឹងក៏បានមិនខ្វះ តែយើងត្រូវឲ្យយល់ដល់អ្នកមានវណ្ណៈខ្សត់ទ្រព្យផង ឲ្យបេះលែកសេចក្ដីទុក្ខពីជនអ្នកក្រលំបាកផង ទើបគេហៅថាមនុស្សយល់កាលវែងនឹងខ្លី; ព្រោះយើងជាជាតិសត្វតែងខ្វះធមសញ្ញាផង មិនគួរបើប្រដៅមនុស្សលោកទេ តែគេស្ដីឲ្យយើងវិញ មុខជាគេផ្ទុះមិនរួចហើយ គេក៏មិនមែនញញើតយើងប៉ុនសរសៃសក់ដែរ ប្រហែលច្បាប់សម្រាប់ប្រទេសម៉េចគេមិនខ្លាច បើថាឲ្យខ្ញុំទៅ សូម្បីសាកបរ ដែលតម្រូវឲ្យប្រើអក្សរសាស្ត្រជាតិជាផ្លូវការ ក៏គង់ជនជំពូកខ្លះគេធ្វើមិនឮ មានកន្លែងខ្លះរឹតតែចូលចិត្តសរសេរអក្សរបរទេសខ្លាំងណាស់ទៅទៀត ប្រហែលជាគេយល់ថាខ្មែរត្រូវស៊ីវិ-ល័យតាមអ្នកបរទេសតាំងពីអក្សរសាស្ត្រជាដើមឡើងទៅ ! បើតាមដំណើរពិតគឺច្បាប់ដែលចេញជាផ្លូវការហើយ ក៏គួរតែអនុវត្តន៍ឲ្យមែនទែន ទើបបានផលប្រ-យោជន៍ដូចម្ដេចខ្លះ? បងពៅតែខ្ញុំក៏ល្មមដល់វេនផ្លាស់គ្នាហើយ នៅបែកព្រាត់ជាមួយបងឯង នាំតែចេញពពុះមាត់ឥតអំពើទេ ! ខ្ញុំសូមលាទៅសម្រាកកម្លាំងសិនហើយ ១២ឆ្នាំទៀត សឹមយើងជួបគ្នា តែខ្ញុំសូមផ្ដាំផ្ដាច់ថា កុំភ្លេចឲ្យសោះញាំងជនក្នុងប្រទេសនេះឲ្យបេះរួមគ្នាតាមលទ្ធិរបស់ប្រទេស វេលាបងទៅរកសួរខ្ញុំកន្លែងណា ក៏ត្រូវប្រាប់អ្នកពុទ្ធជនឲ្យខំប្រឹងតទៅទៀត កុំបង្អង់ឲ្យសោះ ហើយឲ្យបេះអានទស្ស-នាវដ្ដីមិត្តសាលាបាលីនេះកាន់តែច្រើនឡើង ព្រោះជាទស្សនាវដ្ដីតែមួយ ដែលប្រឹងបណ្ដុះសាមគ្គីធម៌និងសុខភាពសម្រាប់ប្រទេសនិងពិភពលោក ៗ

ព–. សាធុ! បងសោះ ខ្ញុំដំបូងឡើងនឹកថានឹងមកគ្រាន់តែបង្គ្រប់ពេលវេលាប៉ុណ្ណោះ តែដល់ឮសំដីរបស់បងឯង នាំឲ្យខ្ញុំរឹតតែគក់ស្មុតឡើង ខ្ញុំសូមសច្ចាចំពោះមុខបងឯងថា កុំឲ្យព្រួយ ១២ខែទៅមុខទៀតនេះ ខ្ញុំគ្មានសំចៃកំឡាំងទេ ខ្ញុំនឹងខំធ្វើអ្នកប្រ

ទេសនេះឲ្យមានជីវភាពរស់នៅតាមលំអានអ្នកពុទ្ធជន ឲ្យបេះមានសាមគ្គី; ស្រឡាញ់ប្រមុខរដ្ឋដែលល្អ ស្នេហាប្រទេសជាតិ,វប្បធម៌, ចរិយាសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រជាតិ ។

ដរាបចង់សេះ អញ្ជើញឲ្យបានសុខសប្បាយ ដរាបចង់តែនៅក្រុមមនុស្សលោកកុំឲ្យឈ្លោះគ្នា មមីផ្ទឹមមែនទឹងដល់ក្រោយ ពុទ្ធជនអើយគួរខិទ្ធឃ្លាត បណ្ដោះយោបល់ជួយយិតយោធជាតិ កុំឲ្យរក់តបាកពុទ្ធសាសនា ។ ឲ្យបេះគោរពទៅតាមលំ-អាន ព្រះពុទ្ធទូន្មានដល់សត្វលោកថា ឲ្យបេះតបគុណមហាក្សត្រា យិតយោធរដ្ឋា តាមផ្លូវសាមគ្គី ។

## តេជះឆ្នាំមមី

ឆ្នាំមមីជាឆ្នាំមានបុទ្ធិពិតជាក់ ប្រសិទ្ធិតេជះ នឹងអំណាចចេស្ដា បារមីព្រះពុទ្ធផុតលើលោកា ទៅ បុត្រសោភាវន្តាខុបខាច ។ សូមថ្វាយពរជ័យសិរី-សួស្ដីសម ប្រសើរឧត្តមបរមបុទ្ធិអំណាច មហាក្សត្រិយ៍តំរពង្សប្រុងរឿងចំណាច ទ្រង់គង់គង់ភព្យ ប្រាសចាកឧបទ្រវន្ត ។ សម្ដេចព្រះរាជបុត្របរិសុទ្ធគុណ រដ្ឋ ទ្រង់នាមប្រាកដសីហនុវរ្ម័ន ទ្រង់ជាអតិជាតិ វិសេសលើជន មានព្រះគុណធ្ងន់លើដែនកម្ពុជា ។ សូមរាជករណីថ្លៃថ្លាប្រសើរ ទ្រង់គេជះលើឧបទ្រវន្ត កំរិក សម្រេចបំណងដែលទ្រង់បង់គ្រប់គ្រា គ្រប់ ក្រស្ដប្រជាពីដផ្អែកបារមី ។

## សួស្ដីឆ្នាំមមី

ឆ្នាំមមីទីជាសួស្ដី មង្គលសិរីល្បីអស្ចារ្យ សូមជូនដល់រាជរដ្ឋា-ភិបាលថ្លៃថ្លាល្អពេកក្រៃ ។ សុំឲ្យស្ថានការប្រទេសជាតិ មានល្បឿនជាអាទិគុណឆ្នាំថ្មី ក្រស្ដរក្សាសាមគ្គីប្រពៃ កុំមានមោះមៃជិតដាយប្រាណ ។ សូមពុទ្ធជននៅក្នុងរដ្ឋ ពួកគ្នាប្រាកដ តាមលំអាន ព្រះពុទ្ធដីកាដែលជាយាន នោះនឹងធ្ងន់បានដល់សុខា ។

---

# ព្រះបរមសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធ ដែលនាំយកមក ពីកោះសីឡង់ បានបូជាចំពោះវត្តខ្មែរ នៅប្រទេសវៀតណាមខាងត្បូង ។

កាលពីថ្ងៃសៅរ៍ទី ២៣ មេសា ១៩៥៥ពេលរសៀល, មានពិធីបុណ្យមួយទទួលព្រះបរមសារីរិក-ធាតុព្រះសម្មាសម្ពុទ្ធនៅទីក្រុងព្រៃនគរ វត្តខ្មែរមួយ នៅវិថីអែរីយ៉ូ-ដេ-វ៉ែរ ។ ព្រះបរមសារីរិកធាតុ

នេះគឺព្រះមហាថេរនាវេទ: បាននាំពីកោះស៊ីឡុង (លង្កា) ។

ក្បួនដង្ហែព្រះបរមសារីរិកធាតុ បានអញ្ជើញទៅចំណតអាកាសយានតាន់-សុង-ញ៉ូត ដើម្បីទទួលព្រះមហាថេរនាវេទ: ព្រមទាំងព្រះបរមសារីរិកធាតុ ។ គេបានឃើញក្នុងចំណោមក្បួនដង្ហែមានគណៈប្រតិភូព្រះសង្ឃខ្មែរមកពីខេត្រត្រាវិញ , សុកត្រាំងនិងបាក់លីវ ។ ក្បួនដង្ហែបានទៅដល់វត្តនោះពេលម៉ោង១៥ ។ នៅទីវត្តមានលោកសឺន-វ៉ៃ-ធៀង, អ្នកតំណាងខ្មែរនៅវៀតណាមខាងត្បូង លោកប-ផតម៉ាល , លោកមេ-អា បាន បានរង់ចាំទទួលព្រះបរមសារីរិកធាតុ ។

ក្រោយដែលព្រះសង្ឃចំរើនព្រះបរិត្ត , ព្រះមហាថេរនាវេទ:ក៏បានប្រាស្រ័យនឹងឧបាសកឧបាសិកា ដោយថេរវាចាថា:

អាត្មាបានសន្យាថានឹងមកទស្សនាប្រទេសវៀតណាមក្នុងកាលអនាគត ។ អាត្មាមានចិត្តសោមនស្សពន់ពេកដោយបំណងអាត្មាបានសម្រេចក្នុងថ្ងៃនេះ ។ គឺអាត្មាដែលបានធ្វើដំណើរមកដោយសេចក្ដីអនុគ្រោះរបស់លោកបដិតម៉ាល, បានជាអាត្មាអាចនាំយកព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធមកបាន ។ នៅគ្រប់ប្រទេស គឺប្រទេសស្វីស, ដាណឺម៉ាក, អល្លឺ-ម៉ាញ ព្រះពុទ្ធសាសនាបានផ្សាយពលការ:ហើយ បានរចនាផនជាតិនៅទីនោះឲ្យទៅជាអ្នកសប្បុរស , អ្នកជឿព្រះពុទ្ធសាសនាជាច្រើន ។

ពិធីបុណ្យនេះបានបង្ហើយនៅម៉ោង ១៧,៣០ នាទី ។

---

## “ប្រដៅភរិយា”

កាលពីដើមមានបុរសម្នាក់កតញ្ញូនឹងម្ដាយខ្លួនណាស់ ។ បុរសនេះជាមនុស្សអកំព្រា ដោយមកពីឪពុកអនិច្ចកម្មបោលតាំងពីក្មេង នៅតែជាមួយនឹងម្ដាយជាស្រីសូត្របួសបរិបូណ៌ដោយចិត្តបុណ្យ ហើយដែលជាទីស្រឡាញ់នឹងជាទីគោរពបំផុតនៃខ្លួន ។ ទោះបីបុរសនេះចម្រើនវ័យពេញកម្លោះហើយ ប្រកែកមិនព្រមយកភរិយា យ៉ាងណាក៏ដោយ ម្ដាយក៏ចេះតែទូន្មានឲ្យរកគូស្រករទៅ ដើម្បីខ្លួនគាត់បានចៅហៅផង ។ ដោយហេតុមានកតញ្ញូធម៌នឹងម្ដាយ បានជារាល់ដង កាលណាបុរសនេះត្រូវមាតាបង្ខំឲ្យយកប្រពន្ធនោះ ខ្លួនពិបាកចិត្តខ្លាំងណាស់ ប៉ុន្តែមិនហ៊ានប្រកែកនឹងពាក្យម្ដាយ គ្រាន់តែសន្យា ពីថ្ងៃមួយទៅថ្ងៃមួយទៀត ឲ្យតែរួចផុតទៅ ដោយបានការហេតុដំរាបម្ដាយថា ចាំឲ្យខ្លួនជ្រើសរើសស្រីសូត្រត្រង់ ដែល

សមធ្វើជាកូនប្រសាល្អនឹងកិរិយាស្លូតត្រង់ស៊ិន ។

បុរសនេះ ពុំមានព្រួយបារម្ភមកពីរឿងយកប្រពន្ធទេ គឺខ្លួនមានចិត្តខ្លាចក្រែងម្តាយនឹងកូនប្រសាស្រីទាស់ទែងគ្នាប៉ុណ្ណោះ ។ ព្រោះហេតុថាវង់ម្តាយក្មេកនឹងកូនប្រសា ច្រើនតែមានកើតសេចក្តីយល់មិនស្របគ្នា ទាស់ឈ្លោះគ្នា ដោយរឿងបន្តិចបន្តួច ដែលជាការណ៍បណ្តាលឲ្យបាត់ចិត្តភាពល្អ ក្នុងគ្រួសារអស់ៗ ព្រោះបុរសនេះធ្លាប់បានប្រទះឃើញរឿងដូចនេះជាញឹកញយណាស់ ។ កាលណាបុរសនេះស្រមៃឃើញថា បើមានប្រពន្ធហើយប្រពន្ធរបស់ខ្លួននៅថ្ងៃក្រោយ នឹងព្រហើនឆ្លើយ មាត់មួយមាត់ពីរ កំបុតកំបុញតបនឹងម្តាយខ្លួននោះ ខ្លួននឹងឈឺចាប់ក្នុងសន្តានចិត្តខ្លាំងក្រៃលែង ។ ហើយបុរសនេះក៏មានចិត្តព្រួយបារម្ភពីមាតារបស់ខ្លួនផងទៀត ដែលច្រើនតែរអែររអូវរអ៊ូរទាំ, ធ្វើម្តេចនឹងជៀសឲ្យផុតពីពាក្យសំដីធ្ងន់ស្រាល ចំពោះកូនប្រសាស្រីដែលគាត់តែងមានអំណាចត្រួតត្រាលើ ហើយដែលជាស្រីថិតក្នុងឋានៈដ៏សំខាន់ក្នុងជីវិតរបស់កូនប្រុសសម្លាញ់គាត់

បុរសនេះចេះតែរករឿងហេតុយកមកសន្យានឹងម្តាយពីថ្ងៃមួយទៅថ្ងៃមួយ រហូតដល់មានមួយថ្ងៃ បុរសនេះប្រកែកទៀតពុំបាន ព្រោះហេតុម្តាយចេះតែយំស្រែកបង្ខំឲ្យមានប្រពន្ធទើបបាន, ទឹកភ្នែកនៃមាតាដ៏ស្លូតនេះ មានកម្លាំងអាចញ៉ាំងឲ្យចិត្តបុរសទៅជាទន់វិញបាន ។ ហេតុនេះហើយបានជាបុរសនេះត្រូវស្តាប់តាមពាក្យម្តាយព្រមទៅដណ្តឹងប្រពន្ធ ។

កាលដំបូង ម្តាយក្មេកនឹងកូនប្រសាស្រីនៅជាមួយគ្នាសុខសាន្តណាស់ ។ ប៉ុន្តែដល់ក្រោយមក សុខដុមក្នុងគ្រួសារកាន់តែបាត់បន្តិចម្តងៗ រាល់ថ្ងៃតាមពេលតាមវេលា ។

កូនប្រសាស្រីបានសំដែងកិរិយាបចកាន់តែព្រហើនមើលងាយម្តាយក្មេក ។ ឯម្តាយក្មេកក៏មានពាក្យធ្ងន់ស្រាលទៅរកកូនប្រសាវិញ ។ ម៉្លោះហើយ ក៏គ្រួសាររបស់បុរសក៏ស្ទើតែឥតបាត់អស់នូវសេចក្តីស្រុះស្រួលសុខដុមនឹងគ្នាដូចកាលដំបូង ។

តែកាលណាម្តាយនឹងប្រពន្ធរៀបនឹងប្រកាសសង្គ្រាមតគ្នានោះ បុរសក៏រកផ្លូវដើរលេងឲ្យផុតបាត់ទៅ កុំឲ្យឃើញភាពការៈឈឺចាប់នេះបាន ។ ព្រោះបុរសបានគិតឃើញថាករណីនេះខ្លួនពុំដឹងតែការគាត់ដូចម្តេច? មិនគួរសមនឹងកាន់ជើងម្តាយហើយវាយប្រពន្ធ ឬមួយចូលដៃនឹងប្រពន្ធហើយមកដេកប្រកែកនឹងម្តាយឯងទៀតឡើយ ។ ដូច្នេះបុរសនេះកាន់តែពិបាកចិត្តខ្លាំងឡើងៗ ។ ពេលណាដែលខ្លួនបានទៅជិតម្តាយ ៗ ដុកដាន់ថា " មិនចេះប្រដៅប្រពន្ធ " ហើយពេលណាដែលខ្លួនបានទៅជិតប្រពន្ធ ៗ ក៏សំឡុតនាយសំឡុកកាយ បន្ទោសថា " ចូលដៃតែនឹងម្តាយ ទុកឲ្យម្តាយចេចង់ដេរបរភ្ជាប់ប្រពន្ធយ៉ាងណាក៏បាន "

យ៉ាងនេះ ហើយបានជាបុរសនេះពិបាកចិត្តរកថ្លែងអ្វីចេញពុំបាន ។ ម្យ៉ាងទៀត ខ្លួនជាមនុស្សស្លូតសុភាពមួយជាតិពុំដែលរករឿងរកហេតុនឹងនរណាសោះ ។ ចំពោះរឿងនេះពិបាកនឹងឲ្យបុរសអារកាត់បាន បុរសក៏មានសេចក្ដីស្ដាយក្រោយដោយមកពីស្ដាប់ម្ដាយព្រមយកប្រពន្ធ ទើបឥឡូវខ្លួនពិបាកចិត្តដូច្នេះ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ បុរសគង់បានធ្វើឲ្យមាតាសម្លាញ់របស់ខ្លួនបានសប្បាយចិត្ត ត្រង់ខ្លួនទទួលយកប្រពន្ធនេះដែរ ។

បុរសនេះកើតទុក្ខព្រួយចិត្តលែងគិតដល់មុខរបររកស៊ីអ្វីទៀត ។ មួយថ្ងៃដល់ល្ងាចដើរចោលតែផ្ទះជួនកាលដើរបាត់ ៤-៥ថ្ងៃទើបមកវិញ ។ គាប់ជួនថ្ងៃមួយបុរសនេះដើរកាត់ផ្សារ បានប្រទះនឹងឈ្មួញលក់កាំបិត មានមុខសស្លាបដាក់ដម្រៀបគ្នាហៃជាជួរ ៗ បុរសនេះមិនដឹងជាមានគំនិតបែបណា ស្រាប់តែទិញកាំបិតមួយយួរតម្រង់ទៅផ្ទះ ។

គេកាន់កាំបិតចូលផ្ទះដោយមានទឹកមុខកាចសាហាវដូចជាចង់សម្លាប់នរណា ដោះអាវចេញថ្ពក់នឹងជញ្ជាំង មកអង្គុយចំកណ្ដាលថ្នាលនៅមុខផ្ទះ ហើយយកកាំបិត ដែលទើបទិញមកសំលៀងឮសូរខ្រូកៗ ។

នៅពេលនោះ ប្រពន្ធទៅផ្សារ ម្ដាយបុរសឃើញកូនគិតតែសំលៀងកាំបិត មុខខឹងឡើងសេរសែកធំៗ ក៏ចូលក្នុងចិត្តទើបដើរចេញមកសួរថា:

— កូនសំលៀងកាំបិតធ្វើអី ?

— កូនគិតតែសំលៀងមិនឆ្លើយ , ចាំឲ្យម្ដាយសួរម្ដងទៀត ទើបជំរាបវិញថា:

—កូនសំលៀងកាំបិតទុកសម្លាប់ប្រពន្ធកូនចោលឲ្យស្រឡះទៅ, ទុកឲ្យវានៅ វាព្រហើនគោងកាចនឹងម៉ែ កូនទ្រាំមិនបានទេ ។

ម្ដាយរំជួលចិត្តហួសប្រមាណ ក៏ឱបកូនយំហើយនិយាយថា:

ណ្ហើយកូន, កុំសម្លាប់វាធ្វើអី, បើកូនសម្លាប់វា កូនត្រូវទោសឧក្រិដ្ឋហើយ បើអ៊ីចឹងម៉ែរស់នៅយ៉ាងម្ដេចបាន ? បុរសនេះនៅតែធ្វើមុខព្រងើយហើយឆ្លើយថា:

— ម៉ែទុកឲ្យកូនសម្លាប់វាស្រឡះទៅ ។ បើមានការអ្វីកូនសុខចិត្តជាប់គុក ។ កូនសុំបាត់ប្រពន្ធឲ្យតែបានម៉ែនៅវិញ ។

កាលដែលម្ដាយបុរស ឃើញកូននៅតែបុកម៉ឹងម៉ាត់ដូច្នេះ, គាត់ក៏ភ័យព្រួយខ្លាំងណាស់ ។ យាយចាស់នេះពាក់អាវបង់ក្រមា កាន់ឈើច្រត់ដើរទៅរកហៅអ្នកស្រុកអ្នកភូមិ ឲ្យមកជួយឃាត់កូនប្រុសគាត់កុំឲ្យសម្លាប់ប្រពន្ធ ។

ដើរបណ្ដើរយាយទឹកឡើង មានសេចក្ដីស្ដាយក្រោយបណ្ដើរថា: អំណើះពីនេះទៅអញនឹងលែងដេរបញ្ចោរកូនប្រុសស្រីអញទៀតហើយ ។

បុរសនេះលុះម្តាយទៅបានមួយស្របក់ ទើបយកកាំបិតមកសំលៀងទៀត ៗ គាប់ជួនពេលនោះប្រពន្ធក៏មកដល់ពីផ្សារ ៗ នាងនេះដែលឃើញប្តីខំសំលៀងកាំបិតញើសហូរចេញសស្រាក់ក៏ដឹងថាមុខជាមានកើតរឿងហេតុអ្វីប្លែកពីធម្មតា ៗ នាងដើរសន្សឹម ៗ ទៅជិតប្តី ហើយឱនសួរប្តីដោយពាក្យទន់ភ្លន់ថាៈ

— បងសំលៀងកាំបិតធ្វើអី ?

ប្រពន្ធសួរមួយដងដម្បូង បុរសមិនឆ្លើយ, ពីរដងក៏បុរសមិនឆ្លើយ ៗ ដល់បីដងកាលបានឃើញប្រពន្ធភ័យទឹកមុខស្លេកស្លាំង ស្លុះហើយស្រាប់តែអង្គុយទ្រហោយំ ទើបបុរសឆ្លើយថា “ មានរឿងអីក៏បានជាអូនយំ ? បងមកពីស្រឡាញ់អូនពេក បានជាមានគំនិតគិតសំលៀងកាំបិតនេះ ទុកសម្លាប់ម៉ែឲ្យបាត់ស្រឡះទៅឲ្យអូនបានស្រួលខ្លួនបន្តិច បើនៅតែទុកម៉ែៗ ចេះតែជេរប្រទេចអូនរាល់ថ្ងៃពេក បងពិបាកចិត្តណាស់ ” ៗ

ប្រពន្ធភ័យខ្លាំងពេក ទាញដៃប្តីដាក់លើទ្រូងខ្លួនហើយឃាត់ថាៈ

ណ្ហើយបងកុំសម្លាប់ម៉ែ, ប្អូនសូមឃាត់ ៗ ទោសកំហុសទាំងអម្បាលមាណ គឺមកតែពីប្អូនទាំងអស់ទេ ៗ ណ្ហើយសូមបងសម្លាប់ប្អូនវិញប្រសើរជាង ៗ

បុរសដែលដឹងថាប្រពន្ធធ្លាក់ក្នុងឧបាយកលខ្លួនហើយ ប៉ុន្តែនៅតែធ្វើពុតខឹងខ្លាំងក៏ស្រែកគំហកឡើងថាៈ

—អូនលែងបងចេញ ទុកឲ្យបងទៅសម្លាប់ម៉ែបង ! ឃាយនោះគាត់ចាស់ហើយ ៗ បងសម្លាប់គាត់ទៅ ទុកឲ្យអូនរស់នៅជាមួយតែនឹងបងបានហើយ ៗ លែង ! លែងដៃបងចេញទុកឲ្យបងទៅសម្លាប់ម៉ែបង ៗ

ប្រពន្ធគិតតែឱបប្តី យំបណ្តើរអង្វរឃាត់ប្តីបណ្តើរ ៗ នាងបានសន្យានឹងប្តីថា អំណើះពីនេះតទៅនាងនឹងតាំងចិត្តស្លូតត្រង់វិញ ដើម្បីឲ្យម្តាយបានសប្បាយចិត្ត ហើយបើទុកជាម្តាយជេរប្រទេចគ្រក់យ៉ាងណាក៏ដោយ នាងក៏ពុំហានប្រកែកវិញទៀតឡើយ ៗ

អាការៈខាងក្រៅរបស់បុរសនេះ បានតាំងពុតស្ងៀមស្ងាត់ស្ងប់ចេះ តែក្នុងចិត្តសប្បាយក្រៃលែង ៗ

រួចបុរសនេះចូលទៅយកអាវពាក់ កាន់កាំបិតដើរចេញ ហើយនិយាយថា “ ទៅរកសម្លាប់ម្តាយ ៗ ប្រពន្ធភ័យហួសវិស្ស័យទៅ ជាសន្លប់ឥតដឹងខ្លួនប្រាណ ដល់បានដឹងខ្លួនវិញ នាងឃើញម្តាយក្មេកកំពុងតែថែទាំខ្លួន ដោយយកកូនកន្សែងរុំដៃ ឆ្អើរក្លិន ហើយយកមកស្អំក្បាល, ទ្រូង, ដៃ ជើងឲ្យនាង ៗ នាងបានចោលភ្នែកទៅរកមើលប្តី, ក៏ពុំឃើញស្រមោលឯណាសោះ ៗ នាងពុំហានសួរម្តាយក្មេក ៦

ម្ដាយក្មេកគិតពុំហានសួរកូនប្រសា ពីរឿងដែលទើបកើតឡើងនេះដែរៗ ប៉ុន្តែយាយបានស្មានថា ការណ៍នេះបានកើតឡើងដូចសំដីរបស់កូនប្រុសគាត់ កាលពីព្រឹកមិញ ។

ចំណែកខាងម្ដាយក្មេក ខ្លាចកូនប្រុសខ្លួនសម្លាប់កូនប្រសា ។ ឯកូនប្រសាខ្លាចប្ដីខ្លួនសម្លាប់ម្ដាយក្មេក ។ ស្ត្រីទាំងពីរមានចិត្តភ័យព្រួយដូចគ្នា តែមិនហាននិយាយចេញ ។ សេចក្ដីស្ដាយក្រោយចាប់ផ្ដើមលូតលាស់ក្នុងសន្ដានចិត្តនៃម្ដាយក្មេកនិងកូនប្រសាស្រីស្របពេលគ្នា ។ ដោយហេតុនេះហើយបានជាការអាស្រ័យនូវគ្នានិងគ្នា រវាងស្ត្រីទាំងពីរនាក់នេះត្រឡប់ទៅជាស្រុះស្រួលគ្នាវិញ ។

ឯប្រុស កាលថ្ងៃគិតតែយូរគាប់ចិត្តទៅ រួចយូរមកវិញ ។ ដូច្នេះមិនយូរប៉ុន្មាន នៅពេលដែលប្រុសមកផ្ទះ ប្រុសក៏បានឃើញទិដ្ឋភាពក្នុងគ្រួសារ មានសេចក្ដីស្រុះស្រួលដូចបំណងដែលខ្លួនបានប្រាថ្នា ។

ចាប់តាំងពីពេលនោះមក គ្រួសាររបស់ប្រុសនេះល្បីជាគ្រួសារដ៏ស្រុះស្រួល មានសុខដុមជាងគេក្នុងភូមិខ្លួន ។ នរណាក៏សរសើរថា គ្រួសារនៃប្រុសនេះជាគ្រួសារម្ដាយក្មេកស្លូត កូនប្រសាចិត្តល្អ កម្រនឹងមានក្នុងស្ថានមនុស្សលោកណាស់ ហើយដែលជាគំរូដ៏ប្រពៃឲ្យអ្នកផងដើរតាម ។

ក្នុងអវសាននៃរឿងនេះ ខ្ញុំសង្ឃឹមថា យុវបុរសទាំងឡាយ គប្បីពិចារណាហើយប្រតិបត្តិតាមរឿងនិទាននេះ ដើម្បីរកមធ្យោបាយទាញចិត្តអនាគតភរិយារបស់អ្នក ឲ្យចេះអត់ធ្មត់ មានគារវកិច្ចដល់មាតា ជាទីស្នេហានិងជាទីគោរពរបស់អ្នកៗ ប៉ុន្តែមុននឹងចង់ឲ្យភរិយាគោរពមាតាអ្នក ខ្លួនអ្នកត្រូវតែគោរពមាតាអ្នកមុន ព្រមទាំងត្រូវស្រឡាញ់គោរពដល់មាតាបិតាក្មេករបស់អ្នកឲ្យស្មោះអស់ពីចិត្តសិន ទើបអ្នកអាចទាញចិត្តភរិយាអ្នកឲ្យគោរពមាតាបិតាបង្កើតរបស់អ្នកបាន ។ ម្យ៉ាងទៀត បើចង់ទាញចិត្តស្រី, ចង់ប្រដៅស្រី, ត្រូវអ្នកធ្វើឲ្យគេដឹងថាអ្នកស្រឡាញ់គេពិតមែននោះ កាលណាអ្នកចង់បង្គាប់ឲ្យគេធ្វើអ្វី ទើបគេសុខចិត្តធ្វើតាមអ្នកបាន ។ ចូរកុំប្រើបទដេរវាយដំប្រទាក់ឲ្យសោះ ។ ហើយបើអ្នកចង់ឲ្យភរិយាអ្នកដឹងថា អ្នកស្រឡាញ់គេនោះ គ្មានអ្វីជាងអ្នកស្រឡាញ់គេឲ្យបានពិតប្រាកដនោះទេ ។

អនាគតនិងបច្ចុប្បន្នមាតាក្មេកទាំងឡាយ, សូមអ្នកជ្រាបថា កូនប្រសាស្រីរបស់អ្នក ជាគូជីវិតល្អដ៏ផ្អែមរបស់កូនប្រុសអ្នក ហើយជាអ្នកទទួលបន្ទុកយ៉ាងធ្ងន់ក្នុងគ្រួសារកូនប្រុសអ្នក ។ គប្បីអ្នកមានចិត្តទូលាយរាប់អានប្រហែលនឹងកូនស្រីរបស់អ្នកផង ។ កុំបីនឹកថាខ្លួនជាម្ដាយក្មេកហើយ ចង់ស្ដីបន្ទោស, ដេរថា យ៉ាងណាបានតាមទំនើងចិត្តរបស់អ្នកឡើយ ។

ឬមួយក៏ប្រព្រឹត្តអាក្រក់កិរិយាសង្កត់សង្កិន ហាមឃាត់ច្រើនផ្សេងៗ ដែលជាការណ៍ធ្វើឲ្យបាត់សេរីភាពក្នុងផ្ទៃស្នេហានៃស្ត្រីដែលជាទីគាប់ចិត្តរបស់កូនប្រុសអ្នក ។ កូនប្រសាស្រីរបស់អ្នក ពុំមែនជាសត្រូវរបស់អ្នកទេ ។ មានមាតាក្មេកខ្លះ គាបហួលពេកពាល់តែកូនប្រសាស្រីព្រមមិនបានសុខចិត្តរតែចោលបុត្រ , ចោលស្វាមីដែលជាទីពេញចិត្តរបស់ខ្លួន ។ នេះហើយជាឥទ្ធិពលមួយ ដែលរមែងឲ្យកើតមានករណីខានលែងលះគ្នារវាងគូស្វាមី–ភរិយា ។

–យុវនារីទាំងឡាយ ដែលជាអនាគតកូនប្រសាស្រីនឹងជាអនាគតភរិយា គប្បីជ្រាបថា មាតាក្មេករបស់អ្នកជាទីស្រឡាញ់នឹងជាទីគោរព ហើយជាអ្នកដ៏មានគុណនៃគូស្នេហាតែមួយក្នុងជីវិតអ្នក ។ គប្បីអ្នកខំអត់ទ្រាំ, គោរពរាប់អាន, និងកាន់រែកទន់ក្នុងយ៉ាងណា ឲ្យលោកចូលចិត្តអាណិតដល់ខ្លួនអ្នកផង ដើម្បីរកសេចក្តីសុខដុមនេះឲ្យមានជានិច្ចក្នុងគ្រួសារអ្នកៗ គឺសេចក្តីសុខដុមនេះហើយ ដែលជាការពេញចិត្តក្រៃលែងនៃស្វាមីអ្នក ។ មានតែបរិយាកាសសុខដុមក្នុងគ្រួសារនេះទេ ដែលជាទីកំសាន្តដ៏បរិសុទ្ធនៃបុរសទាំងឡាយ ក្រោយដែលបានតស៊ូនឿយហត់ ក្នុងកិច្ចការរកស៊ីចិញ្ចឹមជីវិត ដើម្បីគ្រួសាររស់មួយថ្ងៃ ។

សូមអ្នកកុំគិតតែប្រយោជន៍បណ្តោយតាមតែកំហឹងខ្លួន ប្រមាថមើលងាយមាតាក្មេកអ្នក ( ព្រោះមានមាតាក្មេកខ្លះ ក្រជាងកូនប្រសាប្តូរត្រកូល ខ្លួនពុំចេះដឹងដស់ត្រកូលកូនប្រសា ) ទោះបីលោកក្រោះត្រូវប្តីពុំមែនជាអ្នកចេះដឹងដូចគេក៏យើងកុំគប្បីព្រហើន មានសំដីធ្ងន់ស្រាលកំបុតកំបាញ់ទៅកាន់លោកឡើង , ព្រោះជាការបណ្តាលឲ្យស្វាមីអ្នកតូចចិត្ត ហើយដែលជាហេតុញុំាងឲ្យស្នេហានៃស្វាមី ចំពោះរូបអ្នកនោះកាន់តែអន់ថយទៅ ។ ការព្រហើននេះហើយទុកជាសេចក្តីកំហែងគម្រាមដែលនឹងត្រូវកើតមាន ដល់ជោគសួស្តីនៃគ្រួសារអ្នកក្នុងពេលមិនយូរប៉ុន្មាន ។

អ្នកស្រី សខន-សមន

---

# ការសិក្សាក្នុងប្រទេសជប៉ុន

ការដែលប្រទេសជប៉ុន បានឈានដើរទៅមុខយ៉ាងរហ័សក្នុងរយៈពេលមិនយូរប៉ុន្មានឆ្នាំមកនេះ គឺព្រោះប្រទេសជប៉ុនមានការសិក្សា ដែលជាបច្ច័យយ៉ាងសំខាន់ ក្នុងការកសាងសេចក្តីចំរើនរុងរឿងរបស់ប្រទេស ពេលនេះ ពលរដ្ឋក្នុងប្រទេសជប៉ុន ដែលបានទទួលការសិក្សាមានចំនួនច្រើនជាង ៩៩, ៥៨ភាគរយ ,ព្រោះហេតុនេះប្រជាជនជាពលរដ្ឋរបស់ជប៉ុន ក៏កើតមានមនុស្សឆ្លាតវាងវៃចេះដឹងវិជ្ជាផ្សេងៗ

ហើយអាចធ្វើការប្រែផង់ប្រណាំងនិងជាតិដទៃៗ បានតាំងក្នុងផ្លូវឧស្សាហកម្ម ពាណិជ្ជកម្ម និងសេន្យានុភាព ក្នុងឱកាសនេះ ខ្ញុំមានបំណងចង់លើកប្រវត្តិនៃការសិក្សារហូតដល់វិធីចាត់ការសិក្សារបស់ប្រទេសនេះ, ឲ្យបានដឹងថា គេបានដំណើរការមកដោយអាការយ៉ាងណាខ្លះ ប្រវត្តិសាស្ត្ររបស់ជប៉ុនបានចាប់ផ្តើមមានឡើងមុនពុទ្ធសករាជ ១១៧ ឆ្នាំ ។

ក្នុងឆ្នាំនោះជាឆ្នាំសំខាន់បំផុត នៃពង្សាវតាររបស់ជប៉ុន ពីព្រោះឆ្នាំនោះហើយដែលជប៉ុនមានព្រះមហាក្សត្រិយ៍ជាដំបូង ព្រះមហាក្សត្រិយ៍នោះទ្រង់ព្រះនាមថាព្រះបាទចិម្មុ ដែលបានធ្វើបឋមរាជាភិសេកនៅទីក្រុងយាមាតូ ក្នុងកោះហុនដូ, រាប់តាំងពីត្រឹមនោះមកដរាបដល់សម័យនេះ ក៏ល្មមសមគួរនឹងរាប់បានថា ប្រវត្តិសាស្ត្ររបស់ជប៉ុនបានដំណើរមកហើយប្រហែល ២៥៩៨ ឆ្នាំ; នៅក្នុងរយៈវេលាយូរដ៏អង្វែងនេះ ជប៉ុនបានព្យាយាមរៀបចំរបៀបបែបផែននៃទីប្រជុំជន តាមគំនិតរបស់ខ្លួនឯង ហេតុនោះល្មមយើងដឹងអនុមានបានថា វិធីចាត់របៀបការសិក្សារបស់ជប៉ុនជាន់ដំបូងក៏គង់តែអនុលោម តាមរបៀបនៃទីប្រជុំជន ដូចបានពណ៌នាមកហើយនោះ ក្រោយពីជប៉ុនបានចាត់របៀបការសិក្សាដោយខ្លួនឯងនោះ ជប៉ុនបានព្យាយាមដកស្រង់ផ្លូវរបៀបការសិក្សាតាមលំនាំវឌ្ឍនធម៌របស់ចិននិងឧត្តមគតិរបស់ពុទ្ធសាសនាបញ្ចូលទៅជារបៀបក្នុងការសិក្សាផងទៀត ដូចយ៉ាងតួអក្សរគឺជប៉ុនចំលងយកពីចិនមកតាំងតម្រាប់តម្រាប្រាជ្ញារបស់ខុងជឺ ដែលជាកំពូលអ្នកប្រាជ្ញរបស់ចិននោះ គឺជប៉ុនបញ្ចូលទៅប្រើក្នុងប្រទេសរបស់ខ្លួនកាលពុទ្ធសតវត្សទី ៨, ក្នុងសម័យនោះអារ្យធម៌របស់ជប៉ុនក៏បានចំរើនរុងរឿងឡើង , ប្រហែលជាក្នុងសម័យនេះឯងហើយដែលសិល្បការផ្សេងៗដូចជាការចិញ្ចឹមដង្កូវនាងធ្វើសូត្រ ការតម្បាញការធ្វើស្រា ជាងដែករបស់កោរ៉េ (កូរ៉េ) ក៏បានផ្សាយចូលទៅក្នុងប្រទេសជប៉ុន ក្នុងរយៈនេះដែរ, ព្រះរាជវង្ស កាកៃតសុកោ ព្រះអង្គបានតាំងសាលារៀនក្នុងរាជដំណាក់, តមកក្នុងពុទ្ធសតវត្សទី ១១ ក៏មានអ្នកនាំយកពុទ្ធសាសនាអំពីប្រទេសកោរ៉េចូលទៅប្រទេសជប៉ុន, ព្រះពុទ្ធសាសនានេះបានជាគ្រឿងឧបត្ថម្ភសេចក្តីចំរើនក្នុងផ្លូវវិជ្ជានិងអារ្យធម៌ដល់ប្រទេសជប៉ុនយ៉ាងច្រើន, ។

ក្នុងពុទ្ធសករាជ ១១៥០ ស្តេចរាជវង្សសោតោកុតៃឈិ បានទ្រង់ចាត់តាំងព្រះអារាមល្អមួយឈ្មោះហូរ៉ិយុឈិ ឯទីក្រុងណារ៉ា ហើយទ្រង់បានចាត់តាំងសាលារៀនតាមបរិវេណជុំវិញវត្តនោះ ដែលគេចាត់ទុកជាស្ថានសិក្សាជាន់ដំបូង របស់ប្រជារាស្ត្រជប៉ុន ។

លុះអំណឹះតមក ដល់ពុទ្ធសករាជ ២៤១០-- ២៤៤៥ ជាសម័យដែលជប៉ុនចាប់ផ្ដើមកសាងខ្លួនតាមរបៀបបស្ចិមប្រទេស ជប៉ុនបានទទួលយករបៀបការសិក្សាខ្លះរបស់ពួកបស្ចិមប្រទេសនិងរបស់អាមេរិកមកជាគំរូក្នុងការសិក្សារបស់ជាតិ...

របៀបប្រជុំជនរបស់ជប៉ុន ប្រកាន់យ៉ាំនៅត្រង់ការគោរព បុព្វបុរសឬគ្រួសារដែលជាមូលដ្ឋាន ព្រោះប្រកាន់យ៉ាំថា ជនជាតិជប៉ុនម្នាក់ៗសុទ្ធតែតសន្ដតិវង្សមកអំពីសាលោហិតជាមួយគ្នា. ប្រមូលផ្ដុំឡើងទៅត្រង់មហាគ្រួសារ មានរាជត្រកូលនៃសម្ដេចព្រះចក្រពត្តិជាប្រមុខរបស់ជាតិ ក្នុងសម័យបុរាណមានប្រពៃណីថា ត្រកូលណាបានប្រកបអាជីវភាពបែបណា បុត្រកិរិយារបស់ត្រកូលនោះ ក៏ត្រូវតែប្រកបអាជីវភាពតាមរបៀបរបស់ត្រកូលនោះតទៅ ៗ ប្រពៃណីបែបនេះ មិនមែនប្រើចំពោះតែប្រទេសជប៉ុនមួយប៉ុណ្ណោះទេ សូម្បីក្នុងប្រទេសអឺរ៉ុបសម័យកណ្ដាលក៏មានប្រើប្រពៃណីនេះដែរ ដូចយ៉ាងកូនរបស់មន្ត្រីតអំពីឪពុកមក , កូនរបស់ត្រកូលដែលមានអាជីវភាពខាងជាងដែក ក៏ត្រូវធ្វើជាជាងដែក, កូនរបស់ជាងដេរស្បែកជើងក៏ត្រូវទទួលនាទីធ្វើជាជាងដេរស្បែកជើង តាមរបៀបគ្រួសារមក ៗ

របៀបការសិក្សាក្នុងសម័យនោះមិនបានដំណើរទៅដោយសេរីទេ . ការសិក្សាជាដំណើរទៅតាមថ្នាក់របស់ជន. ហេតុនោះការសិក្សារបស់ជប៉ុនសម័យបុរាណនោះនឹងចាត់ថាជាការសិក្សាក្នុងសាលារៀនមិនបាន ព្រោះការដែលរៀនវិជ្ជាជីវៈផ្សេងៗច្រើនតែបង្ហាត់បង្រៀនទៅតាមគ្រួសាររបស់ខ្លួនៗ ឬតាមភូមិជនបទ ដែលគេប្រកបរបររកស៊ីអ្វី គេក៏បង្ហាត់តាមរបៀបនោះទៅ ៗ

លុះដល់សម័យដែលផ្លូវគមនាគមន៍រវាងប្រទេសជប៉ុននិងដែនដីគោកអាស៊ីបានចំរើនឡើង ក៏ពួកចិននិងពួកកូរ៉េ ចូលទៅមកគោះជប៉ុនដើម្បីទាក់ទងក្នុងផ្លូវជំនួញ ការចាំបាច់ក្នុងការប្រើតួអក្សរចិនក៏បានកើតមានឡើង តាំងពីនោះមក កូនចៅរបស់ជនជំពូកនេះ ក៏បានទាក់ទងរហូតមកជាច្រើនតំណអាយុមនុស្ស អ្នកតំណាងត្រកូលរបស់កូរ៉េម្នាក់ឈ្មោះកានដែលមកអំពីជនបទឈ្មោះ កុតារ ក្នុងប្រទេសកូរ៉េ កាលពីរវាង ព.ស ៨២៣ បានមកតាំងទីលំនៅ នៅតំបន់កាវ៉ាជិ ក្នុងខេត្តអូសាកា និងអ្នកតំណាងត្រកូល កាណ៊ីនោអូមិ ដែលមកអំពីប្រទេសចិន ចូលកាន់ផ្សំខាងកូរ៉េ (ខាងក្រោយគាត់ ៤ ឆ្នាំ) នោះបានទៅតាំងភូមិលំនៅឯយ៉ាម៉ាតូ (ក្នុងខេត្តណារ៉ា) ត្រកូលទាំងពីរនេះបានទទួលសរលារបស់ខ្លួនក្នុងការសិក្សាអក្សរចិនយ៉ាងតឹងរឹង លុះក្រោយតែបាននាមថា “ ហ៊ូមិតូប៊ិ „ (ដែលប្រែថាពហុស្សុត) នៃយ៉ាម៉ាតូនិងកាវ៉ាជិ ក្នុងសម័យតមកក៏មានអ្នក

សិក្សាជាតិចិននឹងជាតិកូរ៉េផ្លាស់សញ្ជាតិទៅជាជប៉ុន ហើយបានព្យាយាមរៀនអក្សរចិនអំពីអ្នក ដែលតវង្សត្រកូលរបស់ជនទាំងពីររូប ដែលបានចេញឈ្មោះមកហើយនោះ ទោះបើយ៉ាងម្ដេចក្ដី ការសិក្សារបស់ជប៉ុនក៏នៅមានការបង្អៀតបង្អល់ជាច្រើន ព្រោះនៅមិនទាន់មានសាលារៀន ដែលទាន់សម័យកើតឡើង ។

កាល ព.ស. ១០៩៥ ព្រះពុទ្ធសាសនាបានផ្សាយទូទៅក្នុងប្រទេសជប៉ុន ហើយមានឥទ្ធិពលគ្របដណ្ដប់ទៅលើទឹកចិត្តរបស់ជនជាតិជប៉ុន, សឹងមានជនជាតិជប៉ុនមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាជាច្រើន បានចេញបួសជាភិក្ខុភាវៈក៏ច្រើនណាស់ ។

ក្នុងខាងចុងនៃសតវត្សទី ១១ វប្បធម៌របស់ចិនក៏បានហូរចូលទៅកាន់ប្រទេសជប៉ុនយ៉ាងខ្លាំងអស្ចារ្យ. ការចលនាយ៉ាងនេះហើយ ដែលដឹកនាំចិត្តគំនិតរបស់រដ្ឋាភិបាលជប៉ុន ក្នុងសម័យនោះឲ្យបានបញ្ជូនយុវជនជប៉ុនជាចំនួនច្រើន ឲ្យទៅសិក្សាសិល្បវិជ្ជាការក្នុងប្រទេសចិន. កាលបើអ្នករៀនទាំងនោះបានវិលត្រឡប់ទៅប្រទេសជប៉ុនវិញហើយក៏បានចាប់ផ្ដើមបង្ហាត់បង្រៀន ពលរដ្ឋតាមរបៀបសិល្បវិទ្យាការ ដែលខ្លួនបានទៅសិក្សាអំពីភូមិភាគអាស៊ីមក ៦ សាលារៀនក៏បានកើតឡើងក្នុងសម័យនោះ ។

តមកដល់រជ្ជសម័យព្រះចៅចក្រពត្តិ ដេនឃិ ទ្រង់ក៏បានចាត់តាំងក្រុមសិក្សាឡើង ដែលហៅតាមភាសាជប៉ុន "ហ្វុមិតយ៉ាគិកាសាគាមិ" ក្រុមនេះមានការបង្គិកង់កិច្ចសិក្សារបស់ជនជាតិជប៉ុន ហើយបានតាំងសាលារៀនដែលហៅថា "ដៃហ្គាគុ រិយ៉ូ" (Daigaku Ryo) ក្នុងរាជ្យរជ្ជសម័យព្រះចៅចក្រពត្តិម៉នមុ បានមានចេញព្រះរាជក្រមតាំងវិទ្យាល័យក្នុងរាជធានី ដើម្បីអប់រំបណ្ដុះបណ្ដាលខ្ញុំអ្នករាជការ (ព្រះរាជក្រមនេះហៅថាព្រះរាជក្រម (ថៃហូ) ដែលមានដាក់ខបន្ទាប់ស្ដីអំពីការសិក្សាផងនោះក្នុង – ព.ស.១២៤៤ រដ្ឋាភិបាលបានចេញប្រកាសតាំងសាលារៀន ហៅថា "ដៃហ្គាគុ" និង "កូគុហ្គាគុ" ឡើង សាលារៀនដៃហ្គាគុ ជាខ្នែងសិក្សាដែលនៅក្នុងរាជធានី, ចំណែកសាលារៀន កូគុហ្គាគុនោះជាគ្រឹះស្ថានសិក្សា ដែលតាំងទៅតាមខេត្តនានា (ដូចជាសាលារៀន ដែលមាននៅតាមខេត្តរបស់យើង) "ដៃហ្គាគុ" ជាកន្លែងសម្រាប់សិក្សាបានចំពោះតែបុគ្គលជាន់ទី ៥ (គឺជនជាន់ខ្ពស់) បានដល់ពួកជនដែលជំណាសន្តតិវង្សមកអំពីពហុស្សុតយ៉ាម៉ាតូ និងកាវ៉ាឈិ មេរៀនដែលគេបង្ហាត់ក្នុងសាលាដៃហ្គាគុនោះ មានបរមត្ថវិជ្ជារបស់ចិន ការសរសេរនិងគណិតសាស្ត្រ ជំណាតមករដ្ឋាភិបាលក៏បានផ្លាស់ប្ដូរមេរៀនបែបថ្មី គ្រឹះស្ថានសិក្សានេះទទួលនាក់រៀនមានកំណត់

ចំនួនមិនឲ្យលើសពី ៤៥០ នាក់។ ចំណែកឯសាលាកូគុផ៉ាគុ ដែលគេតាំងតាមខែត្រនានានោះ ក៏ទទួលបានចំពោះតែកូនចៅរបស់ខ្ញុំរាជការប៉ុណ្ណោះ តែបើកន្លែងនោះមាននៅសល់ក៏ទទួលកូនចៅរបស់រាស្ត្រឲ្យរៀនបានដែរ, ភាសាដែលបង្រៀនក្នុងគ្រឹស្ថានសិក្សានេះ មានតុស្ដីបណ្ឌិតខាងបរមត្ថវិជ្ជាចិន (Doctors of chinese philosophy) និងវិទ្យាសាស្ត្រតុស្ដីបណ្ឌិត (Doctor of médechine) តមកជប៉ុនបានតាំងច្បាប់បង្គាប់ដែលមានការទាក់ទងនឹងការបង្រៀនបរមត្ថវិជ្ជាចិន និងវិទ្យាសាស្ត្រឲ្យបានសមរម្យឡើង ដល់មកក្នុងសម័យ "ហៃយាន" (ព-ស ១៣៣៧ -១៧៦៦) រដ្ឋាភិបាលបានតាំងសាលារៀន "ដៃផ៉ាគុ" ឯទក្រុងគៀវតូ និងសាលារៀនកូគុផ៉ាគុ ឯទីក្រុង "ដាសាអ៊ីហ្វូ" ក្នុងកោះ "គិវជិវ" ហើយនឹងខែត្រដទៃៗ ទៀត គ្រឹស្ថានសិក្សាទាំងអម្បាលនេះ បានពង្រីកខ្លួនក្លាយនៅមជ្ឈដ្ឋាននៃការសិក្សារបស់ជនជាតិជប៉ុន ក្នុងសម័យជាមួយគ្នានោះ ឥស្សរជនជាន់ខ្ពស់ជាតិជប៉ុន បានចាត់តាំងសាលារៀនពិសេសដោយឡែក សម្រាប់បង្រៀនបំពេញវិជ្ជាដល់កូនចៅរបស់ខ្លួន ដែលបានរៀនសម្រេចមកពីសាលារៀនដៃផ៉ាគុមកហើយ សាលាពិសេសទាំងនេះគឺ សាលាកូប៊ុនអ៊ិន, ខានផ៉ាគុអ៊ិន, តូផ៉ាគុអ៊ិន និងម៉ុនថូអ៊ិន, ក្នុងព.ស.១៣៧០ ភិក្ខុមួយរូបឈ្មោះគុដាអ៊ិ បានតាំងសាលារៀនឈ្មោះ "ឈុគ៉ីឈុជិអ៊ិន" ឡើងឯ "ហូរិខាក៉ូរិ" ក្នុងក្រុងគៀវតូ គ្រឹស្ថានសិក្សាថ្មីនេះមានវត្ថុបំណង ដើម្បីឲ្យការសិក្សានេះផ្សាយដល់រាស្ត្រសាមញ្ញ តែសាលានេះតាំងនៅមិនបានក៏រលំរលាយសាបសូន្យទៅ ពុទ្ធសតវត្សទី ១៧ អំណាចខាងផ្នែកនយោបាយរបស់ជប៉ុន ធ្លាក់ទៅក្នុងកណ្ដាប់ដៃជនអ្នកចម្បាំង "សាមូរ៉ៃ" សភាពការសិក្សាក៏បានផ្លាស់ប្ដូរ ចាប់តាំងពីសាមូរ៉ៃកាន់កាប់អំណាចការគ្រប់គ្រងប្រទេសមកក៏បានឧបត្ថម្ភការសិក្សាឲ្យបានចំរើនទៅខាងផ្លូវវិជ្ជាការទាហាន ខ្លាំងជាងការសិក្សាតាមបែបផែនវប្បធម៌នោះ ក៏ទន់ខ្សោយថយចុះ ឬទ្រឹងនៅមិនមានការចំរើនលូតលាស់ទៅមុខទៀត ។

សាលារៀនដៃផ៉ាគុ ក្នុងក្រុងតូគៀវ (តូក្យូ) ក៏ត្រូវបិទលែងឲ្យរៀន បណ្ណាល័យ "កាណាសាវ៉ា-ប៊ុនកូ" និងសាលារៀន "អាឈិខាក៉" ដែលកន្លែងសម្រាប់ជនជាតិជប៉ុនក្នុងសម័យនោះសិក្សា ពួកអ្នកប្រាជ្ញនឹងពួកភិក្ខុក៏ត្រូវលបចូលទៅរៀនដោយការសម្ងាត់ក្នុងបន្ទប់ពិសេស ពួកអស់លោកនៅក្នុងរាជដំណាក់នៃក្រុងតូក្យូ ក៏សិក្សាវិជ្ជាដើម្បីធ្វើនាម៉ុនជប៉ុន តាមគន្លងរបៀបមួយរបស់ត្រកូលខ្លួន ។

ហេតុនោះ ជនជំពូកអ្នកចម្បាំង "សាមូរ៉ៃ" បានទទួលការសិក្សាតាមវិហារនិងអាស្រមផ្សេងៗ ចំ

ចំណែកឯប្រជារាស្ត្រទៀតសោតក៏អាស្រ័យការសិក្សា ដោយយកកន្លែងទាំងនេះធ្វើជាទីអប់រំកុលបុត្រកុល – ធីតារបស់ខ្លួនផងដែរ ។

កាលពុទ្ធសតវត្សទី២២ សោគុនតូកុងាវ៉ាអ៊ីយេយ៉ាស៊ុ ឬជាអ្នកសម្រេចរាជការផែនដីប្រទេសជប៉ុនក្នុងសម័យនោះ បានផ្លាស់កន្លែងរដ្ឋាភិបាលរបស់ខ្លួនទៅតាំងឯទីក្រុង "យេដូ" (គឺក្រុងតូក្យូសម័យបច្ចុប្បន្ននេះ) ហើយបានប្រញាប់ចាត់ការសិក្សារបស់ប្រជារាស្ត្រយ៉ាងបន្ទាន់ រដ្ឋាភិបាលបានឈានដៃចូលទៅជួយឧបត្ថម្ភចាត់ការតាំងសាលារៀនសំ–រាប់រាស្ត្រតាមរបៀបរបស់គ្រូកុលហាយាឈិ ហើយបានតាំងឈ្មោះឡើងជាថ្មីថា "ជូហេអ៊ិកូ" តាំងបានចាត់ការបង្ហាត់បង្រៀនតាមបែបរបស់គ្រូកុល "ហា-យាឈិ" ដូចគ្នានឹងសាលារៀនដែងាកុ-ណូកាមិ បានទទួលរ៉ាប់រងនូវវិទ្យាស្ថាន ឲ្យស្មើប្រហែលនឹងសាលារៀនរដ្ឋាភិបាលក្នុងសម័យមួយជាមួយគ្នានោះ រដ្ឋាភិបាលបានចាត់ការតាំងសាលារៀន "វ៉ាង៉ាកុឆូ" (សាលារៀនសម្រាប់សិក្សាភាសាជប៉ុន) សាលារៀន "អ៊ិង៉ាកុឆូ" (សាលារៀនពេទ្យហូឡង់) សាលារៀន "រិកាង៉ុនឆូ" (សាលារៀនបង្ហាត់វិជ្ជាការទា–ហានជើងគោក) នឹងសាលារៀន "ដៃង៉ុនឆូ" (សាលារៀនបង្ហាត់វិជ្ជាការទាហានជើងទឹក) នឹងសាលារៀនប័នឆូឈិរ៉ាបឆូ (សាលារៀនបង្ហាត់ភាសាបរទេស ហេតុនោះក្នុងខាងចុងសម័យតូកុកាវ៉ា (ព.ស. ២១៥៨–២៤០៩) គ្រឹស្ថានដែលសិក្សាផ្សេងៗ ក៏បានបន្ថែមចំនួនកាន់តែច្រើនពាសពេញទីក្រុងនោះ ពូជពង្សវង្សត្រកូលរបស់ជប៉ុនទាំងឡាយ ក៏បានដំ–ណើរតាមគន្លងផ្លូវ របៀបរបស់រដ្ឋាភិបាលក្រុងយេដូ មានការចាត់សាលារៀនសម្រាប់វង្សត្រកូលដើម្បីឲ្យកូនចៅរបស់គេ បានសិក្សាសូត្ររៀនឲ្យបានជិតដល់ គ្រឹស្ថានសិក្សាទាំងនោះបានអប់រំវិជ្ជាធម៌ ដល់កុលបុត្រកុលធីតាជប៉ុនតាមរបៀបបង្ហាត់របស់ប្រាជ្ញាមេង៉ឺ ខុងជឺ; ចំណែកខាងការហ្វឹកហាត់វិជ្ជាទាហាន ឬ វិជ្ជាចំបាំង នៅអប់រំតាមរបៀបបែបផែន របស់លទ្ធិ "បូស៊ិដូ" សាលារៀនប្រភេទនេះជាកន្លែងសម្រាប់ផ្តល់ការសិក្សាខាងវិជ្ជាការទាហានទាំងខាងផ្លូវវិជ្ជាធម៌ ក្នុងព្រះរាជាណាចក្រជប៉ុនទាំងមូល មានសាលារៀនបែបនេះប្រហែលជា៤៧០សាលា ។

លុះដល់មកក្នុងពុទ្ធសតវត្សទី ២៣ ការសិក្សាវិជ្ជាសាមញ្ញតាមបែបបឋមសិក្សា ក៏បានចំរើនឡើងយ៉ាងក្រៃលែង ពួកគ្រូបង្រៀនក្នុងសាលារៀន តេរ៉ាខូយ៉ា ទាំងនេះក៏បានដឹកនាំកុមារកុមារីជប៉ុន ដែលនៅក្បែរៗសាលានោះឲ្យចូលរៀន ហើយបានបង្ហាត់វិជ្ជាសាមញ្ញ ដែលធ្វើឲ្យគេឆាប់បានចេះដូចយ៉ាងបង្ហាត់អាន, សរសេរ, នឹងលេខគណិត ។

(មានត)

# ពត៌មានគួរដឹងខ្លះ គួរគិតខ្លះ

មានក្រមុំឥណ្ឌៀម្នាក់ឈ្មោះ ហាមីដា-ពានូ នៅស្រុកស្យាបុរ ជាអ្នកកីឡាចម្បាប់ឯកសាកល បានប្រកាសរកប្រុសណា ដែលអាចចាប់លើកខ្លួននាងឲ្យបានផុតពីដី ហើយបោកនាងផ្ងួលទៅវិញបាន នឹងយកធ្វើប្ដីភ្លាម ។ គេថាបានជានាងប្រកាសដូច្នោះ ដោយដឹងខ្លួនថា រកប្ដីពិបាកណាស់ ព្រោះនៅពេលថ្មីៗនេះ នាងបានបោកអ្នកចម្បាប់សាកលម្នាក់ ផ្ងួលបាត់មាត់នាំឲ្យគេខ្លាចគ្រប់គ្នា ។

× × ×

មានបុរសនៅកាលីហ្វ័រនីម្នាក់ ខំរស៊ីធ្វើការយ៉ាងខ្លាំង ដរាបដល់បានជាអ្នកមានទ្រព្យស្ដុកស្ដម្ភ អាចទិញយន្តហោះមួយជិះបានដោយខ្លួនឯង ។ បុរសនោះមិនគិតចង់បានប្រពន្ធសោះ តែនរណានិយាយពីរឿងស្រីៗ គាត់ស្ដោះទឹកមាត់ ហើយក្រោកដើរចេញភ្លាម ។

ដោយហេតុបុព្វេសន្និវាស កាលគាត់ជិះយន្តហោះផ្ទាល់ខ្លួនគាត់ទៅលេងកន្លែងនោះ, ម៉ាស៊ីនយន្តហោះកើតមិនស្រួល ហើយភ័យខ្លាំងពេកក៏លោតចុះពីយន្តហោះជាមួយឆ័ត្រយោងមកដី ។ ពេលនោះខ្លួនគាត់មិនរសាត់ទៅណា, ទៅជាធ្លាក់ទៅលើខ្នងមេគោមួយ ដែលនាងក្រមុំម្ចាស់គោកំពុងតែរិតទឹកដោះ ហើយគាត់ក៏កើតសេចក្ដីស្នេហាផតចិត្តមិនរួច ដែលតមក៦ខែ គាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយនាងនោះទៅ ។

ប្រុសក៏ដោយស្រីក៏ដោយ ដែលអួតថាមិនចេះស្រឡាញ់នរណាសោះនោះ មកពីមិនទាន់ជួបប្រទះនឹងមនុស្សត្រូវចិត្តប៉ុណ្ណោះ តែកាលណាត្រូវចិត្តហើយ សូម្បីកូនសេដ្ឋីកំលោះបង់ហាន់ៈមកយកកូនយាយចកក៏មានដែរ ។

★ ★ ★

មានស្ត្រីម្នាក់នៅប្រទេសអាមេរិក (មិនស្គាល់-ឈ្មោះ) នាងមានដោះ ៤ តែដោះពីរប្រើការបាន ដោះពីរទៀតគ្រាន់តែដុះឡើងទ្រដោះល្អប៉ុណ្ណោះ ។

★ ★ ★

បន្ទាប់ពីចុះហត្ថលេខា លើសន្ធិសញ្ញាការពារទ្វីបអាស៊ី SEATO ឯប្រទេសហ្វីលីពីន, ខាងរុស្ស៊ីនឹងចិនក្រហម បានក្ដៅក្លួលយ៉ាងខ្លាំងបបួលគ្នាឃោសនាថា សញ្ញានោះគឺអាមេរិកាំងដឹកនាំជនជាតិអាស៊ីប្រឆាំងនឹងខ្លួន ។ ចំពោះរឿងនេះមានពាក្យខាងប្រទេសថៃដែលគួរស្ដាប់មួយឃ្លាថា "ថៃជាប្រទេសតូចមានកំឡាំងការពារខ្លួនឯងមិនគ្រប់គ្រាន់, បើប្រសិនជាកាន់នយោបាយអព្យាក្រិត គឺនយោបាយជាន់តែមខ្ទូកទាំងពីរខាងធ្វើព្រងើយ ហើយតែខាង

ណាអន្ទ្រយធ្ងន់ទៅម្ខាងណា មុខជាទូកលិច ។ ដូច្នេះ ទើបថៃព្យាយាមរើសរកមិត្តណាបរិសុទ្ធ និងទាត់ចោលមិត្តណាដែលប្រឡុងប្រឡូស ។

អ្នកនយោបាយថៃថា បើពួកក្រហមជាអន្ធពាល ដើរតែបៀតបៀនគេ ដូចបានឃើញសព្វថ្ងៃហើយ តើថៃមិនរើសខាងពួកប្រទេសសេរីប្រជា-ធិបតេយ្យ យកមកជាគ្នាដូចម្តេចបាន ?

× × ×

កាសែតឡាវឈ្មោះឡាវឃោសនាការ ប្រចាំថ្ងៃ ១៦-១១-៥៤ ថាឧត្តមសេនីយ៍គុលីន កាលមកដល់ព្រៃនគរបាននិយាយថា ចំនួនប្រាក់ដែលសហរដ្ឋបានជួយសមាគតរដ្ឋទាំងបីនោះដូច្នេះ តាំងពីឆ្នាំ ១៩៥០មកដល់ថ្ងៃ ៣០ មិថុនា ១៩៥៤ អស់ប្រាក់ ១២៥.៤០០.០០០ ដុល្លា ។ ប្រាក់នេះមាន ៣០.១០០.០០០ដុល្លាជួយខាងកិច្ចការទាហាននិងការបរិហាររដ្ឋ, ឯខាងសេដ្ឋកិច្ចអស់ ៩៥.៣០០.០០០ ដុល្លា ។

តាំងពីឆ្នាំ១៩៥១ដល់១៩៥៤ការជួយតទៅនេះ

ប្រទេសឡាវ ១៧.៣០០.០០០ដុល្លា

ប្រទេសខ្មែរ ៧.៣០០.០០០ដុល្លា

ប្រទេសយួន៧០.៧០០.០០០ដុល្លា

សម្រាប់ឆ្នាំ ១៩៥៥ ក្រុងវ៉ាស៊ីនតោនបានព្រមព្រៀងឲ្យជួយដូច្នេះតទៅទៀត ៖

ប្រទេសឡាវ ១២.៥០០.០០០ដុល្លា

ប្រទេសខ្មែរ ៧.៣០០.០០០ ដុល្លា

ប្រទេសយួន ៧៧.២០០.០០០ដុល្លា

បូករួម ៩៧.០០០.០០០ ដុល្លា

★ ★ ★

សហប្រជាជាតិ–៥-១១-៥៤ ដំណឹងពីញូវ-យ៉កថា ដុកទ័រម៉ាមុកអស្មី ជាជំណាងប្រទេសអេ-ហ្ស៊ីប្ត ប្រចាំនៅអង្គការសហប្រជាជាតិ បានដួលសន្លប់បាត់ស្មារតី ហើយដាច់ខ្យល់ស្លាប់មួយរំពេចក្នុងខណៈដែលជជែកពីរឿងប្រទេសអ៊ីស្រាអែលប្តឹងអំពីប្រទេសអេហ្ស៊ីប្តចាប់នាវាពាណិជ្ជអ៊ីស្រាអែលក្នុងព្រែកជីកស៊ុយអេសដោយឥតហេតុផល ។

អេហ្ស៊ីប្តថា នាវាអ៊ីស្រាអែលបាញ់នាវានេសាទរបស់ខ្លួនបណ្តាលឲ្យស្លាប់ពីរនាក់ ។ ចំណែកអ៊ីស្រា-អែលថា អេហ្ស៊ីប្តគ្រាន់តែចោទប្រកាន់ទទេៗឥតបាននាំសពទៅគណកម្មការពិនិត្យការស្ងប់សឹក ក្នុងក្រុងបាឡេស្តៃមើលសោះ ។

+ + +

ចិនកុម្មុយនិស្តបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងខាងជំនួញ ជាមួយប្រទេសភូមាទិញស្រូវ ១៥០.០០០តោនពីភូមា ដើម្បីប្តូរគ្នានឹងទំនិញប្រ-ភេទខ្វះរបស់ចិនកុម្មុយនិស្ត ។

មហា សម-ម៉ន

នៅអនាគតដ៏ខ្លីនេះ រដ្ឋាភិបាលភូមានឹងបញ្ជូនគណៈកម្មការខាងជំនួញទៅប៉េកាំង ដើម្បីពិនិត្យមើលតើមានទំនិញអ្វីខ្លះដែលភូមាត្រូវការ ។

★ ★ ★

បាងកក—វិទ្យុថៃថ្ងៃទី ១០-១១-៥៤ ផ្សាយថា ដោយរដ្ឋាភិបាលភូមាបានថ្វាយបត្តិ ចំពោះមកសម្ដេចព្រះសង្ឃនាយកប្រទេសថៃ សូមឲ្យជ្រើសរើសព្រះ-ថេរៈ២០អង្គទៅរួមប្រជុំធ្វើឆដ្ឋសង្គាយនា នោះ, គណៈមន្ត្រីសង្ឃបាន ស្នើសុំឲ្យរដ្ឋាភិបាលជួយឧបត្ថម្ភក្នុងដំណើរនេះ ។

គណៈរដ្ឋមន្ត្រីថៃ បានប្រជុំហើយក៏បានអនុមតិជាឯកច្ឆន្ទដើម្បីឧបត្ថម្ភចំពោះកិច្ចនោះ ។

× × ×

ដំណឹងពីតេហេរ៉ង់ថា កាលពីព្រឹកថ្ងៃទី ៩-១១-៥៤នេះ តុលាការពិសេសនៃប្រទេសពែរ្សបានកាត់ឲ្យបាញ់សម្លាប់ដុកទ័រ ហ៊ូសេន-ហ្វាតេមី ដែលជារដ្ឋមន្ត្រីការបរទេសសម័យដុកទ័រម៉ូសាដេក ដោយហេតុថាលោក ហ្វាតេមីនេះ ព្យាយាមរំលើងរាជបល្ល័ង្កស្ដេច រ៉េសាប៉ាឡេវី ហើយនឹងបាត់តាំងរបបសាធារណរដ្ឋកុម្មុយនិស្តវិញ ។ ដុកទ័រហ្វាតេមីបានថ្វាយដីកាចំពោះព្រះចៅដែរ តែស្ដេចបានបដិសេធដីកាចោល ។

★ ★ ★

ដំណឹងពីសិង្ហបុរី (១១-១១-៥៤)ថា អគ្គការបរិហារវិទេសករណីយកិច្ចនៃសហរដ្ឋអាមេរិក បានព្រមព្រៀងនឹងចាត់តាំងមន្ទីរបាតិការ នៃអគ្គការនេះនៅប្រទេសឡាវនឹងប្រទេសខ្មែរ ដើម្បីជួយអនុ-គ្រោះប្រទេសទាំងពីរនេះ ដោយចំពោះកុំបាច់ដំណើរកិច្ចការ តាមផ្លូវព្រៃនគរដូចពីមុនៗ ។

តាមពាក្យថ្លែងនៃអគ្គការវិទេសករណីយកិច្ចថា សហរដ្ឋអាមេរិកនឹងបារាំងសេស សុទ្ធតែមានចេត-នាយ៉ាងបរិសុទ្ធក្នុងការជួយទំនុកបំរុង ខាងការពារឯករាជ្យ ហើយនឹងសេរីភាពនៃប្រទេសទាំងពីរ ។

× × ×

វិទ្យុថៃថ្ងៃទី១៦-១១-៥៤ ផ្សាយថា បានដំណឹងពីភ្នំពេញមកថា ឥស្សរគណៈនាយ សឺន-ង៉ុក ថាន់ បានចូលស្វាមីភក្តិអស់ហើយ ហើយបានទទួលនិរ-ទោសកម្ម ឲ្យចូលកាន់ប្រជាគយកម្ពុជាដូចដើមវិញ ។ មួយទៀតរដ្ឋាភិបាលកម្ពុជាថ្លែងការណ៍ថា តាមដែលមានដំណឹងចចាមអារាមថា បារាំងសេសនឹងសុំតាំងទ័ពប្រចាំនៅប្រទេសកម្ពុជាតទៅ បើប្រ-សិនជារដ្ឋាភិបាលខ្មែរសុំនោះ, ពាក្យនេះពុំអាចក្លាយទៅជាពិតប្រាកដទៅបានឡើយ, ព្រោះតាមសេចក្ដីព្រមព្រៀងក្នុងការស្ងប់សឹក ដែលទាក់ទងនឹងប្រ-ទេសកម្ពុជានោះ, ពុំមានអនុមាត្រាណា អនុញ្ញាតឲ្យ

កំឡាំងទាហាននានាជាតិ តាំងនៅក្នុងដែនដីកម្ពុជាទេ ។

× × ×

វិទ្យុដេល្ហី (ថ្ងៃ២០-១១-៥៤)ថាវិស្វករជំនាញការក្នុងការផលិតដែកថែបរបស់សូវៀតចំនួន១៦នាក់បានទៅដល់ឥណ្ឌាហើយ កាលពីថ្ងៃ១៨-១១-៥៤ អ្នកទាំងនេះនឹងរួមគំនិតគ្នាឲ្យសេចក្ដីណែនាំដល់រដ្ឋាភិបាលឥណ្ឌា ក្នុងគ្រោងការកសាងកន្លែងផលិតដែកថែបមួយកន្លែងថ្មីទៀតក្នុងប្រទេសនេះ ។ សូវៀតបានព្រមព្រៀងនឹងបញ្ជូនគ្រឿងចក្រ ព្រមទាំងឧបករណ៍ផ្សេងៗសម្រាប់គ្រោងការកសាងនេះ ។

វិទ្យុដេល្ហីបន្ថែមសេចក្ដីថា កន្លែងផលិតនេះនឹងបញ្ចេញដែកថែប៥០០.០០០តោន ក្នុងរយៈឆ្នាំផ្ដើមដំបូង ៗ វិទ្យុឥណ្ឌាថា វិស្វករទាំងនេះគឺបានអញ្ជើញមកតាមពាក្យសុំនៃរដ្ឋាភិបាលទាំងអស់ ។

គេចាំបានថា ឥណ្ឌាបានពឹងពាក់វិស្វករអាល្លឺម៉ង់រួចជាមុនហើយ ថែមទាំងកំពុងតែពិនិត្យពាក្យសុំរបស់អង់គ្លេស ដែលសន្យាថានឹងជួយក្នុងកិច្ចការនេះមួយកន្លែងទៀតផង ។

★ ★ ★

នៅស្រុកបាកាអាបាំង កាត់ខាងជើងនៃម៉ាឡាយូ កាលពីថ្ងៃទី ១៨–១១–៥៤ មានកន្ត្ដិបពីរពួក, គឺពួកមួយពណ៌ស្ករនៅក្នុងទឹក, មួយទៀតពណ៌ខ្មៅមកលើគោករួមទាំងអស់ច្រើនរយ បានលើកទ័ពចូលតស៊ូយ៉ាងសម្បើម, ដោយមានសម្រែកអឺងកងហាក់ដូចជាមេទ័ពស្រែកបញ្ជា ។

ការតស៊ូនេះអស់រយៈវេលាមួយថ្ងៃពេញ មានខ្លះស្លាប់ ខ្លះរបួសពាសពេញបរិវេណតស៊ូ នៅកណ្ដាលពពួកប្រជាជន ដែលអញ្ជើញទៅឈរមើលជាច្រើនរូប ។

មានអ្នកជឿគ្រោះជាតនាំគ្នាវិចារណ៍ក្នុងទំនងមិនប្រពៃជាច្រើន ។

ក្នុងការតស៊ូនេះ ពួកពណ៌ស្ករបានដកទ័ពថយទៅវិញ ។

មហា សម-ម៉ន

# រឿងប្លែក

កើតនៅប្រទេសសេរី

គេឮថា មានបុរសម្នាក់ឈ្មោះព្រនាក់ ប្រពន្ធឈ្មោះនាង នាំនៅភូមិដែលគេមិនស្គាល់ ។ ប្ដីប្រពន្ធនេះបានកពប្រសប់គ្នា៣ឆ្នាំហើយគ្មានកូនសោះ ។

នាយព្រនាក់ជាមនុស្សមានទិស្ស័យហ៊ឺហាចូលចិត្តសប្បាយ ដែលគេហៅតាមពាក្យផ្សូរថាអ្នកស៊ីផក់,, ។ រាល់ថ្ងៃពេលចេញពីធ្វើការ នាយព្រនាក់មិនដែលទៅផ្ទះទេ ច្រើនតែដើរលេងត្រេតត្រតតាមប្រកល្អក



រៀនគោះផ្សេងៗ ចំពីនឹងបានដល់ផ្ទះ ម៉ោង៩ឬ១០ យប់ជានិច្ច ឯនាងនាំច្រើនតែចាំពេលបាយខក ៗ

ថ្ងៃមួយ នាយត្រនាក់អង្គុយធ្វើការនៅវេលា ព្រឹកដូចជាទឹកគប់ប្រមល់ក្នុងចិត្ត ក៏ធ្វៀតចេញក្នុង ពេលម៉ោងធ្វើការ ហើយជិះកង់សំដៅទៅកន្លែង តិយាខសត្វទទួលជួបយាយ ដើកដែលកំពុងដើរទៅ ផ្សារពេលនោះ នាយត្រនាក់ដូចជាទឹកឃើញរឿងអ្វី មួយហើយសួរយាយដើកថា

—អញ្ចើញទៅណាយាយ?

—ចាស! ទៅផ្សារចុះលោកអញ្ចើញទៅណាដែ?

—បាទ! ទេ! ខ្ញុំថាមករកយាយ តែបើបានជួប គ្រន់ហ្នឹងស្រួលហើយ !

—មានការអីឬលោក ?

—បាទ ! មាន បានជាមករកយាយ !

—មានការអីលោក? និយាយមកចុះ!

—មានការអី ! ការដូចថ្ងៃមុនអញ្ចឹង !

—ការអីថ្ងៃមុន ?

—អើរកឲ្យតែមួយមក! កុំនិយាយច្រើន!

—យកឥឡូវឬអី ?

—បាទ! យកឥឡូវហ្នឹង!

— យីមិនកើតទេលោក ស្ទើហ្នឹងមិនដឹងជាទៅណាអស់ហើយទេ ចាំល្ងាចបានទេលោក !

—អើ បើឥឡូវមិនបាន ល្ងាចក៏បាន.

—បើអញ្ចឹងម៉ោងប៉ុន្មានលោកអញ្ជើញមក ?

—ម៉ោង៦ កន្លះ !

—អើបើអញ្ចឹងល្ងាចសឹមអញ្ជើញមក ចាំខ្ញុំរកជូន-

— និយាយគ្នាបានតែប៉ុណ្ណោះនាយត្រនាក់ក៏លា យាយត្រឡប់ទៅធ្វើការវិញដោយការសង្ឃឹមទុកថា “ល្ងាចនេះអញហើយ”

— លុះថ្ងៃល្ងាចដល់ពេលម៉ោងដែលអ្នកទាំងពីរ សន្យាគ្នា នាយត្រនាក់ចេញពីកន្លែងធ្វើការជិះកង់ យ៉ាងលឿនសំដៅទៅទីតិយាខសត្វចូលទៅក្នុងតៀម ចិនរកក្អមស្រាហើយក៏ហួសចូល ទៅផ្ទះយាយដើក ពេលនោះយាយដើកឈរនៅមុខផ្ទះ លុះគ្រទៀត ឃើញនាយត្រនាក់ក៏និយាយថា

—យី ! លោកខ្ញុំនឹកថាលោកមិនមកតើ

—ខ្ញុំចូលទៅក្រុមសិនតើ! ម៉េចបានទេ ?

—ហុំ! គេយកចាំតាំងពីម៉ោង៦ម៉្លេះ! អញ្ជើញឡើងទៅ នៅក្នុងបន្ទប់ហ្នុះហ៎ !

នាយត្រនាក់ខំប្រញាប់ប្រញាល់ឡើងទៅលើផ្ទះ ទឹកមុខញញឹមគិតថា "ញញ់ហើយណាំនេះ" លុះបើកទ្វារចូលទៅក៏ស្រាប់តែឃើញនាងនាំនៅក្នុងបន្ទប់ប្រញឹម ៗ ។ ពេលនោះនាយត្រនាក់ខឹងពេកគ្មានបាននិយាយអ្វីមួយម៉ាត់សោះ ក៏ស្រាប់តែស្ទុះទៅចះកាំភ្លៀងផ្លូវថែមមួយដើមទៀត នាងនាំដួលទៅលើថ្ងឹក នាងស្រវាបានវាយត្រូវក្បាលនាយត្រនាក់បែកហូរឈាមស្រស្រាក់ ៗ ហើយអ្នកតាំងពីរចេះតែកាច់ប្រប្តាប់គ្នាចុះឡើងតួងតាងពេញផ្ទះ រហូតដល់ភ្ញើលគេឯងរត់មកមើលល្អូតរមិនយូរប៉ុន្មាន ស្រាប់តែមានគ្នាក់ការប៉ូលិសមកនាំយកអ្នកតាំងពីរទៅឃុំខ្លួនទុកអស់មួយយប់លុះព្រឹកឡើង សួរចម្លើយគូវាទតាំងសងខាងហើយក៏សម្រុះសម្រួលឲ្យបានស្រួលនឹងគ្នា តែអ្នកតាំងពីរមិនព្រមសូមឲ្យបញ្ជូនរឿងនេះទៅតុលាការ ។ ប៉ូលិសក៏បញ្ជូនរឿងនេះទៅ ឲ្យតុលាការកាត់សេចក្តី តុលាការក៏បានហៅខ្លួនអ្នកតាំងពីរនាក់ចូលទៅកាត់សេចក្តី ។ លោកចៅក្រមហ្នឹងគ្រាន់តែបានក្រឡេកឃើញរូបនាងនាំ ក៏ដូចជាព្រឺកក្នុងចិត្តព្រួចការៀងលែងគ្នានេះស្ទុះតែមិនបានការ ហើយកសួរទៅនាយត្រនាក់ថា :

—ម្តេចអាឯង រឿងយ៉ាងម៉េចខ្លះ ?

—ប្របាទម្ចាស់ ប្រពន្ធខ្ញុំវាក្បត់ខ្ញុំ ខ្ញុំខឹងពេកគ្រាន់តែវាយវាមួយដៃវាវាយខ្ញុំមួយថ្ងឹកបែកក្បាល

—ចៅហ្វាយសួរទៅនាងទៀតថា :

—ម៉េចនាងឯងក្បត់ដូចពាក្យគេថាមែនទេ?

—ចាស! ប្តីខ្ញុំមានស្រី ហើយវាយខ្ញុំទៀត!

—ប្របាទ ខ្ញុំបាទគ្មានស្រីឯណាទេ !

—ចាស ខ្ញុំក៏គ្មានក្បត់ ឯណាដែរ !

—បើឯងមិនក្បត់ ម៉េចក៏ទៅនៅលើផ្ទះយាយដើក

ន. ចុះបើឯងគ្មានស្រី ម៉េចក៏ទៅលេងលើផ្ទះយាយដើក?

ច. យើ! ចុះរឿងនេះម៉េចចេះ ត្រនាក់ឯងនិយាយឲ្យយើងស្តាប់តាំងពីដើមសិនមើល

ត្រ. សូមក្រាបប្រសាសន៍ព្រះតេជគុណបានជាខ្ញុំបាទដឹងជាក់ថាប្រពន្ធខ្ញុំមានចិត្តក្បត់ ព្រោះថាពីព្រឹកមិញលមែ្ម ខ្ញុំបាទបានពឹងយាយដើកឲ្យរកស្រីម្នាក់ឲ្យខ្ញុំបាទ លុះខ្ញុំបាទទៅដល់យាយដើកបានប្រាប់ថារកបានហើយឥឡូវនៅក្នុងបន្ទប់ លុះខ្ញុំបាទចូលទៅឃើញប្រពន្ធខ្ញុំនៅក្នុងបន្ទប់នោះ ហេតុនេះសូមព្រះតេជៈគុណមេត្តាថ្លឹងរកសេចក្តីយុត្តិធម៌ឲ្យទានតើមានច្បាប់ដូច្នេះដែរឬ ? បើប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍ពេញទីហើយ ទៅប្រព្រឹត្តអាក្រក់ដូច្នេះ បើប្រ-

សិនណាជាស្រីល្អជាង មុនជាយាយដើកទៅហៅមក ឲ្យប្រុសមិនបានអញ្ចឹងទេ!

ច– អើ! មេះនាងឯង នាងឯងបែបមិនស្រួល ហើយ ដូចពាក្យគេថាមែនទេ?

ន– ចាសទេ! មិនមែនទេ!

ច– យ! ចុះនាងឯងនៅប្រកែកអីទៀត!

ក– ចាស! បានជាខ្ញុំនៅប្រកែកព្រោះថា ព ថៃយាយដើកទៅប្រាប់ខ្ញុំថា មានលោកម្នាក់ពាក់ទៅគាត់ចាប មាត់ប្រាប់ពាក់ពិលចង់ជួបនឹងខ្ញុំ បានជាខ្ញុំទៅចាំជួប លុះខ្ញុំចាំជួបស្រាកទៅបែត ឃើញប្ដីខ្ញុំមក បានជាខ្ញុំដឹងជាក់ថា ប្ដីខ្ញុំមានសំបុត្រអាពាហ៍ពិពាហ៍ពេញច្បាប់នៅឡើតដើរលេងមានស្រីញីទៀត ហេតុនេះ សូមព្រះតេជៈគុណមេត្តាប្ដឹងរកសេចក្ដីយុត្តិធម៌ឲ្យខ្ញុំផងកុំឲ្យលំអៀង ឲ្យស្មើទៅតាមពាក្យថាតុលាការ –

ច–យី! នាងឯងឆ្កួតឬអី បានជានិយាយអញ្ចឹង?

ក–ចាស! ស្រីប្រហែលខ្ញុំមិនមែនឆ្កួតទេ!

ច–អើហ្ន! មីនេះមាត់រឹងមែន នាងឯងធ្វើប្រពន្ធគេ មានសំបុត្រអាពាហ៍ពិពាហ៍ពេញច្បាប់ហើយ ដើររកលុយអញ្ចឹងទៀត នាងឯងឆ្កួតឬអី? បើឆ្កួតទេ គេនឹងយកទៅដាក់ព្រែកក្នាត

ន-ព្រះតេជព្រះគុណ! ខ្ញុំមិនឆ្កួតទេ បើប្ដីខ្ញុំនោះល្មម ព្រះតេជគុណឲ្យទៅព្រែកក្នាតមែន! ព្រោះមានប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍ហើយមិនគិតយកប្រាក់ទៅឲ្យប្រពន្ធ បែរជាយកប្រាក់ទៅឲ្យស្រី-ញីតែផ្ដេសផ្ដាសទៅវិញ ។

ច. ខុះគេប្រុស!

ន- ខុះខ្ញុំជាស្រី!

ច- មីចង្កូត! នាងឯងនិយាយផ្ដេសផ្ដាសមែន មិនដឹងទេឬអី? ស្រីនឹងប្រុសខុសគ្នាឆ្ងាយណាស់ - ប្រុសគេចង់យកប្រពន្ធប៉ុន្មានក៏ដោយ ស្រេចនៅលើគេមិនឃើញទេឬអី? ក្នុងសំបុត្រអាពាហ៍ពិពាហ៍គេសរសេរបំហារទុកថា: ប្រពន្ធទី... បើ ១ គេដាក់ថាទី១ទៅ បើ ២ គេដាក់បន្ថែមថាទី ២ ទៅ ។ល។ ចុះឯងស្រីចង់ធ្វើតាមគេប្រុសដែរ? មិនបានទេត្រូវមានទោស ។

ន- ទោសយ៉ាងម៉េចទៅទានប្រោស?

ច- ទោសដាក់គុក!

ន- បើអញ្ចឹង គុកដាក់តែស្រី ៗ ទេឬទានប្រោស?

ច- ដាក់ទាំងអស់ តែពេលនេះនាងឯងផិតប្ដី ត្រូវដាក់នាងឯង –

ន- បើដាក់ទាំងអស់ ទាំងប្រុសទាំងស្រីអញ្ចឹង ម៉េចក៏មិនដាក់ប្រុសក្នុងរឿងប្រុសផិតប្រពន្ធផង!

ច- ថាប្រុសនឹងស្រីខុសគ្នា!

ន. ខុសគ្នាយ៉ាងម៉េច មនុស្សដូចៗគ្នា ប្លែកគ្នាតែភេទប៉ុណ្ណោះ ឯដៃជើងមុខមាត់ក្ដីក៏គ្រប់មាន ខុសគ្នាឯណា ត្រូវគ្នាទាំងអស់ គួរតែដាក់ប្រុសមុនទើបសម !

ច- យី ! ចុះនៅប្រកែកយ៉ាងម៉េចទៀត មិនឮទេអី ? គេថា មួយប្រុស មួយស្រី !

ន- បាស ! ខ្ញុំឮច្បាស់ណាស់ហើយ តែនៅឆ្ងល់ថា ចុះហេតុអ្វីបានជាខុសគ្នាអញ្ចឹង ស្រីមិនមែនមនុស្សទេឬអី ?

ច មនុស្សដូចគ្នាមែន តែច្បាប់គេអញ្ចឹងឲ្យធ្វើម៉េច ?

ន. ច្បាប់ត្រង់ហ្នឹងខ្ញុំមិនពេញចិត្តសោះ ដូចជាល្អៀងកាន់ជើងខាងប្រុស!

ច- យី ! នាងឯងមើលងាយច្បាប់ ! បើមិនពេញចិត្តក៏តែម្នាក់ឯងនៅ !

ន·បាស! ការនេះជាធម្មតាទេខ្ញុំគ្រាន់តែថាទេតើ

ច- បើមិនមើលងាយទេ កុំនិយាយអញ្ចឹងព្រោះជាច្បាប់មួយៗ មានគណៈកម្មការគេពិនិត្យដោយត្រឹមត្រូវណាស់ មិនមែនធ្វើលេងទេ ហើយច្បាប់នេះគេបានអនុវត្តន៍ប្រើតាំងពីយូរយារណាស់មកហើយ

ន- គេធ្វើត្រឹមត្រូវហើយ តែត្រឹមត្រូវខាងប្រុសៗខុសឯខាងស្រីៗ ព្រោះគណៈកម្មការអស់នោះសុទ្ធតែប្រុស ម្ល៉ោះហើយធ្វើតម្រូវតែចិត្តខាងខ្លួន មិនគិតដល់ចិត្តគេផង ៗ ខ្ញុំក៏ដឹងថា គេមិនធ្វើលេងដែរ គឺគេធ្វើមែនទែន តែគេចង់បំពាក់យ៉ាងម៉េចឲ្យខាងប្រុស ៗ សប្បាយព្រោះគេធ្វើតែប្រុសគ្នាគេ គ្មានហៅស្រីទៅធ្វើគណៈកម្មការផងសោះ ៗ

ច- យី ! មីនេះមាត់រឹងមែន បើប្រទេសកាន់អំណាចផ្ដាច់ការវិញអញឲ្យប៉ូលិសទះកំភ្លៀងពីរបីដៃ តែទាស់ស្រុកឥឡូវកាន់អំណាចប្រជាធិបតេយ្យវាលំ-បាកបន្តិចព្រោះមានហាមមិនឲ្យវាយតប់អីសោះ ដល់អញ្ចឹងទៅនាំឲ្យវាបានចិត្តហើយនាំឲ្យលំបាកធ្វើការ ៗ

ន-បាស! អញ្ចឹងមែនហើយ ស្រុកពីដើមកាលព្រះតេជៈព្រះគុណនៅធ្វើចៅហ្វាយជនបរទេសស្រួលធ្វើការមែន ដល់ឥឡូវស្រុកស្ថិតនៅក្នុងច្បាប់ប្រជាធិបតេយ្យនាំឲ្យលំបាកធ្វើការវិញតើ!

ច· អើ ! វាដូចនាងឯងអញ្ចឹង បានគេបណ្ដោយបន្តិច រឹតតែគ្រាន់បើឡើង វាបានតែដាក់ធម៌ក្ដៅបានស្រួល ឆាប់បាត់មាត់!

ន . ព្រោះតេជព្រះគុណបែបចូលចិត្តតែធម៌ក្ដៅតាមសម័យដែលធ្វើចៅហ្វាយបរទេសណាស់ហ្ន៎! មិនចូលចិត្តតាមរបៀបប្រជាធិបតេយ្យសោះ!

ច - អើ! អញ្ចឹងហើយ ! ប្រជាធិបតេយ្យរឹតតែលំបាកឡើង ព្រោះមនុស្សមិនស្គាល់ដម្លៃ មានមាត់បេះតែថា —

ន · អញ្ចឹងហើយតើព្រះតេជព្រះគុណ ! ប្រជាធិបតេយ្យមានសិទ្ធិក្នុងការនិយាយស្តី !

ប- អើ៎ ! និយាយស្តីតើអញ្ចឹង !

ន . មិនមែនដូចព្រះតេជគុណមានប្រសាសន៍ទេ គឺនិយាយត្រូវៗ ! ព្រោះថារឿងនេះ គួរតែរដ្ឋាភិបាល ធ្វើច្បាប់ហាមប្រុស ៗ កុំឲ្យយកប្រពន្ធច្រើនពេក គឺឲ្យមានតែមួយនឹងមួយបានហើយដើម្បីនឹងឲ្យស្រប ទៅតាមអារ្យប្រទេសនានា ហើយការដែលនឹងតែងតាំងច្បាប់ឡើង ក៏គួរឲ្យមានគណៈកម្មការស្រីមានចំណែកចូលទៅប្រជុំធ្វើផង ដើម្បីនឹងថ្លឹងនូវទម្ងន់ នៃទឹកចិត្តស្រីនឹងប្រុសឲ្យបានស្មើគ្នា ចុះបើយកតែម្ខាង ទៅធ្វើដូច្នេះ ធ្វើម្តេចនឹងបានដឹងទឹកចិត្តនៃអ្នកម្ខាងទៀត ធ្វើដូច្នេះទើបសមទៅតាមហេតុផលនឹងសមទៅតាមឋានៈនៃប្រទេសឯករាជ្យកាន់លទ្ធិប្រជាធិបតេយ្យ ព្រោះថាពាក្យថាឯករាជ្យនេះមិនមែនឯករាជ្យតែម្នាក់ៗ មួយក្រុមៗ មួយពួកៗ ឬតែប្រុសៗទេ គឺឯករាជ្យទូទៅ ក្នុងព្រំដែនទាំងមូល រហូតដល់ស្រីៗ ក៏ឯករាជ្យនឹងគេដែរ តែស្ត្រីដូចជាគ្នាគេកប់រកសោះ !

ចំពោះសិទ្ធិនៃស្រីៗ ការតាំងនេះគួរតែរដ្ឋាភិបាលបើកសិទ្ធិឲ្យស្រីៗ ឲ្យបានស្មើមុខនឹងប្រុស ទើបសម ដូចយ៉ាងសិទ្ធិបោះឆ្នោត សិទ្ធិជាបេក្ខជន ឲ្យគេបោះឆ្នោតឲ្យជាដើមៗ ការដែលខ្ញុំនិយាយនេះ គឺសរឲ្យឃើញថា ស្រីនឹងប្រុសជាមនុស្សដូចគ្នាត្រូវតែមានសិទ្ធិស្មើគ្នា បើមានច្បាប់ហាមប្រាមកុំឲ្យ-ប្រុសយកប្រពន្ធច្រើនដែរទើបសម

ប- យី ! នាងឯងចេះតែនិយាយផ្តេសផ្តាស ម្តេចអញ្ចឹង - មិនឮទេឬអី ? គេថាប្រុស ១ ក៏ផ្សេងគ្នាពីស្រី? ហើយឯងស្រីគេយកទៅធ្វើអីកើត , មិនដែលមានស្រីណាបានជាផះអីទេ -

ន- ចាស - មិនផ្តេសផ្តាសទេ ! និយាយ - ត្រូវ - ព្រះតេជព្រះគុណកុំអាលថាដូច្នេះមិនសមទេ ស្រីគេប្រើការបានដែរតើ ព្រះតេជព្រះគុណ មិន-ដែលបានដឹងទេឬអី អេលីហ្សាបែត ទីពីរ ស្តេចអង់គ្លេស សព្វថ្ងៃប្រុសឬស្រី ?

ប- តាំងហ្វាងដូចជាតល់គំនិត ក៏និយាយបែបស្រួលវិញថា យី ! ត្រង់នេះ ខ្ញុំមិនដឹងដែរ បើច្បាប់គេចែងថាអញ្ចឹងទៅហើយ ?

ន. ខ្ញុំក៏មិនថាអីព្រះតេជព្រះគុណដែរ គ្រាន់តែសូមរំលឹកថា ព្រះតេជព្រះគុណជាអ្នកកាន់កាប់ក្នុងផ្នែកតុលាការនេះ គួរតែរិះរកធ្វើយ៉ាងម៉េចឲ្យបានសិទ្ធិស្មើគ្នាប៉ុណ្ណោះ បើចេះតែបណ្តោយថា ច្បាប់គ្មានចែង ម៉េចកើត ៗ ដូចយ៉ាងច្បាប់ត្រង់កន្លែងនេះ ខ្ញុំក៏ដឹងអញ្ចឹងដែរ តែការដែលខ្ញុំនិយាយនេះគ្រាន់ តែចង់សុំដែងហេតុផល

ប — និយាយបែបនាងឯងគួរតែកែច្បាប់ តែកែម៉េចកើត បើគេធ្វើរួចអស់ទៅហើយ ៗ

ន- អម្បាលយ៉ាងវេទនាមនុញ្ញពេញ គេចង់កែគង់តែកែកើតសព្វបើប៉ុណ្ណឹងកែមិនកើត? មនុស្សធ្វើច្បាប់មនុស្សអាចកែច្បាប់បាន ព្រោះថាច្បាប់គេធ្វើតម្រូវទៅតាមចិត្តមនុស្សនឹងសម័យ ចុះបើសម័យឥឡូវមនុស្សខុសពីសម័យបុរាណ ហើយមានចិត្តគំនិត ក៏គាន់តែដើរទៅរកសេចក្ដីចម្រើន ហើយម៉េចក៏មិនកែសម្រួលទម្រង់ច្បាប់នោះឲ្យដើរទៅតាមសម័យនឹងគេផង " បាន-ហ្មងដកដង្ហើមធំស្ទើរហឹៗ ហើយនិយាយថា ហុះ ! ខ្ញុំដូចជាតាល់ច្រាល ហើយបើអញ្ចឹងឯងចាំងពារនាក់ទៅសិនះចុះចាំខ្ញុំគិតមើលហេតុផលសិន ព្រោះប្រទេសយើង កាន់ព្រះពុទ្ធសាសនាដោយពេញលក្ខណៈ តែបើនិយាយតាមច្បាប់ព្រះពុទ្ធសាសនាវិញគេថា - ស្ត្រីជាហីនភាពគឺភាពថោកថយ ជាតិស្រីមិនដែលកសាងខ្លួនជាមនុស្សអស្ចារ្យបានទេ ដូចជាការកំសាងជាព្រះពុទ្ធ ឬស្ដេចចក្រមិនដែលស្ត្រីឯណាកសាងបានឡើយ នាងឯងនិយាយនេះត្រូវមែនតែត្រូវតែច្បាប់ផ្លូវលោកខុសច្បាប់ព្រះពុទ្ធសាសនា

សួន-សុរិទ្ធ

---

អសុក វិហារ (ASOKA VIHARA)
មេហារលី (MEHRAULI)
ដេល្លី (DELHI)
ឥណ្ឌៀ (INDIA)

ថ្ងៃទី ៣១ ធ្នូ ២៤៩៧

សូមចំរើនពរមក លោកអធិបតីសមាគមមិត្ត-សាលាបាលី សូមជ្រាប ។

សំបុត្រលោកចុះថ្ងៃទី ៧ ខែតុលា ២៤៩៧ ជាប់ជាមួយនឹងទស្សនាវដ្ដី៨លេខនោះ អាត្មាភាពបានទទួលហើយដោយត្រេកអរ ។ បន្តិចមកលោកវិញឲ្យបានឆាប់ដែរក្នុងពេលដែលបានទទួលហើយនោះ តែដោយរវល់នឹងការរៀនសូត្រខ្លាំងក្នុងខែមុនៗ នោះ អាត្មាភាពបានផ្ញើជាប់មកជាមួយនឹងសំបុត្រនេះ នូវអត្ថបទជាបកិណ្ណកប្បរិយាយនឹងសេចក្ដីកែតម្រូវអត្ថបទចាស់ ដែលមានការភ្ញាក់ភ្ញាំងបន្តិចបន្តួច ៗ ឯដទៃទៀតមិនជាអ្វី ពោះបើសេចក្ដីមិនទាន់បង្ខំឲ្យអស់ដៃអស់ជើង ៗ

តទៅមុខទៀត បើទុកជាលោកដឹងថាអាត្មាភាពមិននៅទីនោះទេ ក៏សូមផ្ញើទស្សនាវដ្ដីមកទីនេះដែរ អ្នកនៅទីនោះនឹងផ្ញើត្រឡប់ទៅឲ្យអាត្មាភាពទៀត ៗ

សង្ឃឹមថា លោកសមាជិកទាំងអស់បានសុខសប្បាយ ព្រមទាំងកិច្ចការក្នុងសមាគមក៏បានចំរើនជាលំដាប់ ៗ

ដោយសព្វោគនាដ៏ពិសេស

ភិក្ខុ គួច-គីឡេង (បិតប្បញ្ញោ)

# បកិណ្ណកប្បរិយាយ

*កុលបុត្រផុះឡើងដោយញាណសម្បយុត្ត*

កាលពីថ្ងៃទី ១៣ ខែតុលា ព-ស ២៤៩៧ មានជាតិស៊្វីដែន (Sweden) (១) ពីរនាក់ប្ដីប្រពន្ធ ឈ្មោះលោកនិងអ្នកស្រី ក-ហ-វេគ្នេរ (K.H.Wagner) បានថ្វាយខ្លួនជាពុទ្ធសាសនិកនៅវត្តអានន្ទកុដិ ក្រុងកដ្មណ្ឌុ ប្រទេសនេប៉ាល ។ ពេលនោះប្រជាជនជាតិនេប៉ាលស្រីប្រុសច្រើនគ្នា បានទៅជួយអបអរសាទរនិងកិច្ចដង្ហែកនៃអ្នកទាំងពីរនោះផង ។ លុះអ្នកទាំងពីរបានប្រកាសខ្លួនក្នុងជំនុំសង្ឃ និងប្រជាជនរួចហើយ ព្រះថេរៈអមតានន្ទ បានឲ្យត្រៃសរណគមន៍ និងបញ្ចសីលហើយថ្លែងសេចក្ដីបន្តិចអំពីព្រះពុទ្ធសាសនាឲ្យអ្នកទាំងពីរនោះស្ដាប់ លោក ក-ហ-វេគ្នេរ កាលបើបានស្ដាប់ឱវាទទេសនានៃព្រះថេរៈអមតានន្ទហើយ ក៏

(១) ពាក្យថា (Sweden) នេះ គឺជាឈ្មោះរបស់ប្រទេស មិនមែនសម្រាប់ហៅមនុស្សឬភាសាទេ តែបើហៅឲ្យត្រូវតាមភាសាអង់គ្លេសថា (swedeish) ។ ប៉ុន្តែភាសាខ្មែរយើង មិនចាំបាច់ហៅទេ ថាតែ (Sweden) ប៉ុណ្ណោះក៏ហើយការ បានទាំងអស់ ពីទាំងប្រទេស, ទាំងភាសា ។ ដូច្នេះយើងត្រូវនិយាយថា " ប្រទេសស៊្វីដែន, ជាតិស៊្វីដែន; ភាសាស៊្វីដែន មិនចាំបាច់និយាយថា ប្រទេសស៊្វីដែន, ជាតិស៊្វីឌិស្ហ, ភាសាស៊្វីឌិស្ហទៀតទេ ដើម្បីបញ្ជាក់សេចក្ដីនេះឲ្យរឹតតែច្បាស់ឡើង សុំលើកយកឧទាហរណ៍ខ្លះ មកទៀត ដូចជា១-បារាំង,២ - អង់គ្លេស; ៣ - ភូមា; ៤ - ហិណ្ឌូ;៥ - អាមេរិក; ៦ - ខ្មែរ ; ៧- ចិនជាដើម គេនិយាយថា ១ - ប្រទេសបារាំង ; ២ - ប្រទេសអង់គ្លេស ; ជាតិអង់គ្លេស ; ៣ - ប្រទេសភូមា ; ជាតិភូមា ; ៤ - ប្រទេសហិណ្ឌូ ; ជាតិហិណ្ឌូ ; ភាសាហិណ្ឌូ ៥ - ប្រទេសអាមេរិក; ជាតិអាមេរិក; ភាសាអាមេរិក; ៦ - ប្រទេសខ្មែរ; ជាតិខ្មែរ; ភាសាខ្មែរ; ៧ - ប្រទេសចិន; ជាតិចិន ភាសាចិន; មិនចាំបាច់និយាយថា ១ - ប្រទេសបារាំង; ជាតិបារាំងសែស; ភាសាបារាំងសែស; ២ - ប្រទេសអេនគ្លង់ (England) ជាតិអ៊ិង្គលិស្ហ; ភាសាអ៊ិង្គលិស្ហ; (English) (ល) ។

៧ - ប្រទេសចិន (China) ជាតិឆៃនីហ្ស៍ ភាសាឆៃនីហ្ស៍ (Chinese) ដូច្នេះទេ ព្រោះភាសាខ្មែរយើងមិនមានការប្រែរឹង នឹងប្រើបច្ច័យវិភត្តិ, លិង្គ, វចនៈជាដើមគ្រប់កាលទាំងពួង ដូចជាភាសាបាលី, សំស្ក្រឹត, បារាំង, អង់គ្លេស, ហិណ្ឌូ ឡើយ វៀរតែពាក្យណាដែលចេញមកពីបាលី ។ សេចក្ដីពន្យល់មកនេះ គឺតាមយោបល់របស់ខ្ញុំព្រះករុណាអាត្មាភាព ដែលបានពិចារណាមកហើយ ជាផ្លូវនៃសេចក្ដីរិះរកនៃអ្នកប្រាជ្ញទាំងឡាយផង ។ ម្យ៉ាងទៀត បើមិនអនុវត្តន៍ហៅដូច្នេះទេ ការណ៍នឹងត្រឡប់ទៅជាសេចក្ដីលំបាកលំបិន នៃអ្នករៀនភាសាផ្សេង ៗ គ្នា ក្នុងកាលជាអនាគត ។ មិនតែប៉ុណ្ណោះសោតភាសាខ្មែរយើងនឹងនៅមិនគ្រប់គ្រាន់ដដែល ។ ក្នុងទ្រឹស្ដីនៃអធិការដំស្របគ្នានេះ យើងគួរនឹកដល់ពាក្យយើងថា តែ, បារាំងថា. តេ (Thé) ចិនក៏ថា តេដែរ អង់គ្លេសថា ធី (Téa) យើងថា. សាប៊ូ, បារាំងថា សាវ៉ុង (Savon), យួនថា សាប៉ុង; ហិណ្ឌូថា សាប៊ុន, យើងថា កាហ្វេ បារាំងថា កាហ្វេ (Café) អង់គ្លេសថាកហ្វី (Coffée) យើងថា យីពុន, បារាំងថា ជប៉ុន (Japon); អង់គ្លេសថា ជប៉ាន (Japan), យើងថា ហិណ្ឌូ; បារាំងថាអាំងឌ៍ (Inde) អង់គ្លេសថា ឥណ្ឌា (India), ប៉ុណ្ណោះ ជាដើម ។ បើយើងមិនអនុញ្ញាតមាត់យើងឲ្យហៅផ្សេង ៗ ពីគ្នាដូច្នេះទេ នោះយើងនឹងប្រាកដជាមិនដឹងសោះថា " តើខ្មែរនៅត្រង់ណា ? បារាំងនៅត្រង់ណា? អង់គ្លេសនៅត្រង់ណា ? អ្នកណានៅត្រង់ណា? ជាប្រាកដពុំបានឡើយ ព្រោះថា „ភាសា" ប្រែថា „ ការពោល និយាយស្ដី ហៅ ចរចារ បញ្ចេញសម្លេង" បន្ទំវាចា, បើយើងមិនពោល . . . (ល) បន្ទំវាចាទេ ការនេះមិនទៅជាភាសាឡើយ ។ អ្នកអក្សរសាស្ត្រ អ្នកប្រវត្តិសាស្ត្រគេស្រួលអាចយល់បានដោយងាយនូវរឿងឯចិត ៗ ។

ក្រោកឈរនិយាយទៅកាន់ប្រជុំជនថា "តើព្រោះហេតុអ្វី បានជាខ្ញុំទាំងពីរនាក់ចេញអំពីប្រទេសកំណើតរបស់ខ្លួន ហើយមកត្រឡប់ជាពុទ្ធសាសនិកនៅទីនេះ បញ្ហានេះខ្ញុំមិនចាំបាច់ដោះស្រាយដោយខ្លួនឯងទេ សូមផ្ញើលើអស់លោកអ្នក ប៉ុន្តែខ្ញុំគ្រាន់តែសូមជំរាបអស់លោកមួយឃ្លាថា « សាសនាដែលនាំសត្វណាឲ្យឃើញនូវសច្ចធម៌ពិត ៗ ឲ្យបានទទួលនូវបញ្ញាជាលោកិយនិងលោកុត្តរ, ឲ្យប្រាសចាកសេចក្ដីកំណាញ់, ឲ្យប្រកបដោយព្រហ្មវិហារធម៌—មេត្តា, ករុណា, មុទិតា, ឧបេក្ខា សាសនានោះគឺសាសនានៃព្រះលោកនាថជាម្ចាស់ហ្នឹងឯង (២) ។

លោកនិងអ្នកស្រីទាំងពីរនេះ ក៏បានជួបអាត្មាភាពដើរនៅឃុំសារនាថ ស្រុកពារាណសី កាលពីខែមេសាមុននេះ ។ អាត្មាភាពបានសួរដំណើរទំនងគាត់រួចហើយ គាត់ប្រមានប្រសាសន៍ប្រាប់ថា ភន្តេ ខ្ញុំព្រះករុណាបានចេញពីស្រុកទេសខ្លួនមកដើម្បីស្វែងរកព្រះពុទ្ធសាសនានៅទិសខាងកើតព្រោះខ្ញុំថាព្រះពុទ្ធបានកើតឡើងនៅ ប្រទេសនេប៉ាល បានត្រាស់ដឹងសព្វញ្ញុតញ្ញាណនៅជម្ពូទ្វីប ហើយការប្រៀនប្រដៅរបស់ព្រះអង្គនោះ ក៏រុងរឿងណាស់នៅអាស៊ីទ្វីបនោះ ។ នៅប្រទេសខ្ញុំព្រះករុណាគ្មានអ្នកកាន់ព្រះពុទ្ធសាសនាទេ មានតែខ្ញុំព្រះករុណាពីរនាក់ប្ដីប្រពន្ធនេះឯង ចេញពីប្រទេសខ្លួនមុនគេបង្អស់ ព្រោះតែហេតុព្រះនៃសាសនាបានដឹងព្រះពុទ្ធសាសនាគួរសមដែរ ដោយការអានទស្សនាវដ្ដីផ្សេង ៗ ។ ឥឡូវខ្ញុំព្រះករុណាដើរនមស្ការបូជនីយដ្ឋានក្នុងជម្ពូទ្វីបនេះរួចស្រេច ហើយនឹងនាំគ្នាទៅនេប៉ាល់ទៀត ទៅសិក្សាព្រះពុទ្ធសាសនានៅទីនោះឯង ។ ខ្ញុំព្រះករុណារីករាយណាស់ ដោយបានជួបនឹងព្រះតេជព្រះគុណ ជាជាតិខ្មែរមុនគេបង្អស់ „ ។ អាត្មាភាពជំរាបគាត់ទៅវិញថា "អាត្មាក៏រីករាយដែរ ដោយបានជួបនឹងលោកជាជាតិស្វ៊ីឌុនលើកដំបូងនេះ ហេតុដែលបណ្ដាលឲ្យយើងជួបគ្នានៅទីនេះ ព្រោះយើងសុទ្ធតែជាមនុស្សដំបូងទាំងអស់គ្នា" ។ គាត់ញញឹមហើយអាត្មាភាពនិយាយតទៅទៀតថា "នេះជាឧបនិស្ស័យរបស់លោកដែលបានមកជួបព្រះពុទ្ធសាសនាដោយការគាត់ ស្វែងរកមកឆ្ងាយដល់ម្ល៉េះ ។ បើសិនណាជាលោកប្រាសចាកបញ្ញាជាញាណសម្បយុត្ត លោកមិនបានមកជួបទេ សូម្បីគ្រាន់តែខ្ញុំឮថាអាត្មាភាពមកពីប្រទេសកម្ពុជា ក៏មិនឮផង" ។

X

X X

យី ! គ្មានមួយសេននៅហោប៉ៅសោះ

កាលពីថ្ងៃចន្ទទី ២២ វិច្ឆិកា ២៤៩៧ ពេលថ្ងៃរសៀលមានការលេងមហោស្រពនៅក្រុងដេល្ហី, ពេលនោះអគ្គមហាបណ្ឌិតរាជេន្ទ្រប្រសាទ ( Dr.

២ ប្រែពីទស្សនាវដ្ដីមហាពោធិសមាគមឆ្នាំទី ៦២ លេខ១០ ខែតុលា ព ស ២៤៩៧ ។

Rejendra Prasad ) ប្រធានាធិបតីសាធារណរដ្ឋជម្ពូទ្វីប បានថ្លែងបាឋកថាយ៉ាងក្បោះក្បាយដល់ប្រជុំជនដែលមាននាម៉ឺនសព្វមុខមន្ត្រីតូចធំកំពុងស្ដាប់ដើម្បីបើកពិធីមហោស្រពប្រចាំឆ្នាំរបស់ប្រជាជាតិ ។ លុះចប់បាឋកថានៃប្រធានាធិបតីហើយ លោកនេហ្រ៊ូ នាយករដ្ឋមន្ត្រីក្រោកពីកៅអីស្ទុះទៅចាប់ឧគ្ឃោសនសព្ទ និយាយបញ្ចេញមនោសញ្ចេតនារបស់ខ្លួនឲ្យប្រជាជនស្ដាប់ អំពីសេចក្ដីជាប់ចិត្តនឹងទំនៀមទំលាប់ដ៏ល្អនៃជាតិនេះថា « ទំនៀមទំលាប់របស់ជាតិក្ដី កេរ្តិ៍ដំណែលរបស់ប្រទេសក្ដីដែលល្អ ៗ ឬរៀបរយ ឬអ្វីក្ដីដែលកើតឡើង ដោយស្នាដៃនៃបុព្វបុរសរបស់យើងទាំងឡាយ យើងត្រូវរក្សាការពារនូវកិច្ចទាំងឡាយនោះ ។ ទុកដោយខ្លួនឯង ព្រោះថាយើងហ្នឹងហើយដែលជាម្ចាស់ប្រទេស » ។ ហើយមានប្រសាសន៍បន្ថែមទៅទៀតថា “ ខ្ញុំសូមលើក - រង្វាន់ជូនអ្នកលេងរបាំទាំងឡាយ ” ។ ប្រជាជន , កាលបើការថ្លែងសេចក្ដីចប់សព្វគ្រប់អស់ហើយ ក៏ផ្ដើមសប្បាយរីករាយតទៅ ។ កាលដែលប្រជាជនកំពុងអង្គុយមើល-ស្ដាប់ ហើយរបាំក៏កំពុងតែប្រព្រឹត្តទៅដូច្នោះ លោកនេហ្រ៊ូ នឹងអគ្គមហាបណ្ឌិតកត្យូ ( Dr. KATYU ), រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏នាំគ្នាចេញមកខាងក្រៅ ដោយមិនឲ្យអ្នកណាដឹងសោះ ដើរចូលទៅផ្ទះផ្សារលក់តែតូចមួយ ដើម្បីពិសាតែ - មួយពែងម្នាក់ ។ ពេលនោះអ្នកលក់ក៏និយាយថាសូមអញ្ជើញលោកអង្គុយទៅ លោកត្រូវការអ្វីទឹកឬតែ ? លោកនេហ្រ៊ូ កាលបើអ្នកលក់គេសួរដូច្នេះហើយ ក៏ស្ទាបហោប៉ៅមើលមុខទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិយាយថា “ យី ! គ្មានមួយសេននៅហោប៉ៅសោះតែចង់តែ „ ហើយក៏នាំគ្នាចេញមកខាងក្រៅសញ្ចារទៅមើលប្រជាជនដែលកំពុងតែរីករាយក្នុងមហោស្រ-ពហើយចូលទៅអង្គុយកន្លែងដើមវិញ ។

X

X X

គួរឲ្យចង់អានឬទេ ?

ជាតិអ៊ឺរ៉ុបកំពុងតែទទួលប្រតិបត្តិតាមព្រះពុទ្ធ-សាសនា

កាលពីថ្ងៃទី ១៥ វិច្ឆិកា ២៤៩៧ មានព្រះថេរៈមួយអង្គ ជាតិអល្លឺម៉ង់ នាមកស្សបៈ បានមកដល់ទីក្រុងប៊ុំបេ ( Bombay ) មានថេរដីការទៅកាន់ទីប្រជុំជនក្នុងពេលនោះថា “ ព្រះពុទ្ធសាសនាដែលបានបំរើនជាលំដាប់លំដោយនៅក្នុងទ្វីបអ៊ឺរ៉ុបនោះ សព្វថ្ងៃនេះគេទុកដូចជាសាសនាសម្រាប់អ្នកប្រតិបត្តិមួយធំ - ពិសេសនឹងជាផ្លូវនៃការសិក្សារបៀបគតិវិជ្ជា Scientfic ព្រះថេរកស្សបៈ ដែលជាប្រធាននៃពុទ្ធិកសមាគមឈ្មោះ „ អរិយមេត្តេយ្យមណ្ឌល ” ក្នុងទ្វីបខាងលិចបានបន្តការនិយាយតទៅទៀតថា “ ព្រះពុទ្ធសាសនា រហូតមកដល់សម័យបច្ចុប្បន្ននេះបានបោល

ក្នុងក្រឡេកមើលលើដោយជាតិអឺរ៉ុបថាដូចជាគោលនៃទស្សនវិជ្ជា (Philosophy) ដែលអ្នកតក្កវិជ្ជាទាំង-ឡាយបានរៀនហើយប្រតិបត្តិ សម្រាប់ជីវិតរៀងៗខ្លួន ដើម្បីឲ្យដឹងតម្លៃនៃការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ ជាប់ប្រហែលជា៣០ឆ្នាំមកហើយ ជាតិអឺរ៉ុបបានសិក្សាព្រះពុទ្ធសាសនាទាំងទស្សនវិជ្ជាទាំងតក្កវិជ្ជាតាមទំនងនេះ ដើម្បីឲ្យឃើញនូវសច្ចធម៌ពិតៗមែន " ។ ព្រះកស្សបត្ថេរថា "ព្រះពុទ្ធសាសនាចេះតែចំរើនតាមលំដាប់នៅប្រទេ-សអល្លឺម៉ង់ភាគខាងលិច ។ សព្វថ្ងៃនៅទីក្រុងប៊ែរលិន (Berlin) មានពុទ្ធសាសនិកជន ២.០០០នាក់ហើយ ។ ឯនៅប្រទេសហុងគ្រី (Hungary) ក៏ព្រះពុទ្ធសាស-នាបានទទួលសេចក្តីចំរុងចំរើន ដូចនៅប្រទេសអល្លឺ-ម៉ង់ដែរ តែនៅប្រទេសដទៃទៀតទន់ខ្សោយណាស់ លើកលែងតែក្រុងឡុងដ៍ (London) ចេញដែលមានសមាគមខាងភាសាបាលី (Pali tezt Soeicty) និងពុទ្ធិកសមាគមមកជាយូរហើយនោះ " ។ ព្រះកស្សបត្ថេរថា: " តម្រូវទៅតាមអាកាសធាតុនៅអឺរ៉ុប ពិបាកនឹងប្រតិបត្តិឲ្យដូចជាលោកសង្ឃនៅអាស៊ីទ្វីបណាស់ ព្រោះត្រជាក់ហួសហេតុពេក ហេតុដូច្នេះបានជាលោកទាំងនេះមានការឃុំគ្រងផ្សេងៗ ពីគ្នាដើម្បីការពារត្រជាក់តាមបំណង់របស់ខ្លួន ។ សមាគមអាយមេត្តេយ្យមណ្ឌល ដែលបានប្រតិស្ឋាន២ឆ្នាំមកហើយនោះ គឺទុកដូចជា បេសកម្មផ្សាយព្រះពុទ្ធសាសនា, មានសាខាបែកចេញទៅតាំងនៅប្រទេសស្វ៊ីតហ្ស៊ែរលែនទ្ន (Switzerland) ប្រ៊ីតេន (Britain), បែលហ្ស៊ៀម (Belgium) ស៊្វីដែន (Sweden) ហុងគ្រី (Hungary) និងអាល្លឺម៉ង់ភាគខាងលិច (west germany) ។ សមាគមនោះនឹងរៀបចំឲ្យភិក្ខុស្លៀកពាក់តាមបែបតែមួយ កុំឲ្យពីសរពាស ទោះបីស្លៀកពាក់ដណ្តប់យ៉ាងណាក៏ដោយឲ្យតែបែបមួយ ។ នៅក្នុងទ្វីបអឺរ៉ុបទាំងមូលមានភិក្ខុ ២០០ រយអង្គហើយ (១) ។

ព្រះថេរៈកស្សបបានចេញពីប្រទេសរបស់ខ្លួនមកសិក្សាព្រះពុទ្ធសាសនា និងសាសនាហិណ្ឌូនៅជម្ពូទ្វីប១ឆ្នាំក្នុងឆ្នាំ ១៩៥១ហើយត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ។ ពេលនេះជាលើកទីពីរ ដែលបានមកកាន់ជម្ពូទ្វីប លោកនឹងញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅក្នុងជម្ពូទ្វីប ៦ខែ ហើយបន្ទាប់ពីនោះនឹងទៅលង្កាទ្វីបទៀត ។

X X

X

ខ្ញុំព្រះករុណាបានកែពាក្យនឹងសេចក្តីខ្លះនៃអត្ថបទចាស់ដូចតទៅនេះ

(១) ប្រែពីភាសាអង់គ្លេស ក្នុងកាសែតឈ្មោះ ជម្ពូទ្វីបសម័យ ផ្សាយចេញពីក្រុងដេលីថ្ងៃទី ១៦ វិច្ឆិកា ២៤៩៧

ពោធប្បទេស កែជា គោធប្បទេស ទំព័រ ១៦

គេន „ គេ ន „ ១៩

មនាវិញាណសាស្ត្រ „ មនោវិញ្ញាណសាស្ត្រ „ ៤៤

Citezen » Citizen »

Library » BooK shop »

ត្រង់នេះពាក្យថា “ Library ” នឹង “BooK shop” មានសេចក្ដីផ្សេងគ្នា ។

ភិក្ខុ គួប . គីឡេង ( ចិតប្បញ្ញោ )

ថ្ងៃទី ៣១ ខែធ្នូ ២៤៩៧

---



ព្រះពុទ្ធសាសនាប្រទេសកម្ពុជា កាន់តែឈានទៅមុខច្រើនជំហានណាស់ហើយ ពុទ្ធជនក្នុងកម្ពុជរដ្ឋត្រូវតែប្រឹងប្រែងគ្រប់គ្នាឡើង ដើម្បីរក្សាអនាគតសាសនារបស់ប្រទេស , ចំពោះភិក្ខុសាមណេរទាំងឡាយសូមប្រយ័ត្នតាមផ្លូវវិន័យឲ្យមែនទែន ជាការរក្សាផ្ទៃក្នុងសាសនា , គួរឲ្យពុទ្ធជនមានការទន្ទាក្នុងចិត្តយ៉ាង

ខ្ទាំង ដោយមានភិក្ខុសាមណេរគាត់ខ្លះ និមន្តចប្រប់ដោយប្រកបល្អកនៅទីផ្សារ នឹងកន្លែងខ្លះដែលជាទីសម្រេចកាមនៃជនពាល , តាមផ្លូវវិន័យមិនមែនហាមឃាត់កុំឲ្យដើរចុះឡើងតាមផ្សារនោះទេ តែជាការរក្សាសេចក្ដីរៀបរយនិងសមរម្យ ក៏គួរតែភិក្ខុសាមណេរពលអត្ត ប្រុងប្រយ័ត្នការនោះបន្តិចឡើង សូម្បីតែគង់សំណាក់នៃព្រះមហាថេរទាំងឡាយក៏គង់មានការហាមប្រាមដែរ ។

ការនេះខ្ញុំមិនមែនឃាត់ដំណើរ គង់គិតជាបរិក្ខា សំរាប់សិក្សានិងដំណើរដែលត្រូវនិមន្តទៅទីណា ។ ឡើយ គ្រាន់តែសុំឲ្យមានដំណើរនោះសមហេតុផល ល្អគួរជាទីចាប់ចិត្តដល់ជនបរទេសប៉ុណ្ណោះទេ . រឿងនេះខ្ញុំបានដឹងច្បាស់ថាជាបញ្ហាមួយដែលមានបកយូរ ហើយ មិនអាចនឹងដោះស្រាយដោយងាយ ៗ បានទេ សូម្បីនៅប្រទេសថៃ - ភូមាក៏គង់ជួបយ៉េងដែរ ការដោះស្រាយបញ្ហានេះ លុះត្រាតែប្រើវិយោវិច្ច ដែលមានការទំនុកបំរុងពីពពួកពុទ្ធជនគង់វង្ស ដោយយោបល់របស់សម្ដេចព្រះមហាសុមេធាធិបតី មានរដ្ឋាភិបាលជួយគាំទ្រផង ។

★ ★ ★

## សម័យសិទ្ធិរបស់មនុស្ស

ឮថា ស្ត្រីត្រូវមានសិទ្ធិស្មើនឹងបុរស ខ្ញុំសូមអំពាវនាវឲ្យសិទ្ធិនោះ បានសម្រេចយ៉ាងឆាប់សេពទាន់

កាលៈទេសៈនៃសម័យលោកនិយម តែសូមកុំភ្លេច សិទ្ធិរបស់បុរសនិងស្ត្រីត្រូវមានក្របខណ្ឌសម្រាប់ដើរ សិទ្ធិនេះបើពោលតាមច្បាប់ព្រះពុទ្ធសាសនា ក៏គង់មានចែងស្រាប់មកហើយ ដែលគេបានចាត់ទុកស្ត្រីជាបាទបរិចារិការបស់បុរស , ភិក្ខុនីដែលបានបួសក្នុងព្រះពុទ្ធសាសនា ទោះបីមានវស្សា ២០-៣០ ក៏ដោយ ចំពោះបុរសដែលទើបនឹងបំពេញជាភិក្ខុភាព ១ ថ្ងៃប៉ុណ្ណោះ ក៏ត្រូវភិក្ខុនីគោរពភិក្ខុនោះដែរ ។

ចំពោះស្ត្រីដែលបានទទួលសិទ្ធិនេះហើយកុំអាលភ្លេចខ្លួនអួតហួសហេតុមិនបានគិតដល់ករណីផ្លាស់ខ្លួន ប្រយ័ត្នក្រែងស្ត្រីក្លាយជាបុរស ។ បុរសក្លាយទៅជាស្ត្រីដោយអាងសិទ្ធិ

យើងពោលនេះមិនមែនបង្អាប់នារីពិភពលោកទេ យើងចង់ឲ្យនារីចេះរក្សា ការថ្លៃថ្នូរនិងសេចក្តីបរិសុទ្ធសម្រាប់ឋានៈខ្លួន ខ្ញុំយល់ច្បាស់ថា នារីទាំងឡាយមានសិទ្ធិកាន់ដំណែងរាជការ ក្នុងក្រសួងណាមួយបាន , មានសិទ្ធិធ្វើជាសមាជិកក្នុងអង្គការណាមួយបាន , មានសិទ្ធិតែងតាំងច្បាប់បាន ។ គ្រប់តែនារីតែងមានសីលធម៌ច្រើនពីរោះផ្អែម មានសម្ផស្សគួរស្នេហា ; ខ្ញុំសូមឲ្យនារីពិភពលោកទាមទារសិទ្ធិតាមគោលនៃព្រះពុទ្ធសាសនា ទើបដម្លៃនារីឋិតថេរបានយូរទៅអនាគត

ដើម្បីធ្វើភារកិច្ចឲ្យគ្រប់ឋានៈខ្លួន នឹងញ៉ាំងបុរសកុំឲ្យមើលងាយឋានៈនារី ត្រូវចែកព្រំដែននៃសិទ្ធិដល់ជនទាំងពីរក្រុមនេះតាមប្រភេទនៃព្រះពុទ្ធសាសនា ទើបមិនមានការពោលទោសគ្នាទៅវិញទៅមក ។

X X

X

ធាតុអាកាសប្រទេសកម្ពុជាពេលនេះក្តៅណាស់ សូមជនរួមជាតិជួយពិចារណា ; ដើម្បីជួយបំបាត់អាកាសក្តៅនោះផង ខ្ញុំយល់ថា បើយើងចេះផ្សាយមេត្តាទៅកាន់គ្នាចំពោះមនុស្សគ្រប់ឋានៈនោះ ប្រហែលជាព្រះអាទិត្យមិនកំដៅយើងដល់ថ្នាក់ហ្នឹងទេ ត្រូវកុំលុះដោយតណ្ហាពេក គួរអាណិតអ្នកកំសត់ទុគ៌តផង យើងនឹងវិនាសព្រោះតែខ្វះមេត្តាចិត្ត ។

## អ្នកណារក្សាទំនៀមទំលាប់ខ្មែរ

កូនខ្មែររក្សាទំនៀមទំលាប់ខ្មែរ បើកូនខ្មែរមិនយកចិត្តទុកដាក់ ទំនៀមទំលាប់នឹងរលាយ , សព្វថ្ងៃនេះយើងដូចជាមិនពេញចិត្តនឹងរក្សាទំនៀមទំលាប់សោះ បបួលគ្នាផ្តិតយកតែរបៀបជនបរទេស , បន្តិចទៀតជាតិនឹងមានរបៀបរបបគ្រប់បែបយ៉ាងតាមជនបរទេសជាប្រាកដ , ភ្លេង , សំលៀកបំពាក់ ការជប់លៀង ការចរចា ចរិយាមារយាទ សីលធម៌ យើងបាននិយមតាមអឺរ៉ុបដោយភាគច្រើនហើយ បើយើងអាចនិយមអក្សរសាស្ត្រអឺរ៉ុបទៀតនោះយើងនឹងស៊ីវិល័យ ទាន់អឺរ៉ុបពិត បើពោលឲ្យអស់ទៅត្រូវនិយម

សាសនាខាងអ៊ឺរ៉ុបទៀត នោះយើងនឹងនៅប្លែកត្រឹមតែពណ៌សម្បុរប៉ុណ្ណោះទេ (ស៊ីវិល័យខ្មែរសម័យ-ឆ្នាំ ១៩៥៥)

X X

X

អ្នកមានទ្រព្យគាចកែកំហុសរបស់ខ្លួនបាន អ្នកក្រក្រលំបាក ធ្វើសេចក្ដីត្រូវឲ្យទៅជាកំហុសក្នុងពេលមានរឿង អ្នកមានសម្បត្តិតែងស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនបានតាមប្រាថ្នា ទោះបានលើសិទ្ធិជនដទៃខ្លះក៏ដោយ អ្នកក្រត្រូវវិនាសប្រយោជន៍គ្រប់យ៉ាង ទោះមានបំណងបែបណាក៏ដោយ ៗ (វិសុទ្ធិទេព មិនឈ្នះទេពប្រាក់ទេ)

X X

X

ដើម្បីធ្វើអក្សរសាស្ត្រជាតិកុំឲ្យមានល្បឿន យើងត្រូវនិយមខ្ជាប់ចិត្តជនបរទេសបន្តិច ព្រោះគេធ្លាប់ជាចៅហ្វាយនាយយើង ហើយត្រូវយកជនបរទេសឲ្យចូលជួយធ្វើការក្នុងប្រទេស យើងរឹងរិតតែច្រើនឡើង ពស្ត្រស្រែចំការបេះអក្សរសាស្ត្របរទេសច្រើនជាងអ្នកក្នុងភពជាទី បានជាសព្វថ្ងៃនេះគេប្រើអក្សរបរទេសទៅកាន់ពស្ត្រស្រែចំការ ដោយភាគច្រើន ៗ



## សេចក្ដីជំទាស់

ខ្ញុំសូមតបលិខិតឥតឈ្មោះ (មិត្តសាលាបាលីលេខ ២ ឆ្នាំ ១៩៥៥ ទំព័រ ៨) ត្រង់ដែលសួរថា: ចុះផ្សាយរឿងប្រលោមលោកយើងបានឬមិនបាន ? „ ខ្ញុំសូមឆ្លើយតបលិខិតឥតឈ្មោះថា "ចុះបាន„ គឺគេចុះតាំងពីក្នុងទស្សនាវដ្ដីឆ្នាំ ១៩៥៤ ហូរហែមក ហើយដែលហៅថា ប្រវត្តិនៃក្មេងកំព្រា មានកុមារសំណាងជាតួឯកស្រាប់ ; នេះមិនមែនជារឿងប្រលោមលោកទេឬ? បានជាលិខិតឥតឈ្មោះសួរដូច្នេះ? ៗ ខ្ញុំយល់ថាការចុះផ្សាយរឿងប្រលោមលោកក្នុងទស្សនាវដ្ដីយើង តែប៉ុណ្ណឹងសន្លឹកគ្រប់ ១ លេខទៅក៏ល្មមហើយ បើចុះរឿងហ្នឹងលើសសន្លឹកពីនេះ ហាក់ដូចជ្រុលបំណុះពេក, លុះកាលណាចប់ ប្រវត្តិនៃក្មេងកំព្រា ហើយ យើងរករឿងប្រ

ប្រលោមលោកឯទៀតៗមកចុះផ្សាយតាមលំអានដើម ទើបគួរ ។ ត្រង់ដែលថាគួរឲ្យផ្សាយ ១ខែពីរលើក នោះ ខ្ញុំក៏មិនហ៊ានអាចកាត់យល់ព្រមដែរ ស្រេចតែ គណៈកម្មការទស្សនាវដ្ដីចុះ , តែខ្ញុំសូមជំរាបរឿង ដែលខ្ញុំចាំមួយថា ហ៊ឹងចិបំប៉ោងខ្លួនឲ្យធំ ដូចគោ ស្លាប់ខ្លួនឯងជ្រះដោ នៅកំលស្រែ ស្រមោចពេមអែរ គ្មាននរណាសមគំនិតផង ។

ស.ស. ភ្វិរតោ

ខ្ញុំបាទឈ្មោះ នង-អុម ជាតិខ្មែរជាអតីតមេឃុំ ព្រែកជ្រៃ សព្វថ្ងៃធ្វើជាជាង ផ្ទះសំណាក់លេខ ២១ ទំព្រែក ព្រៃវែង

ខ្ញុំបាទសូមក្រាបប្រណិបតន៍ចូលមកលោក ចាងហ្វាងទស្សនាវដ្ដីមិត្តសាលាបាលី ក្រុងភ្នំពេញ សូមជាទព្រាប ។

ខ្ញុំបានទទួលចុះឈ្មោះជាវទស្សនាវដ្ដី របស់ លោកប្រចាំឆ្នាំ ១៩៥៥ ហើយបានចាប់អានទៅ ឃើញមានអត្ថបទគួរពេញចិត្តច្រើនអន្លើ ដែលអាច បំពេញសេចក្ដីត្រូវការលួងទៅរបស់ខ្ញុំ ឲ្យភ្លឺថ្លាឡើងបានតែ ជឿនជឿនដោយដុំដោយអន្លើ ។

សេចក្ដីជឿនលឿននេះគឺជាសំណាងមួយយ៉ាងក្រៃ លែងរបស់ខ្ញុំ ដោយបានឃើញលោកបើកសិទ្ធិឲ្យ សួរទីងបើកចំហាទំព័រឲ្យចុះសេចក្ដីសង្ស័យ នេះជា សេចក្ដីពេញចិត្តរបស់ខ្ញុំ

ត្រង់ដែលថាអ្នកអានចាំងឡាយចេះតែផ្ញើសេចក្ដី ត្រាំគ្រប់ហាងនោះជាសេចក្ដីពេញចិត្តយ៉ាងកណ្ដាល

ខ្ញុំសូមជំរាបថា តាមយោបល់របស់ខ្ញុំជាជន លួងទៅក៏តែងតែងល់មិនចេះអស់ហើយ ចំពោះ សារាចររបស់ឯ. ឧ. នាយករដ្ឋមន្ត្រីលេខ ២០ ចុះថ្ងៃ ១២ កុម្ភៈ ១៩៥៥ និងមាត្រា ២ នៃរដ្ឋធម្មនុញ្ញដែល លោកបានចុះផ្សាយថា ត្រូវប្រើអក្សរសាស្ត្រជាតិទៅ តាមផ្ទៃការ , អ្វីដែលធ្វើជាភាសាបាលីហើយត្រូវ តែប្រែមកជាអក្សរសាស្ត្រទាំងអស់ ។

ចុះឥឡូវនេះហេតុម្ដេចក៏ទស្សនាវដ្ដីលេខ ១ឆ្នាំ ១៩៥៥ ទំព័រ ១៣ មានចុះអក្សរបាលីខាងក្រោម ត្រង់វង់ក្រចក និងទំព័រ ១៦ ទៀតច្រើនអន្លើសៀវភៅ លេខ២ ទំព័រ ៣០ , ៣២ , ៣៣ ម្ដេចក៏មានចុះ អក្សរបាលីនាំឲ្យអ្នកល្ងីល្ងង់មើលមិនយល់ មិនដឹង ជាបានសេចក្ដីដូចម្ដេច? ម៉្លោះហើយក៏គាន់សៀវភៅ នោះដើរសួរអ្នកចេះភាសាបាលី ; គង់មនុស្សរាប់ ពាន់អ្នកនៅទីរួមខេត្តព្រៃវែងវៀរលែងតែអ្នករាជការ ចេញ មានអ្នកចេះភាសាបាលីប្រហែលជាពីរនាក់ ប៉ុណ្ណោះ ; អ្នកដែលត្រូវគេសួរនោះមើលអក្សរបាលី បី-បួនគ្រួសទើបប្រែយកសេចក្ដីបាន គិតទៅខាត ពេលជាង ១ ម៉ោង គ្រាន់តែពាក្យបាលីមួយម៉ាត់ ប៉ុណ្ណោះ នេះចំពោះជនអ្នកនៅក្នុងក្រុង , ចុះបើជន ជាតិខ្មែរនៅស្រែចំការវិញ ដែលពុំធ្លាប់ស្គាល់អក្សរ

បារាំងផងនោះ តើគ្នាមិនទានស្គាល់ពាក្យនោះហើយឬ?

ខ្ញុំសូមជំរាបថា ប្រជាជនខ្មែរ តាំងមូលក្នុង-អាណាចក្រកម្ពុជាតាំងមូល មានអ្នកចេះភាសាជាតិ-ផងភាសាបារាំងផងនោះមានចំនួនតិចណាស់ បើយ៉ាងនេះតើលោកសរសេរអក្សរបារាំងឲ្យអ្នកណាមើល ? ឬពាក្យបារាំងនោះដាក់មកជាអក្សរខ្មែរមិនត្រូវ , ប្រែចេញមកជាភាសាជាតិមិនបាន ពុំនោះរោងពុម្ពគ្មានអក្សររៀប . ឱ ! លោកគ្រូភាសាសូរសំដីលោកណាស់ គ្រប់តែកាសែតនិងទស្សនាវដ្តី បានអំពាវនាវឲ្យគេជួយជាវជួយអាន ដើម្បីធ្វើវឌ្ឍនធម៌របស់ជាតិឲ្យមានដំណើរទៅមុខ , ឥឡូវសព្វបើពាក្យបារាំង ២ - ៣ ម៉ាត់ប៉ុណ្ណោះលោកខំសរសេរតាំងដុលមកមិនហ៊ានបកប្រែ នាំឲ្យគ្នាអ្នកអានទានដឹងដែរ !

សេចក្ដីនេះខ្ញុំសូមទីពឹងលើលោកចាងហ្វាងទស្ស-នាវដ្តីនិងកាសែត សូមឲ្យលោកប្រយ័ត្នព្រោះជាអ្នកមេដឹកនាំ នឹងឲ្យជួយស្រែកពន្យល់ដល់ខេមរៈជាតិទោះតាំងស៊ីវិលឬទាហាន ដែលសរសេរសំបុត្រទៅកាន់មិត្តភក្ដិឬឪពុកម្ដាយនៅលើស្រោមសំបុត្រ សុំឲ្យសរសេរអក្សរសាស្ត្រជាតិដោយដាច់ខាត ព្រោះ-ភ្នាក់ងារឃុំដែលជាអ្នកកាន់ការនោះ តិចចេះបារាំងណាស់ ហើយអ្នកទទួលលិខិតសោតទៀតក៏មិនដែលតាំងយល់ទ.មោ បារាំងមួយម៉ាត់ផង ។

សេចក្ដីសង្ស័យនោះបើលោកចេះតែបើកអំណាច ខ្ញុំក៏ចេះតែសង្ស័យជានិច្ចតាមសភាពខ្លួនជាអ្នកល្ងង់ទៅ ការណ៍ដែលបានរៀបរាប់មកខាងនេះសូមលោកចាងហ្វាងមេត្តាពិនិត្យហើយធ្វើឲ្យបានឆាប់ បើយល់ថាគ្មានប្រយោជន៍ក៏សូមបដិសេធចោលដោយគ្មានទោមនស្សឡើយ ។

## សេចក្ដីឆ្លើយ

ខ្ញុំមានសេចក្ដីត្រេកអរជាអនេកដោយបានទទួលលិខិតឆ្លើយឆ្លងរបស់មិត្តអ្នកអាន ។

តាមសេចក្ដីឆ្លើយរបស់លោក គូរ៉េកា តបលិខិតគ្មានឈ្មោះ ពីការស្នើចុះរឿងប្រលោមលោក ឥឡូវអ្នកនិពន្ធគ្មានឈ្មោះបានតបសេចក្ដីជូនតទៅ .—

ប្រវត្តិក្មេងកំព្រាលោកថារឿងនោះជាប្រលោមលោកខ្ញុំដូចជាពុំទាន់ចូលចិត្តនៅឡើយ ព្រោះរឿងនោះមានជាប់ទាក់ទងផ្លូវសាសនាច្រើន នឹងឲ្យច្បាស់សូមសួរយោបល់អ្នកនិពន្ធ;រឿងចេញ ១ ខែ ១–២ លើក ស្រេចលើគណៈកម្មការនោះពិតមែន ! រឿងហ្នឹងខ្ញុំបំប៉ោងនោះក៏ខ្ញុំយល់ខ្លះដែរ ថាបើយើងខំបំប៉ោងតាមគំនិតបញ្ញានោះប្រសើរ តែបើបំប៉ោងយកខ្យល់នោះមុខជាបែកពោះហើយ បញ្ចេញខ្យល់ឈ្មុយដែលគេមិនត្រូវការ ; អ្នកណាបំប៉ោងលោកចាងហ្វាងឬ? ពុំនោះលោក . . . . . . . . . .ទេដឹង?

លាហើយលោក គូរ៉េកា

ប្រវត្តិក្មេងកំព្រា មិនមែនជារឿងប្រលោមលោកសុទ្ធសាតនោះទេ សូមចាំសន្មតិរឿងនោះដល់ពេលចប់ អ្នកនិពន្ធខ្ញុំបាទសន្មតិរឿងនោះថាជារឿងប្រលោមលោកក្នុងសាសនា សូមជ្រាបដោយសេចក្តីខ្ញុំ ·–(ហា.ហា)

X X

X

លោកអតីតមេឃុំព្រែកជ្រៃ ខ្ញុំទើបតែភ្ញាក់ខ្លួនថាលោកចេះដាក់ខ្លួនធ្វើជមនុស្សល្ងង់ ហើយប្រសប់ចាប់កំហុសអ្នកនិពន្ធអត្ថបទគុំឲ្យរើខ្លួនរួច សេចក្តីនេះប្រាកដដូចលោកចាប់កំហុសមែនហើយ ខ្ញុំសូមទទួលដោយមេត្រីភាពយ៉ាងស្មោះស្ម័គ្រ សូមឲ្យលោកបំពេញកិច្ចនេះតទៅទៀត

អក្សរបារាំងដែលបានចុះក្នុងវង់ក្រចកនោះ ដោយគាំងថាមានសេចក្តីអធិប្បាយរួចហើយ បានជាមិនបាចប្រាប់ពីអានទឹងការប្រែផ្ទឹតនៃពាក្យ ហើយមួយទៀតភាសានោះជាភាសាអង់គ្លេសផង ; ចំពោះអក្សរបារាំងដែលចុះក្នុងអត្ថបទ សញ្ញាការពារភាស៊ីនោះ ជាកំហុសអ្នកនិពន្ធពិតមែនហើយតែអ្នកនិពន្ធគេគាំងថា មានចំណងជើងនៃអត្ថបទរួចទៅហើយ នឹងសេចក្តីពន្យល់ខាងដើមល្មមជាការសណ្ដាប់ដែរ ចាំបាច់ប្រែផ្ចិតធ្វើម៉េចទៀត ? ដែលថាគ្មានអក្សររៀប, មានច្បាប់ហាមប្រាមនោះមិនមានឡើយ គឺថាកំហុសអ្នកចាត់ការ ; តទៅថ្ងៃមុខខ្ញុំសូមបំពេញចំណងរបស់លោកតាមសេចក្តីពិត ។

សេចក្តីខាងចុងដែលលោកបានអំពាវនាវឲ្យខ្ញុំជួយស្រែកពន្យល់ដល់ជនរួមជាតិនោះ ជាការប្រពៃណាស់ ខ្ញុំក៏ស្មាក់ចិត្តបំរើយោបល់លោកមិនខ្លាចសេចក្តីនឿយហត់ ; ខ្ញុំពេញចិត្តបំផុតបើអ្នកកម្ពុជាចេះស្គាល់ដំឡៃអក្សរសាស្ត្ររបស់ខ្លួន , តែបើតាមដែលខ្ញុំធ្លាប់បានដឹងមក គេយល់ផ្ទុយស្រឡះពីខ្ញុំទៅវិញថា បើជនណាចេះសរសេរអក្សរជនបរទេសនោះ សូម្បីបន្តិចបន្តួច ក៏គេរឹតតែប្រឹងសរសេរយ៉ាងច្រើនទៅទៀតដើម្បីបង្អួតថាខ្លួនចេះ អក្សរសាស្ត្រជាតិនេះជាតិនោះ សូម្បីនិយាយរកជនរួមជាតិដូចគ្នាក៏គេនិយមនិយាយភាសាបរទេសលាយឡំផងដែរ ទីចាត់ការរបស់រាជការជាច្រើនមានតិចណាស់ដែលប្រើអក្សរសាស្ត្រ មានតែខាងតុលាការទេប្រើអក្សរសាស្ត្រជាតិ ទីដទៃទៀតគេគាំងថាប្រើអក្សរខ្មែរយឺតពេកមិនទាន់ការ ហើយពាក្យខ្មែរមានតិចប្រើមិនគ្រប់គ្រាន់ មានកន្លែងខ្លះគេនិយមយកជនបរទេស ដែលមិនទាំងចេះនិយាយភាសាខ្មែរឲ្យធ្វើការរាជការទៀតផង បើដូចនោះអក្សរសាស្ត្រជាតិយើងដើរទៅតាមផ្លូវណា?

សូមលោកជ្រាបថា សព្វថ្ងៃនេះអ្នកដែលចេះភាសាជាតិយ៉ាងម៉ត់ចត់នោះ ច្រើនតែមានបណ្ដាស័ក្តិតូចតាច អ្នកទាំងនោះគ្នាត្រូវចាត់ការតែតាម

ចៅហ្វាយនាយ ចុះបើចៅហ្វាយនាយខ្លះមើលអក្សរខ្មែរមិនទាំងយល់ផង ទឹងឲ្យប្រើអក្សរសាស្ត្រជាតិដូចម្ដេចកើត? គួរឲ្យអាសូរពេកខ្មែរមិនចេះអក្សរសាស្ត្រខ្មែរ ដូចជាលោកបានអាសូរខ្ញុំលើកហួសដូចនោះដែរ ។ (ហា, ហា.)

---

# រឿងជ័យប្រាជ្ញ (ត)

វេលាថ្ងៃមួយពួកអស់អ្នកបានមកជួបជុំគ្នាហើយបបួលកុមារជ័យលេងប្រដៅ ។ កុមារជ័យប្រកែកថា ខ្ញុំមិនហ៊ានលេងទេ ព្រោះប្រដៅរបស់ខ្ញុំជ្រៅ ៗ ណាស់ ក្រែងខ្ញុំបាទចាត់ទៅហើយអ្នកបងរកមិនឃើញ ។ កាលណាខ្ញុំបានលក់អ្នកបងទៅក្រែងអ្នកបងត្រឡប់ជាមួរម៉ៅនឹងខ្ញុំបាទវិញ នាំឲ្យហាប់ចិត្តខឹងគ្នា ។

ពួកអស់អ្នក — មិនអីទេ ! ឲ្យតែអូនឯងលេងចុះ បងមិនប្រកាន់ទេ សូមកុំឲ្យតែអ្នកណាជួយរកអូនឯង

កុមារជ័យ — បើអ្នកបងមិនប្រកាន់មែន មានអី ខ្ញុំបាទសុខចិត្តលេងជាមួយ ។

ពួកអស់អ្នក — បើដូច្នេះតើឲ្យអ្នកណាប្រដៅមុន

កុមារជ័យ — ឲ្យខ្ញុំបាទប្រដៅមុនក៏បាន អ្នកបងប្រដៅមុនក៏បាន ប៉ុន្តែសូមកុំឲ្យអ្នកបងប្រដៅមួយម្នាក់ៗ ទាំងអស់គ្នា ហើយបូករួមឲ្យខ្ញុំបាទរកម្នាក់ឯងតែម្ដង នោះខ្ញុំបាទមិនលេងទេ ។ បើប្រដៅមួយទៅមួយមកទើបលេងបាន ។ ចំណែកខាងការរកខ្ញុំបាទបើកឲ្យអ្នកបង រកគ្រប់គ្នាទាំងអស់ បើរកមិនឃើញត្រូវខ្ញុំលក់ម៉ៅទាំងអស់គ្នា បើព្រមលេងដូច្នេះទើបខ្ញុំសុខចិត្តលេង ។

ពួកអស់អ្នក — អើ មិនអីទេ លេងយ៉ាងនេះក៏លេង ។

កុមារជ័យ — ឲ្យខាងណាប្រដៅមុន ឬឲ្យខ្ញុំប្រដៅមុន ។

ពួកអស់អ្នក — ត្រូវឲ្យពួកយើងប្រដៅមុន ។

កុមារជ័យ — អ្នកបងប្រដៅយ៉ាងម៉េច ក៏ប្រដៅចុះ ។

ពួកអស់អ្នក — ដើមក៉ប៉ុនទៀន លៀនឡើងប៉ុនជាស ។

កុមារជ័យ — ព្រលិត ត្រូវខ្ញុំប្រដៅវិញ ប៉ុនករដៃកាល័យគូថ ។

ពួកអស់អ្នក — អាឯងប្រដៅអាក្រក់ពេកអញមិនខ្ចីរក ។

កុមារជ័យ — បើមិនរកទុកជារកមិនឃើញ ត្រូវតែលក់ ។

ពួកអស់អ្នក — ក៏ព្រមឲ្យលក់ ។

គុមារជ័យ – លក់ថា៖ សូមលក់អ្នកបង់ទៅស្រុកចំអេះ ធ្វើមាត់ប្រវេះ គេះស៊ីមិនបាន ហ្នឹងគេហៅកន្ទុយគោ ។

ពួកអស់អ្នក – យី! អាឯងលក់អីក៏អាក្រក់ម្ល៉េះ ។

គុមារជ័យ – សូមអ្នកបង់ប្រដៅមកទៀត ។

ពួកអស់អ្នក – សត្វនោះមកពីស្រុកចិន កន្ទុយសិនរុំនស៊ីក្បាលមនុស្ស ។

គុមារជ័យ – កន្ត្រៃ, ត្រូវឲ្យខ្ញុំប្រដៅវិញ

មមិសពីលើមមិសពីក្រោមទន្ទិចគ្នាព្រមស្រណុក ទាល់ព្រឹក ។

ពួកអស់អ្នក – យី! អាឯងប្រដៅអីអាក្រក់ម្ល៉េះ អញមិនខ្វីរកទៀត ។

គុមារជ័យ – បើមិនរកទុកជារកមិនឃើញ ត្រូវតែលក់ ។

ពួកអស់អ្នក – បើអាឯងលក់អញ្ចុំអំបែងលីងសួត ។

គុមារជ័យ – សូមលក់អ្នកបង់ទៅដល់កំពង់ក្តុក ខាងក្រោមគគ្រុកខាងលើគគ្រេច ហ្នឹងហៅត្រយក វិក្កលើក្រោម ។

ពួកអស់អ្នក – ដើមកប៉ុនអង្រែផ្លែកប៉ុនអង្រឹត ។

គុមារជ័យ – ដើមអន្ទ្យរ ត្រូវខ្ញុំប្រដៅវិញ តែកគោកក្រោមក្តៅរុញទៅចេញទឹក ។

ពួកអស់អ្នក អញមិនខ្វីរកទៀត អាឯងប្រដៅអាក្រក់ពេក ។

គុមារជ័យ – បើមិនរកទុកជារកមិនឃើញ ត្រូវតែលក់ៗ លក់អ្នកបង់ទៅស្រុកតាមែក បើមិនញែកចូលមិនរួច ។ ហ្នឹងគេហៅស្នាបបាចទឹកទូក ។

ពួកអស់អ្នក – មួយមិនដែលមានពីរ, ពីរមិនដែលមានបី, បីមិនដែលមានបួន, បួនមិនដែលមានប្រាំ, ប្រាំមិនដែលមានប្រាំមួយ, ប្រាំមួយមិនដែលមានប្រាំពីរ, ប្រាំពីរមិនដែលមានប្រាំបី ប្រាំបីមិនដែលមានប្រាំបួន ប្រាំបួនមិនដែលមានដប់ ដប់មិនដែលមានដប់មួយ

គុមារជ័យ – នេះមិនមែនប្រដៅទេ គេហៅថា ចំណោទ ដូច្នេះខ្ញុំមិនរកទេ ។

ពួកអស់អ្នក បើអាឯងមិនរកទុកជារកមិនឃើញត្រូវអញលក់ ។

គុមារជ័យ – បើអ្នកបង់ចង់លក់ខ្ញុំៗរក

១ មិនដែលមាន ពីរ ភ្នំព្រះសុមេរុ
២ " បី យប់នឹងថ្ងៃ
៣ " បួន ត្រៃវេទ
៤ " ប្រាំ ទ្វីប ៤
៥ " ប្រាំមួយ អវយវៈតាំងប្រាំ
៦ " ប្រាំពីរ ឆកាមាសួគ៌
៧ " ប្រាំបី ភ្នំសត្តបរិភណ្ឌ
៨ " ប្រាំបួន ព្រាយក្បាល៨

៩ " ដប់ នព្វន

១០ " ដប់មួយ ទសពិធរាជធម៌

កុមារជ័យ – កំប៉ាក់ប៉ុនស្លឹកម្ទូ ប្រហោងគ្រហូ មមិសផុត ៗ

ពួកអស់អ្នក – អញមិនទំរកទេ អាឯងប្រដៅអាក្រក់ម៉្លេះ អញទៅក្រាបបង្គំទូលព្រះមហាក្សត្រហើយ ព្រោះអាឯងថាឲ្យអញអាក្រក់ណាស់ អញមិនសុខចិត្តទេ ៗ

កុមារជ័យ – ឱ អ្នកបងអើយ ការលេងសោះ មិនគួរនាំគ្នាទៅក្រាបបង្គំទូលព្រះមហាក្សត្រ នាំឲ្យរំខានព្រះរាជហឫទ័យព្រះអង្គធ្វើអ្វីទេ ៗ

ពួកអស់អ្នកមិនព្រមស្តាប់កុមារជ័យ នាំគ្នាទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរសព្វគ្រប់ ៗ

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ហើយទ្រង់មានបន្ទូលសួរថា នែអាជ័យ ! ហេតុអ្វីក៏អាឯងប្រដៅថាឲ្យអស់អ្នកអញអីអាក្រក់ម៉្លេះ? ថែមទាំងលក់គេក៏លក់ៗក្រក់ទៀត បើដូច្នេះចូរអាឯងអធិប្បាយឲ្យអញស្តាប់មើលតើសមឬមិនសម បើមិនសមអញនឹងយកទោស ដោយបទអាឯងពោលចំអកឲ្យគេ

ទី១ តើអាឯងប្រដៅដូចម្តេចលក់ដូចម្តេច ?

កុមារជ័យ –. ទី ១ ទូលព្រះបង្គំប្រដៅថា : "ប៉ុនកដៃអាល័យគូថ" ហ្នឹងហៅថា "កន្ទុយគោ" អធិប្បាយថា : តាំងពីបុរាណកាលមក កន្ទុយគោមិនដែលលះបង់គូថគោឡើយ គឺនៅប្រនៀលអស់កាលជានិច្ចតែទីងគគូថគោនោះ ដរាបទាល់អស់ជីវិត ៗ

ពាក្យលក់ទូលព្រះបង្គំថា : „ស្រុកចំអេះ ធ្មុ មាត់ប្រវេះកេះស៊ីមិនបាន„ បានសេចក្តីថា "កន្ទោ សម្រាប់ដោះទុកសត្វតូច„ ព្រោះកន្ទ្រោពីកំនេះ មាត់ចំហ វត្ថុនៅក្នុងនោះបរិភោគមិនបាន ៗ សូមទ្រង់ជ្រាប ៗ

ទី២ – តើអាឯងប្រដៅដូចម្តេច ? លក់ដូចម្តេច?

កុមារជ័យ –. ទី ២ – ទូលព្រះបង្គំប្រដៅថា "មមិសទាំងលើ មមិសទាំងក្រោមទង្គិចគ្នាព្រមស្រណុកទាល់ព្រឹក" ហ្នឹងគេហៅថា „ត្របកភ្នែកលើ ត្របកភ្នែកក្រោម„ អធិប្បាយថា "ត្របកភ្នែកលើក៏មានមមិស ត្របកភ្នែកក្រោមក៏មានមមិស តែកាលណាដេកទៅហើយ ត្រូវតែទង្គិចគ្នា ទទួលទានដំណេក លក់ស្រណុកទាល់ព្រឹក ៗ

ពាក្យដែលទូលព្រះបង្គំលក់ថា : កំពុងក្អកក្អង ខាងលើគគ្រុក ខាងក្រោមគគ្រិប„ បានសេចក្តីថា „បង្គន់" នៅទីបង្គន់ខាងក្រោមក៏មិនស្អាតខាងលើក៏មិនស្អាត ៗ

ទី ៣ តើអាឯងប្រដៅដូចម្តេច លក់ដូចម្តេច?

កុមារជ័យ. – ទី ៣ ទូលព្រះបង្គំប្រដៅថា

“តែលតោលក្រោមក្តៅរុញទៅចេញទឹក” ហ្នឹងគេហៅថា “ស្នាចបាចទឹកទូក” អធិប្បាយថា : វេលាដែលគេបាចទឹកទូកគេក្រោកឈរឡើង បង់ជំទែង យកដៃទាំងពីរ កាន់ស្នាចដាក់សំយុងទៅក្រោមក្តៅ ហើយគេរុញទៅមុខ យោលតែលតោល ជួយគ្រវែងទឹកចេញពីទូកចោលទៅក្រៅ ។

ពាក្យលក់ទូលព្រះបង្គំថា “ស្រុកគាមែកបើមិនញែកចូលមិនរួច” បានសេចក្តីថា “ព្រៃគ្រង” អ្នកដែលចូលព្រៃគ្រងបើមិនយកដៃញែកចូលទៅមិនរួចទេ ព្រោះព្រៃគ្រងជាព្រៃស្បាតមួយយ៉ាងស្អាប់ៗ

ទី ៤ – តើអាឯងប្រដៅយ៉ាងម៉េច លក់យ៉ាងម៉េច? ។

កុមារជ័យ – ទូលព្រះបង្គំប្រដៅថា : „កំប៉ាត់ប៉ុនស៊ីកម្មប្រហោងគ្រហូមមិសផុក„ ហ្នឹងគេហៅថាស៊ីកគ្រចៀកគោ„ ព្រោះគ្រចៀកគោរាងកំប៉ាត់ប៉ុនស៊ីកម្មមានទ្រូ ហើយមានរោមផុសផុកខាងក្នុង ៗ ត្រង់នេះទូលព្រះបង្គំឥតបានលក់ទេ ព្រោះអ្នកបង់ទាំងនោះក្តៅក្រហាយក្នុងចិត្តលែងលេងទៅ ហើយចូលមកក្រាបបង្គំទូលព្រះអង្គ ដើម្បីនឹងឲ្យទ្រង់ធ្វើទោសទូលព្រះបង្គំ ដោយយល់ថា ទូលព្រះបង្គំថាឲ្យអាក្រក់ពេក បើទុកជាទូលព្រះបង្គំឃាត់យ៉ាងណាក៏អ្នកបង់ទាំងនេះមិនព្រមដោយដាច់ខាត ព្រោះយល់ថាទូលព្រះបង្គំពោលពាក្យអាសគ្រាម មិនគប្បីនឹងពោល ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ព្រះសម្រួល មានបន្ទូលទៅកាន់អស់អ្នកទាំងឡាយនោះវិញថា ហៃនាងទាំងឡាយ ! តាមចម្លើយអាជ័យនេះយើងមិនអាចសម្រេចទោសវាបានឡើយ ៗ ព្រោះមិនឃើញកន្លែងត្រង់ណាមួយ គួរចោទប្រកាន់ថាវាពោលពាក្យអាសគ្រាមបាន ។

ពួកអស់អ្នកទាំងនោះក៏សុញគំនិតនៅស្ងៀមទៅ ៗ

ព្រះមហាក្សត្រទ្រង់មានបន្ទូលសួរបញ្ជាក់ទៅពួកអស់អ្នកទាំងនោះថា : អាជ័យវាប្រដៅដូច្នេះមែនឬ?

ពួកអស់អ្នក – សូមទ្រង់ព្រះមេត្តាប្រោស វាប្រដៅដូច្នោះមែន ។

ព្រះមហាក្សត្រ -- អើបើយ៉ាងនេះត្រូវវាបានរួចខ្លួន ព្រោះវាប្រដៅទាំងអស់នេះមិនមែនប្រដៅអាក្រក់ទេ ៗ គឺប្រដៅល្អ មកតែពីនាងរាល់គ្នាយល់ផ្ទុយ បានជាថាវាប្រដៅអាក្រក់ ។

ពួកអស់អ្នកទាំងនោះនឹកខ្នាខ្នាញ៉ើនឹងកុមារជ័យខ្លាំងណាស់ តែដល់គំនិតមិនដឹងជាធ្វើដូចម្តេច ។

ព្រះមហាក្សត្រទ្រង់យល់គំនិតអស់អ្នកទាំងនោះ ដល់វេលាកុមារជ័យចេញបាត់ទៅ ទ្រង់មានបន្ទូលថា : សូមនាងទាំងឡាយកុំភ័យ ចាំយើងស្វែងរកទោសអាជ័យឲ្យក្នុងរយៈ ៦ - ៧ ថ្ងៃទៅមុខទៀត ។

X X

X

លុះកន្លងមកបាន២ថ្ងៃ ព្រះមហាក្សត្រទ្រង់ចេញប្រកាសរកអ្នកចំបាប់ឯណា ដែលពូកែជាងគេមកលេងនឹងអ្នកចម្បាប់របស់ព្រះអង្គ បើលេងឈ្នះទ្រង់ប្រទានរង្វាន់យ៉ាងច្រើន ។ ទ្រង់ហៅកុមារជ័យមកដាក់កំហិតថា : នែ! អាជ័យ! អញតាំងអាឯងជាអ្នកចំបាប់របស់អញហើយ ហេតុនេះបើមានអ្នកឯណាមកលេង ត្រូវចេញទៅលេងត នៅវេលាចំនួនប៉ុន្មានថ្ងៃទៅមុខទៀត ។

កុមារជ័យ — ឱ! ខ្លួនអញអើយ! ថ្ងៃនេះមុខជាអញត្រូវទទួលគ្រោះថ្នាក់យ៉ាងធំហើយមើលទៅ ប៉ុន្តែណ្ហើយចុះ ត្រូវអញដោះប្រស្នានេះដោយប្រថុយទៅចុះ ។

លុះគិតដូច្នោះហើយ កុមារជ័យយំផងសើចផងនៅចំពោះមុខព្រះមហាក្សត្រ ។ ទ្រង់មានព្រះបន្ទូលសួរថា : នែ! អាជ័យហេតុអ្វីក៏អាឯងយំ? ហេតុអ្វីក៏អាឯងសើច?

កុមារជ័យក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន! បានជាទូលព្រះបង្គំយំមកពីគិតឃើញថា ជីវិតទូលព្រះបង្គំ នៅតែប៉ុន្មានថ្ងៃទៀតស្លាប់ហើយ ព្រោះទូលព្រះបង្គំទើបតែមានទំហំប៉ុណ្ណេះ បើទៅលេងនឹងគេដែលជាអ្នកចេះចំបាប់យ៉ាងពូកែ ឱ! ខ្លួនអញអើយ! មិនសមបើស្លាប់ចោលព្រះមហាក្សត្រសោះ ។

បានជាទូលព្រះបង្គំសើច ដោយគិតឃើញថា បំណាច់មួយថ្ងៃនឹងរស់មួយថ្ងៃនឹងស្លាប់ ត្រូវស្អិតស្អាងកាយឲ្យស្អាតបាតល្អសិន ហេតុនេះត្រូវក្រាបបង្គំទូលសុំអ្នកស្អិតស្អាងពីរនាក់ដែលមានថ្វីដៃយ៉ាងចំណាន និងមហាតលិក ៤ នាក់ ទៅតាក់តែងស្អិតស្អាងកាយឲ្យទូលព្រះបង្គំ ហើយមហាតលិកទាំងបួននាក់នោះថ្នាក់ថ្នមតាំងពីថ្ងៃនេះទៅ ព្រោះនៅប៉ុន្មានថ្ងៃទៀតនឹងដល់ថ្ងៃស្លាប់ហើយ ។ លុះគិតឃើញដូច្នេះបានជាទូលព្រះបង្គំមានសេចក្តីត្រេកអរឥតឧបមា ដោយសង្ឃឹមថាប្រាកដជានឹងទ្រង់ព្រះមេត្តាប្រោសប្រទានតាមសុំជាមិនខាន ។

(នៅមានត)

---

## ប្រវត្តិក្មេងកំព្រា (ត)

ឥឡូវនេះបងឯងចង់និយាយអ្វីនឹងខ្ញុំ បងឯងបានអ្វីពីសំណាង មានតែបងឯងសំឡាប់សំណាង ទើបនិយាយដូច្នោះ ។

ទេអ្នកអូន! រណោតចិត្តខ្ញុំផង ក្នុងពេលដែលខ្ញុំកំពុងតែក្តុល់ព្រួយដូចនេះ ខ្ញុំសូមស្បថជូនអ្នកអូនថា ជីវិតរបស់ខ្ញុំនឹងសំណាងរស់នៅជាមួយគ្នា បើសិន

ជាខ្ញុំរាប់ទទួលគ្រោះថ្នាក់ជួសសំណាងបាន ខ្ញុំស៊ូស្លាប់ឲ្យតែសំណាងបានរស់ជីវិត ទឹងជាទីរកពាយដល់អ្នកអូនផង

— បងឯងនិយាយយ៉ាងម៉េ[illegible]!

មុខនាងឡើងក្រហមដូចភ្លើងឆេះ ស្ទើរតែស្ទុះទៅទះកំភ្លៀងអ្នកកំឡោះ តែពេលដែលស្ទុះចូលទៅ សារិនបានពោលពាក្យដោយសំដីយ៉ាងលំអុតលំទុនថា

— អត់ទោសអ្នកអូន! សូមអ្នកអូនកំអាលប្រឡោត ខ្ញុំបានដឹងសព្វគ្រប់អស់ហើយ រឿងពៅអ្នកអូននឹងសំណាង បើអ្នកអូនចង់ដឹងយករបស់នេះទៅទើបច្បាស់ក្នុងចិត្ត, ដែលខ្ញុំរក្សារបស់នេះព្រោះតែជួយបំបិទការស្លាត់កំបាំង ... ។

នាងស្ទុះយ៉ាងប្រញាប់ចាក់យកវត្ថុនោះមកមើល នាងបានលាក្រដាស់ដែលខ្ចប់ ក៏បានឃើញសំណល់វត្ថុដែលនាងបានប្រគល់ដល់សំណាង ពេលនេះនាងត្រូវយំខ្ទប់មុខម្តងទៀត នៅមុខប្រុសកម្លោះដែលកំពុងតែសំឡឹងនាង

ពេលដែលនាង ធន - សារឿនកំពុងតែយំ ទទួលកូនស្រីលោកជម្ទៀវប្រសើរដើរយ៉ាងលឿនត្រដោះមករកនាងដោយការងឿងឆ្ងល់; សារិនថយចេញទៅអង្គុយទីមួយតែឯង;

នារី សួរ - វត្ថុអ្វីដែលកាន់ទីងដៃ ដែលធ្វើឲ្យបងអណ្តើកអណ្តកយ៉ាងនេះ ?

ធន - សារឿន - មិនឆ្លើយសោះ បែរជាស្ទុះមកឱបនារីយ៉ាងខ្លាំងទៅវិញ នារីទាំងពីរនាក់នេះក៏យំជាមួយគ្នាម្តងទៀត,

ន - បងប្រាប់ខ្ញុំផង ខ្ញុំចេះតែណែនក្នុងទ្រូងខ្លាំងណាស់ ចំពោះរឿងនេះ ?

ស - អូន! កុំចង់ដឹងពីរឿងនេះ

ន - បងរណិតតែប្រាប់អូនផងកុំលាក់ សូមឲ្យបងទុកចិត្តអូនចុះ

ធន - សារឿន នាងព្រមមិនបានក៏ហុចវត្ថុទាំងនោះទៅឲ្យនាងនារី, នារីទទួលហើយក៏យកមកមើលដោយសព្វគ្រប់ បានឃើញវត្ថុទាំងឡាយដូចមានរៀបរាប់ពីមុនមកហើយ; រឿងនេះជាការធុនចិត្តចំពោះនារីគ្រាលើកដំបូងបង្អស់ ។

ជាអកុសលអ្វីម៉្លេះទេ នារី កាលពីដើមនាងពុំបានដឹងថាសំណាងជាកូនចិញ្ចឹមរបស់ឪពុកនាងទេ នាងស្មានថាជាបងបង្កើត ទើបតែក្នុងពេលមុនសំណាងទទួលគ្រោះថ្នាក់នេះទេ ដែលឪពុកនាងបានប្រាប់សេចក្តីពិតត្រង់ឲ្យដឹង, កាលមុននាងដឹងសេចក្តីពិតនោះ នាងបានស្រឡាញ់សំណាងដូចជាបងបង្កើតមែន ។ ដល់ពេលដែលនាងដឹងសេចក្តីពិតនោះកាលណា លោជានឹកក្នុងស្រឡាញ់លាយឡំដោយសេចក្តីស្នេហាខ្លះ តែសេចក្តីស្នេហានោះនៅពុំមានរស្មី

សូម្បីបន្តិចបន្តួចឡើយ , ចុះបើនាងបានឃើញសេចក្តីស្នេហារបស់ ធន - សារឿន គ្រប់លើគោលបំណងរបស់នាងដែរ តើចិត្តរបស់នាងបែបណាទៅវិញ ? យើងបានដឹងហើយ ថាសំណាងបាត់បង់រូបគ្មានលេចពុំដំណឹងអ្វីសោះ ; ចុះម្តេចក៏នារីពីរនាក់នេះ នៅចាប់អារម្មណ៍លើអ្វីទៀត ? សូមអ្នកប្រាជ្ញពុទ្ធសាសនាវិនិច្ឆ័យចុះ ។

នារីមានទឹកមុខប្រែប្លែកប្រក្រតី ដែលធ្វើឲ្យ ធន-សារឿន មានសេចក្តីសង្ស័យខ្លះ តែការសង្ស័យនេះមិនមែនចំពោះលើសេចក្តីស្នេហានៃនារីទេ ព្រោះនាងដឹងច្បាស់ថាសំណាងជាបងរបស់នារីបង្កើតទៅហើយ តែនាងសង្ស័យថាក្រែងនារីមិនគាប់ចិត្តឲ្យសំណាងទទួលនាងធ្វើជាភរិយា បើសិនជាសំណាងមានជីវិតមកវិញ ; ការពិគ្រោះក្នុងចិត្តរបស់នាងក្នុងពេលនេះ ទុកដូចជាការបង្ហើយោបល់តាមពពកទេ ព្រោះជាហេតុដែលមិនគួរឲ្យមានសេចក្តីសង្ឃឹម

ពេលនេះត្រូវនារីទទួលសេចក្តីទុក្ខយ៉ាងធ្ងន់ម្តង ដោយយោបល់ថា :

បើរកសំណាងឃើញក៏គង់មិនសម្រេចតាមសេចក្តីបំណង បើបាត់រូបសំណាងមែនទែនទៅក៏នាងនៅតែព្រួយ ធ្វើម្តេចហ្ន៎ ! នឹងបានចិត្តនាងធូស្បើយខ្លះ ! សំណាងស្លាប់ក៏នាងទុក្ខ សំណាងរស់ក៏នាងនៅតែទុក្ខ ។

ការស្វែងរកសំណាងដូចជាពុំមានហេតុផលអ្វីសោះ ទុកដូចជាគ្រាន់តែជិះសំពៅទៅរកសេចក្តីទុក្ខឲ្យនារីក្រមុំពីររូបប៉ុណ្ណោះ ; សំពៅបេះតែអណ្តែតទៅ ការស្វែងរកនៅតែគ្មានប្រយោជន៍ ; ឱ ! គ្រោះថ្នាក់ជិតមកដល់ទៀតហើយ ; គេសំឡឹងឃើញជើងខ្យល់ព្យុះកំពុងមានសន្ទុះយ៉ាងលឿន ជំរង់មករកសំពៅអ្នកជិះទាំងឡាយភ័យគ្រប់គ្នា ប្រឹងរត់ធ្វេធ្វាចុះឡើងគួរឲ្យធ្ងល់ណាស់ នារីឈរដោយស្ងុំស្មារតី ស្រាប់តែខ្យល់គួចរូបនាងចេញពីសំពៅធ្លាក់ចុះទៅក្នុងទឹកតែម្តង , ខ្យល់ក៏ស្ងប់ភ្លាម សំពៅមិនបានលិចដូចពេលមុនទេ ស្ងប់ខ្យល់ហើយគេត្រូវប្រមូលគ្នា —

ផ្សៅប្រសើរត្រូវបាត់កូនស្រីទៀតពុំដឹងជាទៅទិសតំបន់ណារកពុំឃើញសោះ អ្នកសំពៅទាំងឡាយបានបោះយុថ្កាដើម្បីចុះទឹករកនាង តែរកទៅនៅតែគ្មានប្រយោជន៍ ; ក្នុងការបាត់រូបនាងនារីលើកនេះ មានមនុស្សដែលព្រួយខ្លាំងជាងគេនោះពីរនាក់ គឺលោកផ្សៅប្រសើរនឹងនាងធន-សារឿន ។

ការទុក្ខព្រួយខ្ញុំមិនបាច់រៀបរាប់ឲ្យវែងឆ្ងាយទៅទៀតទេ តែសូមជំរាបថា ម្តងនេះលោកផ្សៅប្រសើរបានឲ្យសំពៅមួលទៅកាន់កោះមួយនៅទីជិតនេះដើម្បីនឹងរៀបចំសង់ជម្រំមួយសម្រាប់គាត់មកធ្វើបុណ្យឧទ្ទិសដល់វិញ្ញាណក្ខន្ធនៃសំណាងនឹងនារី ។

ផម្រាំនេះគេបានធ្វើពីថ្មរំលេចដោយក្បាច់យ៉ាងចំឡែក នៅក្នុងផម្រាំនោះមានបន្ទប់ពីរយ៉ាងស្អាត ដែលមានសោភាសនៈរៀបបំរុងទុក គេមានយកគ្រឿងឧបភោគ-និងបរិភោគក្រៀមក្រោះខ្លះដាក់ទុកនៅទីនោះ ជាច្រើន ; ភល់តែថ្ងៃពេញបូណ៌មីនឹងខែដាច់ គេឃើញលោកដង្កើកមធ្វើបុណ្យទៅទីនោះ ជួនកាល-នារី ធនសារៀនមកជាមួយផង ។

★ ★ ★

ក្នុងពេលដែលសំណាងបានទទួលគ្រោះថ្នាក់ដំបូង អ្នកផងគេស្មានបានថា អ្នកនឹងបាត់បង់ជីវិតដោយពិតប្រាកដតែបើតាមសេចក្ដីពិតសំណាងមិនបានទទួលគ្រោះថ្នាក់ដូចសេចក្ដីស្មាននោះទេ ពេលដែលអ្នកកំពុងតែឈ្លក់ទឹកស្ទើរតែដាច់ខ្យល់ទៅហើយនោះទទួលមានគល់ឈើមួយលូមឲ្យអ្នក ពឹងប្រាស្រ័យយោងយកជីវិតអ្នកបានហើយក៏បណ្តោយខ្លួនឲ្យរសាត់ទៅតាមយ-ថាហេតុ ។ ក្នុងពេលរាត្រីស្ងាត់ដែលគ្មានពន្លឺព្រះចន្ទ-រះ គល់ឈើមួយនេះបាននាំរូបអ្នកទៅដល់កោះមួយ អ្នកបានឡើងទៅអង្គុយលើថ្មដាមួយផ្ទាំងដែលមិនអាចកំណត់ទិសដំបន់បាន អ្នកបានសំឡឹងមើលទៅលើមេឃឃើញតែផ្កាយដេរដាស មើលជុំវិញ-ខ្លួនឃើញសុទ្ធតែព្រៃឈើហើយនឹងផ្ទាំងថ្ម , ខ្លួនអ្នកត្រូវខ្យល់ត្រជាក់រងាយ៉ាងខ្លាំង ដោយគ្មានសំពត់សម្រាប់ការពារត្រជាក់បាន ព្រោះនៅជាប់នឹងខ្លួនមានត្រឹមតែខោទ្រនាប់មួយប៉ុណ្ណោះ គួរឲ្យវេទនាមែន សេចក្ដីគានតឹងលំបាកវេទនារបស់អ្នកមិនដឹងជាថ្លែងប្រាប់បុគ្គលណាមួយ អ្នកមានតែរុក្ខជាតិសិលាព្រមទាំងមច្ឆាក្នុងទឹកដែលកំពុង ហែលជាមិត្តរបស់អ្នក , ក្នុងពេលដែលកំពុងលំបាកចិត្តដូចនេះ សំណាងបានសំឡឹងមើលចិញ្ចៀន ដែលពាក់នៅដៃស្រាប់តែឃើញរស្មីភ្លឺ ៗ ចេញពីចិញ្ចៀននោះនាំឲ្យអ្នកព្រឺព្រួចក្នុងចិត្តឥតឧបមា, បន្ទាប់មកសំណាងបានរៀបចំខ្លួននមស្ការព្រះរតនត្រ័យ នឹងនឹកដល់គុណបិតាកំសត់របស់ខ្លួន រួចក៏សម្រាកកំលាំងនៅលើថ្មដានោះទៅ ។

ក្នុងពេលដែលអ្នកកំពុងបន្សាត់អារម្មណ៍ ដែលក្រាសក្រែលដោយសេចក្ដីទុក្ខបែបនេះ ស្រាប់តែអ្នកភ្ញាក់ព្រើតព្រោះមានមនុស្សចាស់មួយរូប ស្លៀកសពាក់សកាន់ប្រទីបនៅដៃដើរដំរង់មករកអ្នក , អ្នកក៏ក្រោកក្រាបអភិវន្ទដោយសេចក្ដីគោរព ហើយពោលពាក្យជាសេចក្ដីអង្វរករថា „ សូមលោកតាមេត្តាសង្គ្រោះជីវិតខ្ញុំផង ,, តាប្លែកនេះក៏ឥតមានពោលពាក្យអ្វីច្រើនទៅទៀតដែរ គ្រាន់តែថា “ចូរចៅដើរតាមតាមក ,, គួរឲ្យសំណាងមានសេចក្ដីងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះថា គ្រាន់តែឈានជើងផុតពីកន្លែងដែលខ្លួនអង្គុយអម្បាញ់មិញនេះភ្លាម ក៏ស្រាប់តែជួបប្រទះលើផ្ទៃថ្មដាយ៉ាងស្អាតក្រៃលែង ហើយជាកន្លែង

ដែលនៅក្នុងរូងភ្នំទៀត ទីនោះសោតក៏មិនងងឹត នៅមានពន្លឺដូចជាពេលថ្ងៃ គេបានគន់គេមើលប្រទីបសំរាប់អុចបំភ្លឺក៏ពុំឃើញមានដែរ មិនតែប៉ុណ្ណោះ តាដែលនាំផ្លូវនោះក៏បាត់ពីមុខអ្នកទៀត, ដំហានអ្នកក៏ចេះតែឈានទៅ តែចិត្តអ្នកនៅវិលវល់នៅឡើយ ។ អ្នកបានប្រទះព្រះពុទ្ធរូបបូរាណជាច្រើន ដែលរចនាដោយថ្មកែវយ៉ាងភ្លឺចិញ្ចាច ហើយនឹងវត្ថុមានដម្លៃជាច្រើនផង នៅខាងមុខអ្នកបន្តិចមានព្រះពុទ្ធរូបមាសមួយព្រះអង្គដែលមានព្រះពុទ្ធរូបថ្មកែវតូច ១ ជាច្រើនពទ្ធជុំវិញ នៅខាងមុខព្រះពុទ្ធរូបនោះគេឃើញមានផ្កាស្រស់ៗ ដែលទើបនឹងដោតថ្មីៗនឹងក្លិនធូបកំពុងតែឆេះហុយៗផង, អ្នកចូលមកកន្លែងនេះក៏ក្រាបថ្វាយនមស្ការតាមបវេណី អ្នកព្រះពុទ្ធសាស-នា ហើយក៏ក្រោកដើរទៅមុខទៀត ម្ដងនេះគេត្រូវជួបលើសំលៀកបំពាក់ តាមសម័យបូរាណគ្រប់បែបគ្រប់យ៉ាង ផុតពីនេះទៅស្រាប់តែជួបតាដែលនាំផ្លូវអ្នកមក កំពុងអង្គុយលើគ្រែតូចមួយ នៅខាងមុខតាមានតុតូចដែលដាក់អាហារ និងល្អនៅទីនោះផង និងសំពត់សម្រាប់ស្លៀកមួយប្រដាប់ទៀត, តាប្លែកនេះក៏ធ្វើសញ្ញាឲ្យសំណាង យកសំពត់នោះមកស្លៀកដណ្ដប់ និងឲ្យកាស្រ័យភោជនដែលដាក់នៅទីនោះផង និងទីបំផុតឲ្យសម្រាកខ្លួននៅលើគ្រែតូចនេះរួចក៏វិនាសបាត់ពីទីនោះទៅ ។ សំណាង អ្នកសែនឆ្ងល់ឥតឧបមា ព្រោះជាហេតុដែលខ្លួនពុំដែលជួបប្រទះសោះ ដូនកាលអ្នកក៏នឹកស្មានថានេះជាការសុបិនទេដឹង ? អ្នកបានប្រព្រឹត្តតាមសញ្ញាដែលតាបង្គាប់រួចក៏សម្រាកនៅទីនោះទៅ; កាលបើអ្នកភ្ញាក់ឡើងក៏ស្រាប់តែឃើញតាដដែលនោះ មកប្រាប់ម្ដងទៀតថា ឲ្យរក្សាតូហារនេះផង កាលបើដល់ពេលអាហារចៅឯងត្រូវមកកន្លែងនេះ តែអាហារគេឲ្យចៅឯងបានតែម្ដងទេ ក្នុងមួយថ្ងៃ ហើយទៀងពេលផង ចៅឯងដើរលេងលើភ្នំនេះ បានតែក្នុងពេលរសៀលទល់នឹងយប់ ពេលព្រឹកដើរមិនបានទេនឹងមានគ្រោះថ្នាក់ ចូរចៅនៅក្នុងទីនេះចុះ តាឈប់មកទៀតហើយកាលបើចៅចង់ដឹងហេតុអ្វីមួយ ត្រូវទៅនមស្ការចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបធំនោះនឹងដឹងប្រាកដជាមិនខាន ។

## បុត្រីលោកជង្គៀប្រសើរធ្លាក់លើកណ្ដាប់

ដៃចោរព្រៃ

នារី នាងនឹកឆ្ងល់ខ្លាំងណាស់ :- ហាក់ដូចជានាងគេងលក់ហើយភ្ញាក់ឡើង, ថាកាលដែលខ្យល់ព្យុះតូចនាំនាងចេញចាកសំពៅកាលណា ស្មារតីនាងរលត់ឈឹងក្នុងពេលនោះ ស្រាប់តែធ្លាក់ខ្លួនមកនៅលើកណ្ដាប់ដៃចោរមួយក្រុម ដែលមានសំពត់ខ្មៅពាសមុខដូចគ្នាទាំងអស់ តែបើតាមដែលគេសំគាល់មើលទៅក្រុមចោរទាំងអស់នេះ ដូចជាមិនមែនកាច

សាហាវដល់អ្នកផងគ្រោះប៉ុន្មានទេ ; មេចោរជាបុរសមួយរូបដែលមានសំដីផ្អែមពីរោះ ខណៈដែលគេគ្រាន់តែឮសំដីនោះក្ដាម កូនចោរទាំងឡាយក៏ចិញ្ចឹមជីវិតនៅដោយប្រពៃក្រោមឱវាទមេចោរនោះ , ខ្ញុំមានសិទ្ធិជំរាបលោកអ្នកអានថា : ក្រុមចោរនេះមិនមែនមានករណីដូចជាចោរសាមញ្ញទេ តែដោយខ្លួនមកសម្ងំចាកសង្គមជាតិ ក៏គេសន្មតថាជាក្រុមចោរមួយទៅ , តាមសេចក្ដីពិតចោរនេះមានសមសភាពដូចគេទៅ ។

នាយវិន្ទា ជាបុត្រលោកប្រសិទ្ធ ត្រូវជាបងលោកជនស្វៀប្រសើរបង្កើត នាយវិន្ទានេះបានចេញចាកលោកប្រសិទ្ធជាឪពុក តាំងពីអាយុ ១២ ឆ្នាំ ដោយការដឹកនាំនៃបុរសស្នេហាជាតិមួយរូប បានកាត់ឆ្លងដែនកម្ពុជៈទៅសិក្សានៅប្រទេសថៃ ដល់ពេលដែលខ្លួន ត្រូវត្រឡប់មកកាន់មាតុប្រទេសវិញ ត្រូវគេចោទប្រកាន់ថាខ្លួនជាមនុស្សក្បត់ជាតិ រាជការអាណានិគមបំរុងនឹងចាប់យកទៅបំបរបង់ចោល នៅឯកោះត្រឡាច , គ្រាន់តែអ្នកដឹងរឿងនេះក្ដាមក៏គេចខ្លួនរហូតលុះសព្វថ្ងៃនេះ ឪពុករបស់អ្នកក៏ពុំបានដំណឹងថាអ្នកនៅទីណាដែរ គ្រាន់តែដឹងថាត្រឡប់មកវិញហើយ ៗ ភាសខ្លួនបាត់ទៅ; លោកប្រសិទ្ធក៏ដែលមានបុត្រតែមួយ ដូចជាប្អូនរបស់លោកដែរនោះ ក៏ត្រូវទទួលកិច្ចសន្យាមួយ ដែលបងប្អូនពីរនាក់នេះបាននិយាយគ្នារួចមកហើយ គឺថានឹងផ្សំផ្គុំនារីឲ្យទៅវិន្ទា ក្នុងពេលដែលបុត្រទាំងពីរមានវ័យគ្រមុំ - កម្លោះ ; សព្វថ្ងៃនេះលោកប្រសិទ្ធអនិច្ចកម្ម-ទៅ៣ឆ្នាំហើយ នៅតែលោកស្រីជាភរិយា ។ សេចក្ដីសន្យានោះជាកិច្ចមានខ្លឹមសារក៏ពិតមែន តែ-គង់អ្នកកាន់កិច្ចសន្យានោះ គ្មានសេចក្ដីសង្ស័យ-ថាកូនទាំងពីរជួបគ្នាឡើយ . ចំណែកនារីនឹងវិន្ទា ក៏ពុំបានដឹងច្បាស់ថាខ្លួនទាំងពីរនាក់នេះត្រូវឪពុកម្ដាយផ្សំផ្គុំពីកុមារនោះដែរ ចុះបើនារីធ្លាក់មកក្នុងកណ្ដាប់ដៃវិន្ទាហើយ នោះនឹងដូចម្ដេចទៅ ? រឿងនេះសូមអ្នកអានចាំពិនិត្យទៅទំព័រខាងចុងចុះ គង់នឹងវិនិច្ឆ័យពាក្យសន្យានោះជាប្រាកដ ។

នាយវិន្ទាសព្វថ្ងៃនេះបានតាំងខ្លួនជា ជាមនុស្សនៅក្រៅរបងរបស់អាណានិគម អប់រំជនអ្នករួមករណីគ្នោះទៅរកឯករាជ្យ ក្រុមពួកនេះមិនដែលទៅរំជាន់ ឬប្លន់យកសម្បត្តិនៃជនជាតិណាបន្តិចឡើយ ការចិញ្ចឹមជីវិតរស់ដោយរបរនេសាទត្រី, ត្រីដែលចាប់បានមក យកទៅប្រឡាក់ធ្វើងៀតហើយនាំទៅលក់នៅដែនយួន រួចទិញគ្រឿងឧបភោគបរិភោគមកចិញ្ចឹមគ្នាជាសុខនៅទីនោះ ក្រុមនេះមានលំនៅរួមជាមួយនឹងកោះដែលសំណាងកំពង់តែអាស្រ័យនៅសព្វថ្ងៃនេះ តែនៅចុងកោះម្ខាងម្នាក់ ; កោះនោះមានបណ្ដោយប្រហែល ១៥ គ.ម. ទទឹង

ប្រហែល២-៣ គ.ម. ប៉ុណ្ណោះ ជនអ្នកនៅក្នុងកោះនោះ ក៏ពុំសូវបានដើរពិនិត្យឲ្យសព្វគ្រប់ចំពោះស្ថានភាពក្នុងកោះនោះដែរ ។

នាយវិន្ទា បាននាំស្ត្រីរងគ្រោះនេះទៅដល់ផ្ទះរបស់ខ្លួន បានសាកសួរនាងនារី តាំងពីដើមរៀងរហូតដល់ពេលដែលនាងត្រូវលង់ទឹក នាងក៏បានរៀបរាប់តាមដំណើរសព្វគ្រប់ ។ នាយវិន្ទានិមិត្តតែបានស្ដាប់ពាក្យនោះភ្លាម អ្នកសែនរំជួលចិត្តឥតឧបមា ដោយអ្នកស្គាល់ថា នេះជាប្អូនស្រីរបស់អ្នក សេចក្ដីមេត្តាក៏កើតពោរពេញទាំងខ្លួន ; ដំបូងឡើង ពេលដែលអ្នកជួយសង្គ្រោះនាងនារីភ្លាមអ្នកនឹកក្នុងចិត្តថា នឹងសួរចិត្តនាងដើម្បីទុកធ្វើភរិយា ដល់ដឹងច្បាស់ថា ជាប្អូនដ៏ជួនមួយអ្នកទៅវិញ អ្នកក៏រសាយបាត់នូវសេចក្ដីស្នេហានោះ ទៅជាអាណិតស្រឡាញ់ដូចបងប្អូនបង្កើតរបស់ខ្លួនទៅវិញ : តែអ្នកពុំបានប្រាប់ហេតុនោះដល់នាងឡើយ គ្រាន់តែឲ្យអារក្ខានឹងទីនៅអាស្រ័យជាសុខស្រួលប៉ុណ្ណោះ ។

តាំងពីនាងបានមកនៅក្នុងទីនោះមកនាងឈប់ស្លៀកពាក់ជាស្រីហើយ សូម្បីសក់ក៏នាងកាត់ជាប្រុសដែរ នាងបានហាត់ជិះសេះនឹងកាន់អាវុធបានយ៉ាងចំណាប់ សេះទាំងឡាយទិញដាក់ទូកយកពីប្រទេសយួនមក សេះនៅទីនោះមានចំនួនត្រឹមពីរប៉ុណ្ណោះទេ សម្រាប់អ្នកហាត់ជិះ នាយវិន្ទាបានតាំងនាងជានាយគប្រួតរង គេហៅនាងថា នាយនារី ។

រាល់យប់ថ្ងៃនារីមានចិត្តបែកជាពីរចំណែក : ណាមួយនាងនឹកដល់សំណាង ដែលធ្វើទុកចិត្តឲ្យនាងលួចជាប់នូវសេចក្ដីស្នេហា តែសេចក្ដីស្នេហានោះដូចជាគ្មានសេចក្ដីសង្ឃឹមដល់រូបនាងសោះមួយបែបទៀត ចិត្តនាងដូចជាទន់ទៅលើនាយវិន្ទាខ្លះដែរ; រឿងនេះ បើប្រសិនជានាងពុំបានជាប់ជំពាក់ចិត្តលើសំណាង ប្រហែលជានាងប្រថុយបង្ហាញអាការៈស្ទាក់ក៏បាំងឲ្យនាយវិន្ទាស្គាល់ចិត្តនាងជាមិនខាន ។

ការស្និតស្នាលដោយសំដីរវាងនាយវិន្ទានឹងនារី ក៏រឹតតែចំរើនឡើងជាលំដាប់ ពាក្យបងនឹងអូនបានហៅរកគ្នាដោយមិនមានគ្គង់សោះ ជាយូរមកហើយ នាយវិន្ទា ក៏រឹតតែរសាប់រសល់ក្នុងខ្លួនព្រោះតែនារីនាំឲ្យភាយពកគរបស់អ្នករឹតតែដុតពេលជារាល់ថ្ងៃឥឡូវនេះអ្នកមានចិត្តលួចលើនារីខ្លះហើយ តែអ្នកមិនហានសំដែងទឹកចិត្តនោះឲ្យនាងដឹង ព្រោះនឹកដល់ ដម្លៃវង្សត្រកូល ដោយអ្នកយល់ឃើញថា បើលោកលើបវេណីរបស់នាង ទុកដូចជាអ្នកបំផ្លាញបវេណីរបស់អ្នកដែរ , នេះហើយដែលធ្វើឲ្យនាយវិន្ទាស្រពោនក្នុងចិត្តមិនសូវសប្បាយ ។

នៅរាជធានីភ្នំពេញ ពុំសូវមានការប្លែកប៉ុន្មានៗ

នៅគេហស្ថានលោកធន-សម្បត្តិ ក៏រឹតតែ

មានបរិយាកាសថ្មីតប្រក្រតី, គេដូចជាធៀនចូលក្នុងផ្ទះនោះដែរ ដោយមានមនុស្សចុះឡើងក្នុងគេហស្ថានលោកយ៉ាងច្រើន ។

ការនេះគឺលោកធនសម្បត្តិមានជម្ងឺ, កាលលោកទៅឯកិតតពីគ្រាបាត់សំណាង លោកបានអញ្ជើញតាមសមុទ្ទជាមួយនឹងគ្រួសារកំសត់នោះទទួលពេលដែលខ្យល់ព្យុះគួចយករូបនាងនារីបាត់ទៅ លោកហាក់ដូចជាស្លុតស្មារតីហួសប្រមាណ នាំឲ្យមានរោគក្នុងទ្រូងតាំងពីពេលនោះមក នេះមកពីការជួយភ័យ, ជួយស្តាយ, ជួយស្រណោះគេ បណ្តាលឲ្យទៅជាមានរោគក្នុងខ្លួនឡើងយើង រោគនោះបក្តឡើងដូចជាមនុស្សមាយា, ពេលណាឈឺក៏ឈឺទៅ ពេលណាជាក៏លោកតែងប្រកបកិច្ចការតាមធម្មតាទៅ, វេជ្ជបណ្ឌិតជាច្រើន បានតាល់គំនិតចំពោះការពិនិត្យរោគនោះណាស់, គ្រឿងចក្ររបស់លោកខាងក្នុងក៏បេះតែខ្សោយទៅជាលំដាប់; សព្វថ្ងៃនេះការជំនួញគ្រប់យ៉ាងត្រូវនាងនីធនសារ-រៀងចាត់ការទាំងអស់, នាងជានារីមួយរូបស្គាល់ការប្រមាណរបស់ខ្លួន នាងបានប្រមូលប្រាក់ដាក់ធនាគារជាច្រើន សម្រាប់យកក៏ទ្រមកប្រើប្រាស់, ទៅសល់តែប្រាក់ដែលពាក់ព័ន្ធខាងផ្ទះសមាគម ជំនួញផ្ទាប់មុខនាងបានដកចេញអស់ហើយ ។

(នៅមានត)

## សញ្ញាការពារអាស៊ីភាគអគ្នេយ៍ (ត)

កាលបើខ្លួនយើងមិនមានឥស្សរភាព, សេរីភាព ឬមានសេចក្តីខ្វាប់ខ្លួនក្នុងផ្ទៃសេដ្ឋកិច្ច ក្នុងផ្ទៃសង្គមសោះដូច្នេះ? ចំពោះពាក្យសួរនេះ បើប្រជាជនប្រទេសណាទៅទីទៃក្នុងស្ថានភាពរបស់ខ្លួនហើយ មិនងាយជាប់ចិត្តធ្វើអ្វីឡើយ, ឬបើធ្វើទៅក៏ដោយមិនពេញចិត្តដែរ ។ ដូច្នេះឯងទើបប្រទេសថៃ សុំឲ្យអ្នកតំណាងរបស់ខ្លួនសំដែងឲ្យប្រាកដដល់ទីប្រជុំ ថារដ្ឋាភិបាលថៃនោះ មានបំណងនឹងជួយឧបត្ថម្ភ ព្រមទាំងមានសេក្តីតាំងចិត្តដ៏ពិតប្រាកដ ក្នុងការដែលនឹងបានឃើញប្រទេសទាំងឡាយមានសិទ្ធិស្មើភាគបានទទួលសេចក្តីយុត្តិធម៌ នឹងមានសេចក្តីពេញចិត្តចំពោះឯករាជ្យរបស់ខ្លួន ។

គេចាំបានថា ការចុះហត្ថលេខាក្នុងសន្ធិសញ្ញានេះ ប្រទេសថៃយល់ថា គួរតែប្រកាសឲ្យសាកលលោកបានជ្រាប ដើម្បីពង្រឹងនឹងបញ្ជាក់ចំពោះប្រទេសទាំងនោះៗថា យើងស្រឡាញ់ឥស្សរៈភាពនឹងសេរីភាពៗ

សេចក្តីយល់នេះ, បានកើតផលគឺនៅទីបំផុតប្រទេសអង់គ្លេស, បារាំងសេស បានប្រកាសនូវវិត្តបំណងរួមគ្នាថា នឹងជួយឲ្យប្រទេសទាំងឡាយបានមានឯករាជ្យនឹងសេរីភាពដោយរហ័សរួសរាន់ ៗ ហើយមនោសញ្ចេតនានេះកាលបើស្របគ្នាក៏មានការព្រាងធម្មនុញ្ញប៉ាស៊ីហ្វិកចេញមក ដែលជាផ្លូវដ៏ល្អជា

ទីបំផុតក្នុងការប្រកាសនូវវត្ថុបំណងរួមគ្នា ចំពោះឯករាជ្យនិងសេរីភាពរបស់ប្រទេសទាំងឡាយ ។

ធម្មនុញ្ញប៉ាស៊ីហ្វិក ជាឯកសារមួយច្បាប់ដំបូងបំផុតដែលបានចុះហត្ថលេខា មានសេចក្តីសំខាន់ថា

ដោយអ្នកតំណាងប្រទេសអូស្ត្រាលី , បារាំង-សេស , នូវែលស៊ីឡង់ , ប៉ាគីស្ថាន, សាធារណរដ្ឋហ្វីលីពីន , រាជអាណាចក្រថៃ , សហរាជ-អាណាចក្រប្រីតានីកធំ និងអៀរឡង់ខាងជើង ហើយនិងសហរដ្ឋអាមេរិក មានសេចក្តីប្រាថ្នា នឹងស្ថាបនានូវមូលដ្ឋានដ៏ខ្ជាប់ខ្ជួន ដើម្បីប្រតិបត្តិការរួមគ្នាក្នុងការទ្រទ្រង់និងរក្សានូវសន្តិភាព ព្រមទាំងជាវរៈភាពនៃតំបន់អាស៊ីភាគអាគ្នេយ៍ និងប៉ាស៊ីហ្វិកទិសនិរតីនោះ , ទាំងអស់គ្នាបានមានសេចក្តីយល់យ៉ាងជាក់ច្បាស់ថា ការប្រតិបត្តិរួមគ្នាក្នុងកិច្ចនេះ ដែលនឹងឲ្យមានគុណប្រយោជន៍ ហើយនឹងកើតផលដ៏បរិបូណ៌ ត្រូវប្រកាន់ខ្ជាប់ក្នុងគោលការណ៍ខ្ពស់បំផុតខាងយុត្តិធម៌និងសេរីភាព ។

សូមប្រកាសក្នុងទីនេះថា ៖

មាត្រាទី ១ — ដោយន័យនៃបទបញ្ញត្តិរបស់ធម្មនុញ្ញសហប្រជាជាតិ , អ្នកតំណាងដូចពោលមកខាងលើបានលើកស្ទួយគោលការនៃសិទ្ធិស្មើភាគគ្នា. និងកំណត់ការតាមចិត្តខ្លួននៃប្រជាជន , ព្រមទាំងមានតែចំណងដោយមាំមួនទៅគ្រប់វិធីនៃសន្តិ ដើម្បីស្ទួយរបបគ្រប់គ្រងខ្លួនឯង ឲ្យបានមកនូវឯករាជ្យនៅគ្រប់ៗប្រទេសដែលប្រជាជនមានសេចក្តីប្រាថ្នាឯករាជ្យនោះ ហើយដែលនឹងអាចរ៉ាប់រងទទួលខុសត្រូវចំពោះឯករាជ្យនោះបាន ។

មាត្រា ២ — អ្នកតំណាងនៃប្រទេសនីមួយៗ បានព្រមព្រៀងគ្នាក្នុងកិច្ចដំណើរមាត្រាការដ៏សមស្របហើយឲ្យកើតផលតទៅ ដើម្បីតាមទាន់និងសការៈហេតុដែលជាការអនុគ្រោះដល់ សេចក្តីសំរេចដោយមានរបៀបនៃវត្ថុបំណងដូចពោលមកហើយ , តាមរបបគ្រប់គ្រង អាស្រ័យរដ្ឋធម្មនុញ្ញនៃប្រទេសរៀងខ្លួន ។

មាត្រា ៣ — អ្នកតំណាងដូចពោលមកហើយ នឹងរួមគ្នាតទៅ ក្នុងការសេដ្ឋកិច្ច , ការសង្គមនិងកិច្ចការខាងវិជ្ជនៈធម៌ ដើម្បីបណ្តុះបណ្តាលមាត្រដ្ឋាននៃការរស់នៅរួមគ្នាឲ្យល្អក្រៃលែងដើម្បីវឌ្ឍនាការនៃសេដ្ឋកិច្ចនិងសុវត្ថិភាពខាងសង្គមនិងភូមិភាគនេះ ។

មាត្រា ៤— តាមដែលបានថ្លែងមកហើយក្នុងសន្ធិសញ្ញារួមគ្នាការពារតំបន់អាស៊ីភាគអាគ្នេយ៍នោះ , អ្នកតំណាងទាំងឡាយបានព្រមព្រៀងគ្នានឹងធ្វើការ ការ-ពារប្តូរមួយតស៊ូដោយមធ្យោបាយគឺសមគួរ ក្នុងក្រប-ខណ្ឌនៃសន្ធិសញ្ញានេះ ចំពោះសេចក្តីព្យាយាមឯណានីមួយដែលរុកគួនសេរីភាពឬទំលាយអធិបតេយ្យ ឬ-ទំលាយបូរណៈភាពនៃអាណាខេត្តរបស់ខ្លួន ។

## គាយខេមរៈជាតិប្លែងតមកទៀតបា

តាមឯកសារដូចពោលមកនេះ ឃើញថា នយោបាយរដ្ឋាភិបាល ថៃដែលបានគាំទុកនោះ បានសម្រេចផលដូចប្រាថ្នា ។ មួយទៀតប្រទេសផល វាភាគីនៃសញ្ញានេះ ដែលគេមានដែនដីនៅក្នុងគ្រប់គ្រងរបស់ខ្លួនក៏បានព្រមព្រៀងចុះហត្ថលេខា ហើយប្រកាសនូវវិត្តបំណងនៃខ្លួនថា នឹងឲ្យឯករាជ្យឲ្យសេរីភាពដល់ប្រទេសទាំងឡាយ តាមវិថីសន្តិ ហើយយ៉ាងរហ័សជាទីបំផុត ។ ដូច្នេះធម្មនុញ្ញនេះ ទើបមានដំឡៃច្រើនចំពោះកិច្ចការដែលយើងរួមគ្នាចុះហត្ថលេខាក្នុងសន្ធិសញ្ញាជួយគ្នាការពារអាស៊ីភាគអគ្នេយ៍តទៅ ។

មួយទៀត ចំពោះការចុះហត្ថលេខាក្នុងសន្ធិសញ្ញានេះ ឃើញថាប្រកបដោយបរិយាកាសដ៏ល្អលើសលុប គឺគ្រប់ៗនៃប្រទេសដែលទៅរួមប្រជុំគ្នាពុំបាន រករឿងហេតុឯណាមកប្រកែកប្រណាំងឡើយ គឺគ្រប់ប្រទេសសុទ្ធតែរកផ្លូវព្រមព្រៀងគ្នា ដើម្បីធ្វើឲ្យសន្ធិសញ្ញានេះ បានល្អតាមដែលខ្លួនអាចនឹងរកបាន ។ សំដែងឲ្យឃើញថាចេតនានៃប្រទេសផ្សេងៗ ដែលនៅរួមធ្វើសន្ធិសញ្ញានេះ គឺជាចេតនារួមគ្នាជួយឧបត្ថម្ភ នឹងជួយការពារកុំឲ្យលទ្ធិកុម្មុយនីស្តជ្រាបចូលមកបានតែម្យ៉ាង ។ កាលដែលចុះហត្ថលេខាស្រេចហើយ , គ្រប់ប្រទេសបានថ្លែងបិទសម័យប្រជុំយ៉ាងពីរោះ , ដោយពោលសរសើរនិងថ្លែងអំណរចំពោះ សហរដ្ឋអាមេរិក , ដែលកាលបើសារុបសេចក្តីទៅដូច្នេះ ៖

— បើមិនមែនសហរដ្ឋអាមេរិកជាអ្នកផ្តួចផ្តើមហើយ ការធ្វើសន្ធិសញ្ញានេះ មុខជាមិនបានកើតផលឡើយ ។ លោកដ៏លឿសបានបញ្ជាក់ថាសន្ធិសញ្ញានេះ ជាសេចក្តីព្រមព្រៀងដែលរួមគ្នា ដើម្បីជួយការពារនូវគ្នានឹងគ្នា , ចំណែកឯអ្នកមិនពេញចិត្តនោះគឺកុម្មុយនិស្តដែលជាអ្នកមេរុកកនគេប៉ុណ្ណោះឯង ។

តាមដែលដំរាបមកនេះ , ឃើញថាពួកដែលរួមគ្នាចុះហត្ថលេខាទាំងអស់គ្នាគឺមានចិត្តមូលមួយជាឯកច្ឆន្ទ ។ ចំណែកការជួយឧបត្ថម្ភ , និងការរួមចិត្តគ្នាក្នុងផ្លូវទាហានក្តី , ក្នុងផ្លូវសេដ្ឋកិច្ចក្តី , ក្នុងផ្លូវសង្គមក្តី, ដែលបានចុះហត្ថលេខាជាសញ្ញាទុករួចហើយនោះនឹងបង្កើតផលយ៉ាងរហ័សហើយពិតប្រាកដជាបំផុតដែលស្មានថានឹងយឺតយូរឬកើតហេតុដ៏ចំរដុបផ្សេងនោះ , មិនអាចកើតមានឡើងទេ ព្រោះថាប្រទេសធំៗ គេមុខជាកាន់នូវសច្ចៈចំពោះមុខការរបស់គេ ដោយគេមិនមែនទុកចោលឲ្យនៅជាតួអក្សរក្នុងក្រដាសនោះឡើយ ។

សម្រាប់វិធីសារ (Protocole) នៅខាងចុងសន្ធិសញ្ញានោះ , បានកើតមានឡើងដោយមុនដំបូង គេប្រជុំនិងចុះជាបទបញ្ញត្តិក្នុងមាត្រានៃសន្ធិសញ្ញាថា ឲ្យប្រទេសកម្ពុជា - លាវ - និងវៀតណាម

សេរី នៅក្នុងខេត្តដែលមានគួសរួចហើយ ហើយនឹងឲ្យបានប្រយោជន៍ , បានទទួលការការពារក្នុងផ្លូវពាហន , ហើយមានទារណាមករុករានប្រទេសទាំងបីនេះហើយ នឹងឲ្យបានទទួលនូវការជួយឧបត្ថម្ភក្នុងផ្លូវសេដ្ឋកិច្ច នឹងសង្គមផង ។ ប៉ុន្តែប្រទេសទាំង ៣ ពុំបានមកចុះហត្ថលេខាក្នុងសញ្ញានេះ , ទើបខាងបារាំងនឹងអង់គ្លេសមានសេចក្ដីយល់ថា បើនឹងយកឈ្មោះប្រទេសទាំងបីនេះមកដាក់ក្នុងមាត្រានៃសន្ធិសញ្ញានេះ រួចដែលមានអ្នកដំណាង ៨ ប្រទេសជាអ្នកចុះហត្ថលេខារួចហើយ នឹងនាំទៅជាការទំនាស់ដល់សញ្ញាស្ងប់សឹក ដែលព្រមព្រៀងគ្នានៅហ្សឺណែវ ដូច្នេះបារាំងសេសទើបសុំឲ្យញែកចេញទៅជាពិធីសារដោយឡែកមានសេចក្ដីថា ៖

«ភាគីនៃសន្ធិសញ្ញាការពាររួមគ្នាក្នុងអាស៊ីអាគ្នេយ៍ យល់ព្រមជាឯកច្ឆន្ទ ឲ្យប្រទេសកម្ពុជា , លាវ , នឹងអាណាខេត្តសេរី ដែលនៅក្រោមអំណាចតុលាការវៀតណាមនៅក្នុងវត្ថុបំណងនៃមាត្រា ៤ នៃសន្ធិសញ្ញានេះ ,

ភាគីបានព្រមព្រៀងគ្នាទៀតថា រដ្ឋនឹងអាណាខេត្តដូចពោលមកពីខាងដើម ត្រូវស្ថិតនៅក្នុងក្របខណ្ឌដែលទាក់ទងមាត្រដ្ឋានសេដ្ឋកិច្ចដែលមានកំណត់ទុកក្នុងមាត្រា ៣ ។

ពិធីសារច្បាប់នេះ នឹងមានចាត់ឲ្យអនុវត្តព្រមគ្នានឹងសន្ធិសញ្ញា ។

ដើម្បីជាសក្ខីភាពចំពោះការនេះ , អ្នកមានអំណាចពេញទីដែលមាននាមខាងក្រោមនេះ បានចុះហត្ថលេខាក្នុងពិធីសារបន្ទាត់ខាងក្រោយ សន្ធិសញ្ញារួមគ្នាការពារអាស៊ីអាគ្នេយ៍ ច្បាប់នេះហើយ ។

X X

X

តាមសន្ធិសញ្ញា នឹងពិធីសារជាគ្រឿងរណបនេះ សឲ្យឃើញថាគេព្រមទទួលថា ប្រទេសកម្ពុជា , លាវ នឹងវៀតណាមសេរីនោះ បានទៅនៅក្នុងសេចក្ដីឃុំគ្រងនៃសន្ធិសញ្ញានេះផង ដូចគ្នានឹងប្រទេសភាគីដទៃៗ ។ ដូច្នេះបើមានការប្រតិបត្តិឯណាជាការគំរាមដល់និរភ័យនៃប្រទេសទាំង ៣ ហើយ , ប្រទេសទាំងឡាយដែលជាភាគីនឹងប្រកាន់ថាដូចជាការរុករានខ្លួនឯងដែរ ហើយនឹងដំណើរការទៅតាមវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន ។

អាចមានបញ្ហាថា បើប្រសិនណាជាប្រទេសណាមួយត្រូវកុម្មុយនិស្ដ៍រុករាន ហើយរដ្ឋាភិបាលនៃប្រទេសនោះពុំបានហៅឲ្យប្រទេសភាគីសន្ធិសញ្ញាទៅជួយ តើយើងនឹងបញ្ជូនទាហានចូលទៅជួយបានឬទេ? ចំពោះការនេះគេយល់ថា បើប្រទេសណាមួយត្រូវរុករាន ហើយប្រទេសនោះពុំហៅឲ្យជួយទេ យើងក៏ពុំអាចជួយដោយទាន់ហន់ដែរ ។ ប៉ុន្តែមុខជាគេហៅឲ្យជួយជាប្រាកដដោយមិនបាច់គិតទេ

នាយខេមរជាតិបានបន្តសេចក្តីទៅទៀតថា៖

ក្រៅពីនេះមាននិយាយពីតាំងគណៈមន្ត្រីបរិហារការងារតាមសន្ធិសញ្ញា ដែលគ្រប់ប្រទេសត្រូវតាំងអ្នកតំណាងឲ្យទៅជាមន្ត្រី ៗ គណៈមន្ត្រីនេះនឹងមានការប្រជុំគ្រប់ពេល កាលបើឃើញថាគួរ ហើយ-ត្រូវមានមន្ទីរធ្វើការនៅទីដ៏មួយកន្លែងផង ។

កិច្ចតាំងប៊ុយរ៉ូនេះ, ប្រទេសអូស្ត្រាលីសូមឲ្យតាំងនៅឯប្រទេសខ្លួន ចំណែកហ្វីលីពីនសុំឲ្យតាំងនៅហ្វីលីពីន ហើយប្រទេសថៃក៏សុំឲ្យតាំងនៅថៃដែរ គ្រង់ណេះនៅពុំទាន់ដាច់ស្រេចទេ គឺនៅធ្វើកិច្ចចរចារខាងផ្លូវទូតថាតើនឹងឲ្យមានប្រជុំជាដំបូងនៅឯណា ?

សារបសេចក្តីថា, ធម្មនុញ្ញប៉ាស៊ីហ្វិកនេះជាការសំដែងនូវមនោសញ្ចេតនារបស់ប្រទេសដ៏ជាភាគីដែលប្រាថ្នានឹងឲ្យឥស្សរៈភាព, សេរីភាពក្នុងការកំណត់ឲ្យប្រទេសនានាគ្រប់គ្រងខ្លួនឯងដោយឥស្សរមានអធិបតេយ្យពេញលេញ ។

មួយទៀតគោលការណ៍រួមគ្នាក្នុងការសេដ្ឋកិច្ចនឹងសង្គមហើយនឹងវប្បធម៌ ព្រមទាំងគោលការណ៍ការពារតស៊ូចំពោះកិច្ចប្រងទំលាយសេរីភាពរបស់ប្រទេសហើយនឹងវត្ថុបំណងក្នុងធម្មនុញ្ញប៉ាស៊ីហ្វិកនេះគឺដើម្បីសំដែងឲ្យសាកលលោកនឹងប្រទេសក្នុងអាស៊ីអាគ្នេយ៍ឃើញថា វត្ថុបំណងនៃការធ្វើសន្ធិសញ្ញានេះមិនចំពោះតែជាការការពាររួមគ្នាក្នុងផ្លូវទាហានប៉ុណ្ណោះទេ គឺនឹងទំនុកបំរុងឥស្សរភាពនឹងសេរីភាពរហូតដល់ការរួបរួមគ្នាក្នុងផ្លូវសេដ្ឋកិច្ច, ផ្លូវសង្គមទៀត ៗ ហើយដែលមិនបានបញ្ញត្តិទុកក្នុងសន្ធិសញ្ញាទាំងអស់ផង ព្រោះប្រទេសខ្លះបានពោលថា មិនមានអំណាចនឹងចុះហត្ថលេខាក្នុងសេចក្តីដទៃក្រៅពីសេចក្តី ដែលបានទទួលអនុម័តហើយ ; ទើបបានផ្លាស់ប្រើជាសេចក្តីថ្លែងរបស់ប្រទេសទាំង ៨ ដែលសំដែងនូវមនោសញ្ចេតនាក្នុងការប្រតិបត្តិតាមករណីសម្ពន្ធដែលត្រូវមានចំពោះសហប្រជាជាតិទៅវិញ ។

នាយពច់ន-សារសិន ឯកអគ្គរាជទូតថៃប្រចាំវ៉ាស៊ីងតោនបានបញ្ជាក់ដល់ការធ្វើសន្ធិសញ្ញានេះថា សន្ធិសញ្ញានេះបានធ្វើឡើងដោយមានវត្ថុបំណង ៣ ប្រការ គឺជួយតទប់ការរុករានដោយវិធីប្រើកំឡាំងបើមានការរុកគួនដើម្បីរំលំរដ្ឋាភិបាល. ដើម្បីរំលំរបបសេរីប្រជាធិបតេយ្យ ៗ មួយទៀតជួយគ្នាការពារភយន្តរាយផ្សេង ៗ ។ ទី ៣ គឺដោយហេតុប្រទេសទាំងអស់នេះមានគំនិតនឹងតស៊ូលទ្ធិកុម្មុយនិស្តនោះ, ជីវភាពនៃប្រជាជនរមែងជាគ្រឿងសំខាន់ ព្រោះហេតុនោះទើបមានមាត្រាខ្លះពោលដល់ការអនុគ្រោះក្នុងផ្លូវសេដ្ឋកិច្ចផង គឺគ្រាប់ប្រទេសត្រូវជួយអនុគ្រោះខ្លួនឯង នឹងរួមគ្នាជួយអនុគ្រោះ ដើម្បីឲ្យមាត្រដ្ឋានជីវភាពរបស់ប្រជាជននៃប្រទេសនោះ ៗ បានល្អឡើងដែលមានលក្ខណ៍ហានដូចតទៅនេះ៖

# សន្ធិសញ្ញារួមគ្នាការពារអាស៊ីភាគអាគ្នេយ៍

ភាគីនៃសន្ធិសញ្ញានេះ ព្រមទទួលរាប់អាននូវសេចក្ដីស្មើភាគខាងអធិបតេយ្យនៃភាគីទាំងអស់ ។ គោលបញ្ជាក់ដោយចេសក្ដីជ្រះថ្លា ក្នុងវត្ថុបំណងនិងគោលការណ៍តាមដែលមានត្រាទុក ក្នុងធម្មនុញ្ញសហប្រជាជាតិ និងក្នុងសេចក្ដីប្រាថ្នាដែលនឹងរស់នៅរួមគ្នាក្នុងសន្តិភាពជាមួយបណ្ដាប្រជាជាតិនិង រដ្ឋាភិបាលទាំងឡាយ ។

អះអាងថា តាមន័យរបស់ធម្មនុញ្ញសហប្រជាជាតិ, ភាគីត្រូវលើកដំកើងនូវគោលការនៃសិទ្ធិដ៏ស្មើភាគ. និងការកំណត់នូវការប្រព្រឹត្តតាមចិត្តខ្លួន នៃប្រជាជន ហើយនឹងប្រកាសថា ភាគីនឹងរិតនូវចំណងសន្តិភាព គ្រប់យ៉ាងដោយសច្ច : ដើម្បីទំនុកបំរុងការគ្រប់គ្រងខ្លួនឯង និងឲ្យបានមកនូវឯករាជ្យនៅគ្រប់ប្រទេស ដែលប្រជាជនមានសេចក្ដីប្រាថ្នានូវឯករាជ្យ ហើយដែលអាចទទួលការខុសត្រូវនោះបាន ។

ប្រាថ្នានឹងរិតនូវចំណងសន្តិភាពដែលគ្រោងទុក និងសេរីភាពឲ្យរឹងប៉ុងមាំមួនក្រៃលែងឡើង ហើយនឹងដំកើងគោលការណ៍ប្រជាធិបតេយ្យ, សេរីភាពរបស់មនុស្សម្នាក់ម្នាក់ និងគ្រប់ខណ្ឌនៃច្បាប់ ហើយនឹងដំកើងនូវសុវត្ថិភាពខាងផ្លូវសេដ្ឋកិច្ច និងវឌ្ឍនាការរបស់ប្រជាជនទាំងអស់ក្នុងគ្រប់ខណ្ឌនៃសន្ធិសញ្ញា ។

មានចេតនានឹងប្រកាសដោយបើកចំហរ ហើយជាផ្លូវការនូវសម្បជញ្ញ ក្នុងឯកភាពដើម្បីឲ្យមនុស្សដែលគិតនឹងរុករានគេ ដោយវិធីណាមួយបានដឹងខ្លួន ហើយនឹងសង្រ្គមចិត្តដោយគិតថា ភាគីទាំងអស់ឈរក្រោញរួមក្នុងខេត្តការពារនោះ ។

ប្រាថ្នាតទៅទៀតក្នុងការផ្សារភ្ជាប់នូវសេចក្ដីព្យាយាមដើម្បីកិច្ចការពាររួមគ្នា និងដើម្បីរក្សាសន្តិភាពហើយនឹងសេក្ដីខ្ជាប់ខ្ជួន ។

ដូច្នេះទើបព្រមព្រៀងគ្នាដូចតទៅ ៖

មាត្រា ១ តាមដែលមានត្រាទុកក្នុងធម្មនុញ្ញសហប្រជាជាតិ , ភាគីទាំងឡាយរាប់រងនឹងរម្ងាប់ការរំខានរវាងប្រទេសណា ៗ ដែលភាគីអាចមានកិច្ចទាក់ទងដោយសន្តិវិធដើម្បីមិនបង្កឲ្យកើតភ័យចំពោះសន្តិភាពនឹងសេក្ដីខ្ជាប់ខ្ជួនរវាងប្រទេស និងចំពោះសេចក្ដីយុត្តិធម៌ ។ ហើយព្រមនឹងលះបង់នូវពន្ធៈរវាងប្រទេសរបស់ខ្លួន អំពីការគំរាមកំហែល ឬការប្រើកំឡាំងបង្ក្រាប់ក្នុងទំនងណា ៗ ដែលទទឹងទាស់នឹងគោលបំណងរបស់សហប្រជាជាតិ ។

មាត្រា ២ ដើម្បីដំណើរកិច្ចការឲ្យបានផលក្រៃលែងឡើងតាមវត្ថុបំណងនៃសន្ធិសញ្ញានេះ, ភាគីរៀងខ្លួនដែលរួមគ្នា ត្រូវជួយខ្លួនឯងនឹងជួយនូវគ្នានឹងគ្នាដើម្បីប្រសិទ្ធប្រសាទនូវផល ដែលជាប់ទាក់

ទង្គា ហើយនឹងរក្សាព្រមទាំងធ្វើឲ្យវឌ្ឍនានូវ
សមគ្គភាពដោយឯកទេសប្ដូរមគ្គា តស៊ូទប់ទល់នូវការ
រុករានដោយប្រើអាវុធ នឹងការពារទប់ទល់នឹងកិច្ចរុក
គួន ដែលមានមកពីក្រៅ ។

ប្រកាសនៅក្រុងមាទិល នៅថ្ងៃទី ៦ កញ្ញា
គ, ស, ១៩៥៤

(មានត)

## រឿងស្រីកំសត់

(១) អតីតេ កាលេ បពិត្រអើយ ! គ្រាអតីតសម័យ ភ្នំព្រឹទ្ធគប់គន្ធកប្បូរណ្ណកំបាំងបាត់ស្ងាត់កន្ទ្រលលង់យូរលង់ណាស់ហើយ មានស្រីកំសត់ទុគ៌តម្នាក់ជាស្រីមេម៉ាយ , ក្រោយដែលគស្វាមីក្ស័យផុនជីពទៅ , នាងនៅតែជាមួយកូនប្រុសតូចពីរនាក់ ម្នាក់នៅធ្មៅដោះនៅឡើយ ម្ល៉ោះហើយនាងម្ដាយត្រូវតែខ្វល់ខ្វាយធ្វើការជាអម្រេសអម្រេលៀ-ងដើម្បីចិញ្ចឹមខ្លួននិងកូនទាំងពីរ សែនហៅពិបាកពិបិនយាប់យ៉ិនពន់ពេក , ជួនកាលកូនឃ្លានស្រេកស្រេកទ្រហោយំទ្រហឹងអឹងកាប់សត្វស៊ិន , ជួនណា នាងរកបានល្មមឆ្អែតពោះ , ជួនកាលរកមិនស្ទើបានសោះក៏រហេមរហាមអត្តខាត . នាងក៏បរិ-ភោគខ្លួនឯង មួយម៉ាត់ពីរម៉ាត់គ្រាន់តែសង្កត់ពោះរស់រួចប៉ុណ្ណោះ ។

(២) ឱកាសល ជួនជាស្រុកនោះឯងកើតទុរ្ភិក្សអត់បាយ មនុស្សម្នាប្រជាជនទាំងឡាយក្រខ្សត់អត់ឃ្លានគ្មានអាហារភោជន , កើតចោរលួច-ប្លន់កាប់សម្លាប់អ្នកស្រុកជាទុក្ខវេទនាខ្លោចផ្សាព្រោះតែអត់អាហារផ្ទះ នាងមេម៉ាយនោះក៏គោងតែរុករានទន្ទ្រានចូលព្រៃដើម្បីស្វែងរកនុណា ផលនឹងមើមឈើផ្សេងៗ នាងខំស្វែងសារសៀរបមៀរក្សែរគីរីបពិតស្ទាត់ប្រៀបស្ទូនឡឈឹង មានសឹងតែម្រឹគសាហាវយង់ឃ្នង ពរភេទម្ដងៗ គ្រហឹមខ្ទរព្រៃគ្គរឲ្យភ័យតក់ស្លុតរន្ធត់ពន់ពេក ។

(៣) គ្រាបុព្វណ្ហសម័យមួយ ព្រះអរុណោទ័យទើបតែនឹងរះបំព្រាងៗ ; ផ្ទៃមេឃក្រហមព្រឿងឡើងពណ៌លឿងដូចជាពណ៌មាស ;ហើយក្រឡាស់ជាពណ៌លោហិតក្រហមឡើងធ្លុះ តែមួយសន្ទុះក៏លេចសុរិយវិមានពេញរង្វង់មូលក្លំអណ្ដែតគ្រៀន ៗលយលឿនលើអាកាសវេហាស៍នភាល័យ បញ្ចាំងស្ទូរសែងរស្មីផ្សាយផ្សប់ចប់ពិភពលោក ពួកទិជចរក៏គ្រាកករកអាហារតែរៀងខ្លួន , សត្វតាកាក៏ស្រែកហៅផ្ទួនៗ ថាទៅៗ , ដល់លំនៅនាងមេម៉ាយនាងក៏ប្រកាយភ្ញាក់ឡើងដាស់កូនឲ្យមើល ថែទាំប្អូន ប្រុសច្បងក៏ចុះចាកគ្រឹហា ស្ពានបរសំដៅស្មសានព្រៃក្លុំស្ងាត់ជ្រងំគួរខ្លាចពន់ពេក , ថែមទាំងមានអាភេទបម្រែកសត្វក្អែកហើរមកឆាបមុខនាង គួរឲ្យរញ្ញាក្រលៀវគ្រឹហាវិញ តែនាងនៅតែខំដើរទៅទាំងទុក្ខវេទនា ។

(៤) នៅឋានមហាស្ថានតិរច្ឆាននោះឯង សឹងមានរុក្ខជាតិលូតលាស់លេចគ្រប់ជាតិពណ៌ផ្សេង ៗ គួរឲ្យពិតពិលរម៉ិលមើល ល្អស្រណុកសុខសប្បាយ ពន្លកកាយតាមចិត្តក្រពេក , ដីជាលំនៅនៃហ្វូងបក្សាបក្សីផង : មានទាំងទឹកជ្រោះជ្រៅជ្រះថ្លាផ្អែមយល់ដី មានផលជាតិណែនណាន់តាន់តាប់ប្រដាប់ដោយឈើផ្កាផង រយោនរយានរីករុះស្គុសស្កាយផ្សាយក្លិនគន្ធពិដោរក្រអូបល្ហិងល្ហើយ ជាបើអ្នកណាមួយបានចូលទៅដល់ទីនោះហើយ ក៏សឹងសប្បាយរីករាយសុខក្សេមក្សាន្ត ហាក់ដូចជាបានចូលទៅកាន់នន្ទនឧទ្យានឋានត្រៃត្រឹង្សសួគ៌ាល័យ ។

(៥) បើទុកណាជាដល់ម្ល៉ោះក៏ដោយ នេះតែនាងមេម៉ាយ រកសប្បាយរីករាយមិនបាន ព្រោះនឹកប្រយោគដល់ប្ដីណា ដែលជាអ្នកទាល់ក្រកំសត់មានសំពត់ស្លៀកដណ្ដប់រយេវរយាករយ៉ីរយ៉ៃរយ៉ុក-រយាកលេចមុខលេចក្រោយ , សំពត់នោះទៀតសើមផ្អូមផ្អូរក្លិនធុំអាបឆ្អេះគ្រប់គ្រាបើ ណាគិតអាណិតប្រណីដល់កូនទាំងពីរ ដែលនៅកំព្រាកំព្រាកណ្ដែងកណ្ដោចកណ្ដាលព្រៃហិមពាន្ត ស្រេកឃ្លានគ្មានបោះ ភាជន៍គិតសព្វគ្រប់ទៅសែនសង្វេគអណោចអាធ័មអាណិតអាសោចអនិច្ចាខ្លួនពេក ទឹកភ្នែកក៏ហៀរហូរជោរជល់ស្រក់សស្រាកជោគត្រា ។

(៦) អស្ចារ្យប៉ុណ្ណោះឯង មហាមួយសឹងផេរផាសពាសពេញដោយពពកខ្មៅខ្មួល ហាក់ដូចជាទឹកស្រក់ស្រុតធ្លាក់ចុះមក រាយោបក់បោកប្រូលប្រូលត្រឡប់ត្រឡិនរលេវរលាវ ផ្ការលាទគ្គិលៗផង , ផ្គរបន្លឺរគ្រឹមៗ ផ្លេកប្រពាត , រន្ទះអសនីបាញ់ចុះគគ្រឹកគគ្រេងកក្រើកពសុធា ; ព្រះពិរុណក៏បង្អុរចុះព្រិចៗព្រិចៗរៅៗ វិលាសស្រោកមិនដាច់រយៈ គួរឲ្យត្រជាក់រងាពេកណាស់ លោកអើយ! ប៉ុន្តែនាងមេម៉ាយគ្មានរងាត្រជាក់សោះឡើយ បែរជាបែកញើសដោតខ្លួនទៅវិញ ព្រោះនាងខំប្រឹងខ្នះយាតជីកកកាយក្ដុបក្ដាត ខ្វះចៀលគាស់រំលើងមើមក្រាដែងឡូងនានា ; មិនបានឈប់ឈរសម្រាកសម្រាន្តលំហែប្រាណសោះឡើយ ។

(៧) — ឯនៅមីមាតាទាំងឡាយក្នុងលោកទាំងអស់សឹងដូចគ្នា សុខចូលរងទុក្ខលំបាកវេទនាដោយខ្លួនឯង ប្រាថ្នាឲ្យតែកូនគាត់បានសេចក្តីសុខ បើកូនមានទោសទុក្ខឧបសគ្គគ្រោះថ្នាក់អ្វីមួយ ក៏កើតទុក្ខព្រួយពន់ប្រមាណ ប្រសិនជាផ្ទេរមកដាក់ខ្លួនឯងបានក៏ស៊ូទទួលរងវេទនាខ្លាចផ្សា ឲ្យតែកូនគាត់បានសុខក្សេមក្សាន្តរីករាយសប្បាយ , ឯនាងមេម៉ាយក៏ជាម្ដាយស៊ូរងទុក្ខវេទនាដូច្នោះ ព្រោះតែក្ដីអនុគ្រោះចំពោះកូនស៊ូបូជាជីវិតខ្លួនមិនមានស្ដាយ មិនខ្លាចអន្តរាយដល់ខ្លួនឡើយ ,,

( មានត )

# សេចក្ដីជូនដំណឹង

ក្រសៀវភៅទស្សនាវដ្ដី មិត្តសាលាបាលីប្រពៃណាស់ បានផ្លាស់រូបរាងពីបែបចាស់
មានផ្លាស់អក្សរនឹងរូបភាព ។ ផ្សាយចេញផ្សំលោកនឹងធម៌ អត្ថបទដ៏ល្អមានខ្លះតាម
ធ្វើឲ្យអ្នកអានបានជ្រួតជ្រាប សភាពសាសនា - អក្សរសាស្ត្រ ។ សូមអស់ព្រះសង្ឃនឹងលោកអ្នក
ជួយជាវតាមសទ្ធាយ៉ាងរហ័ស ដោយផ្ញើបច្ច័យឬប្រាក់កាស់ ថ្លៃល្មមជាវណាស់មួយរយរៀល ។
គឺក្នុងមួយចប់ដល់ពីរលេខ គួរតែជួយត្រេកកុំតិះដៀល ជាថ្លៃហួសពេកមួយរយរៀល
ដប់រៀលមួយលេខមិនថ្លៃទេ ។ បើអស់លោកនៅក្រៅកម្ពុជា ថ្លៃនោះខុសគ្នាមិនដូចគេ
លើសតែម្ភៃរៀលប៉ុណ្ណោះទេ គិតបូករួមមួយរយម្ភៃ ។ ថ្លៃដប់ពីររៀលក្នុងមួយលេខ
មិនជាថ្លៃពេកល្មមលក់លែ ជាវយកទៅអានល្អប្រពៃ ប្រាជ្ញានឹងវៃស្ដីឈ្លាស ។
ម្យ៉ាងទៀតសូមជួយផ្សាយឃោសនា ដល់ជនខេមរឲ្យពេញពាស នឹងជនបរទេសមន្ត្រី - រាស្ត្រ
សូមកុំខ្ចីសពាសប្រយ័ត្នស្ដាយ ។ សូមផ្ញើនាមនឹងអាសយដ្ឋាន ឲ្យបានប្រញាប់កុំបីណាយ
ទៅមន្ទីរសំណាក់ការផ្សាយ នឹងបានខ្វល់ខ្វាយផ្ញើមកវិញ ។ ជូនដល់អស់លោកឲ្យបានឆាប់
ប្រញាប់មិនឲ្យមានទោម្ញិញ រាល់ពេលដែលបានសៀវភៅចេញ ពីរោងពុម្ពវិញនោះឯណា ។
ឆាប់ ៗ ជាវទៅនៅតិចណាស់ សូមឲ្យរហ័សកុំសារ៉ា បកមកមើលអានបុទស្សនា
បណ្ដុះប្រាជ្ញាគំនិតហើយ ។

កាំ - ម៉ែ

លេខាធិការសមាគមមិត្តសាលាបាលី